មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

ខែធ្នូ
២០១២

# ឥន្ទធនូខ្មែរ៖ ប្រែការរើសអើងទៅជាមោទនភាព



## អំពីមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (ម.ស.ម.ក) ជាអង្គការមិនមែនរដ្ឋាភិបាល មិនចូលបក្សសម្ព័ន្ធ ឯករាជ្យឈានមុខ ដែលធ្វើការដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស ពិសេសសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ នៅកម្ពុជា។ ចក្ខុវិស័យរបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា គឺចង់ឲ្យកម្ពុជាក្លាយជាព្រះរាជាណាចក្រមួយគ្មានអំពើហិង្សា ដែលក្នុងនោះប្រជាពលរដ្ឋទទួលបានសិទ្ធិជាមូលដ្ឋាន មានសមភាព ត្រូវបានអនុញ្ញាតឲ្យចូលរួមក្នុងលទ្ធិប្រជាធិបតេយ្យ និងទទួលបានផលប្រយោជន៍ពីការអភិវឌ្ឍប្រទេស។ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ចង់បាននីតិរដ្ឋជាជាងនិទណ្ឌភាព ចង់បានស្ថាប័នរឹងមាំជាជាងបុគ្គលខ្លាំង និងចង់បានសង្គមពហុនិយម ដោយក្នុងនោះភាពចម្រុះបែបនៃសង្គមត្រូវបានទទួលយក និងសាទរ ជាជាងព្រងើយកន្តើយ ឬដាក់ទណ្ឌកម្ម។ ស្លាកសញ្ញារបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា រំលេចឲ្យឃើញរូបសត្វព្រាបសហើរចេញពីរង្វង់មូលនៃផ្ទៃមេឃពណ៌ខៀវ ដែលនេះជានិមិត្តរូបនៃការទាមទារសេរីភាពរបស់កម្ពុជា។

របាយការណ៍ដែលមានចំណងជើងថា "ឥន្ទធនូខ្មែរ៖ ប្រែការរើសអើងទៅជាមោទភាព" គឺជាលទ្ធផលនៃការអនុវត្តគម្រោងនិន្នាការភេទនិងអត្តសញ្ញាណយេនឌ័រ (ហៅកាត់ថា "គម្រោងសូជី") របស់ម.ស.ម.ក។

## សេចក្តីថ្លែងអំណរគុណ

របាយការណ៍នេះ កើតជារូបរាងឡើងបាន គឺដោយសារកិច្ចឧបត្ថម្ភគាំទ្រ របស់សមាគមស៊ុយអែតដើម្បីអប់រំខាងផ្នែកភេទ តាមរយៈទីភ្នាក់ងារសហប្រតិបត្តិការសម្រាប់ការអភិវឌ្ឍអន្តរជាតិស៊ុយអែត ហៅកាត់ថា«ស៊ីដា»។ ខ្លឹមសារនៃរបាយការណ៍នេះ ជាការទទួលខុសត្រូវទាំងស្រុងរបស់ម.ស.ម.ក។

ម.ស.ម.ក សូមថ្លែងអំណរគុណដល់ស្ថាប័ន លីងខ្លេទ័រ អិល.អិល.ភី (Linklaters LLP) ដែលបានធ្វើការសិក្សាស្រាវជ្រាវបែបប្រៀបធៀប ទៅលើច្បាប់នៃប្រទេសអង់គ្លេសនិងវែលស៍ ហុងកុង ហូឡង់ និងសហរដ្ឋអាមេរិក។ ការស្រាវជ្រាវនេះចូលរួមចំណែកយ៉ាងសំខាន់ ក្នុងការចងក្រងជារបាយការណ៍នេះឡើង។

ម.ស.ម.ក ក៏សូមថ្លែងអំណរគុណផងដែរ ដល់ក្រុមតស៊ូមតិសម្រាប់ការអភិវឌ្ឍអន្តរជាតិ ដែលហៅកាត់ថា អេ.ហ្វ័រ.អាយ.ឌី (A4ID) ដែលបានជួយសម្របសម្រួល ដល់កិច្ចការស្រាវជ្រាវនេះ។

## ចម្ងល់ និងមតិចូលរួម

ប្រសិនលោកអ្នកមានសំនួរ ឬត្រូវការព័ត៌មានបន្ថែម ពាក់ព័ន្ធនឹងរបាយការណ៍នេះ ឬមានបំណងចង់ផ្តល់ជាមតិយោបល់ សូមសរសេរជាអ៊ីមែលមកកាន់ ម.ស.ម.ក តាមរយៈ info@cchrcambodia.org ។ ម្យ៉ាងទៀត លោកអ្នកអាចទាក់ទងម.ស.ម.ក តាមរយៈ៖


អាសយដ្ឋាន៖ ផ្ទះលេខ៧៩៨ ផ្លូវ៩៩ បឹងត្របែក ចំការមន ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

អ៊ីមែល៖ info@cchrcambodia.org

ទូរស័ព្ទ៖ ៨៥៥(០)២៣ ៧២ ៦៩ ០១

ទូរសារ៖ ៨៥៥(០)២៣ ៧២ ៦៩ ០២

គេហទំព័រ៖ www.cchrcambodia.org

# មាតិកា

និយមន័យ និងពាក្យកាត់ ..... i
សន្ទានុក្រម ..... iii
ខ្លឹមសារសង្ខេប ..... iv
១. សេចក្តីផ្តើម ..... ១
២. គោលបំណង វិសាលភាព និងវិធីសាស្ត្រ ..... ៤
៣. បរិបទប្រទេសកម្ពុជា ..... ៦
៤. ការផ្តល់អនុសាសន៍ ខាងទិដ្ឋភាពច្បាប់និងទិដ្ឋភាពមិនមែនច្បាប់ ..... ៨
៤.១. ការរើសអើងទូទៅប្រឆាំងនឹងបណ្តាជន ក.ដ.ព.ប ..... ៨
៤.២. អាស៊ាន ..... ១៤
៤.៣. ជីវិតគ្រួសារ ..... ១៧
៤.៤. អាពាហ៍ពិពាហ៍រវាងអ្នកស្រឡាញ់ភេទដូចគ្នា ..... ១៩
៤.៥. សហគមន៍ ..... ២២
៤.៦. ការអប់រំ ..... ២៧
៤.៧. ការងារ ..... ៣០
៤.៨. សេវាសុខភាព ..... ៣៤
៤.៩. បណ្តាញសារព័ត៌មាន ..... ៣៨
៥. សេចក្តីសន្និដ្ឋាន ..... ៤៣
៦. គន្ថនិទ្ទេស ..... ៤៥
ឧបសម្ព័ន្ធ៖ អង្គការមិនមែនរដ្ឋាភិបាលធ្វើការលើវិស័យសិទ្ធិរបស់បណ្តាជនក.ដ.ប.ប នៅកម្ពុជា ..... ៥៤

# និយមន័យ និងពាក្យកាត់

| | |
|---|---|
| ស.ប.ស.អ | សេចក្តីប្រកាសស្តីពីសិទ្ធិមនុស្សអាស៊ាន |
| អាស៊ាន | សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ |
| បណ្តាញចតុមុខ | បណ្តាញចតុមុខ |
| គម្រោងធុរកិច្ចនិងសិទ្ធិមនុស្ស | គម្រោងធុរកិច្ចនិងសិទ្ធិមនុស្ស របស់ម.ស.ម.ក |
| អ.ត.ប | អង្គការតេន្ទធនូបាងកក |
| កម្ពុជា | ព្រះរាជាណាចក្រកម្ពុជា |
| ម.ស.ម.ក | មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា |
| គ.ស.ស.ស.វ | គណៈកម្មាធិការអង្គការសហប្រជាជាតិ ស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ |
| រដ្ឋធម្មនុញ្ញ | រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ (យោងតាមវិសោធនកម្ម) |
| អ.ស.ស | អង្គការសង្គមស៊ីវិល |
| ច្បាប់ស្តីពីសមភាព | ច្បាប់ស្តីពីសមភាព ២០១០ (ចក្រភពអង់គ្លេស) |
| ច.ប.ស | ច្បាប់ស្តីពីការប្រណិបត្តិដោយស្មើភាព (ហូឡង់) |
| ហ៊ីវ/អេដស៍ | វីរុសដែលធ្វើឲ្យប្រព័ន្ធស៊ាំនឹងមេរោគថយចុះ/រោគសញ្ញាដែលធ្វើឲ្យប្រព័ន្ធស៊ាំនឹងមេរោគថយចុះ |
| ក.អ.ស.ព.ន | កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ |
| ក.អ.ស.ស.ស.វ | កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ |
| ទ.អ.ប.រ.អ..ស.ភ.ប.ភ | ទិវាអន្តរជាតិប្រឆាំងនឹងការរើសអើងអ្នកស្រឡាញ់ភេទដូចគ្នា និងអ្នកប្តូរភេទ |
| គ.អ.ស.អ.ស.ប.ប.ស.ស | គណៈកម្មការអន្តរជាតិ សិទ្ធិមនុស្សបុរសស្រឡាញ់បុរស និងស្ត្រីស្រឡាញ់ស្ត្រី |
| ស.អ.ស.ភ.អ.ព.ភ.ប.ភ.អ.ភ | សមាគមអ្នកស្រឡាញ់ភេទដូចគ្នា អ្នកស្រឡាញ់ភេទទាំងពីរ អ្នកប្តូរភេទ និងអន្តរភេទ |
| ស.អ.រ.ផ.គ | សហព័ន្ធអន្តរជាតិរៀបចំផែនការគ្រួសារ |
| ច.គ.ថ | ច្បាប់ស្តីពីការគ្រប់គ្រងថ្នាំញៀន ឆ្នាំ២០០៥ |
| ភ.ដ.ព.ប | ស្ត្រីស្រឡាញ់ស្ត្រី បុរសស្រឡាញ់បុរស (ឬហៅថាអ្នកស្រឡាញ់ភេទដូចគ្នា) អ្នកស្រឡាញ់ទាំងពីរភេទ និងអ្នកប្តូរភេទ |
| បញ្ជី ភ.ដ.ព.ប | យុទ្ធនាការស្តីពីសិទ្ធិមនុស្ស "ទីកន្លែងល្អបំផុតសម្រាប់ធ្វើការដើម្បីសមភាពរបស់ ភ.ដ.ព.ប" |
| បណ្តាញ ភ.ដ.ព.ប | បណ្តាញ ភ.ដ.ព.ប អាស៊ាន |
| វេទិកា ភ.ដ.ព.ប.អ.អ | វេទិកាអាស៊ានស្តីអំពីអ្នកស្រឡាញ់ភេទដូចគ្នា ស្រឡាញ់ទាំងពីរភេទ អ្នកប្តូរភេទ អន្តរភេទ និងភេទមិនច្បាស់ |
| ច្បាប់ទប់ស្កាត់ការជួញដូរផ្លូវភេទ | ច្បាប់ស្តីពីការទប់ស្កាត់អំពើជួញដូរ និងការកេងប្រវ័ញ្ចផ្លូវភេទ ឆ្នាំ២០០៨ |
| សុខភាពបុរសនៅកម្ពុជា | សុខភាពបុរសនៅកម្ពុជា |
| បុរសស្រឡាញ់បុរស | បុរសស្រឡាញ់បុរស |
| កម្មវិធីជាតិចម្រុះប្រឆាំងនឹងអំពើហិង្សា | កម្មវិធីជាតិចម្រុះប្រឆាំងនឹងអំពើហិង្សា |
| អង្គការ | អង្គការមិនមែនរដ្ឋាភិបាល |

| | |
|---|---|
| ក.ឧ.ស.ស | ការិយាល័យឧត្តមស្នងការសិទ្ធិមនុស្ស |
| ក្រមព្រហ្មទណ្ឌ | ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ |
| គម្រោងសាច់ញាតិរបស់អ្នកស្រឡាញ់ភេទដូចគ្នា | គម្រោងឪពុកម្ដាយ ក្រុមគ្រួសារ និងមិត្តភក្តិរបស់អ្នកស្រឡាញ់ភេទដូចគ្នា |
| វិបសាយ | ឥន្ទធនូខ្មែរ |
| គម្រោងសូជី | គម្រោងនិន្នាការភេទនិងអត្តសញ្ញាណយេនឌ័រ អនុវត្តដោយ ម.ស.ម.ក |
| របាយការណ៍ | របាយការណ៍នេះ ចំណងជើង "ឥន្ទធនូខ្មែរ ៖ ប្រៃពីការរើសអើងទៅជាមោទនភាព" |
| រដ្ឋាភិបាល | រាជរដ្ឋាភិបាលកម្ពុជា |
| រ៉ក់ | សមាគមឥន្ទធនូកម្ពុជា |
| សូជី | និន្នាការភេទ និង/ឬ អត្តសញ្ញាណយេនឌ័រ |
| ច្បាប់ស្តីពីការមិនរើសអើង | ច្បាប់ស្តីពីការមិនរើសអើងលើនិន្នាការភេទទីក្រុងញូវយ៉ក ឆ្នាំ២០០៣ |
| មេរោគឆ្លង | ការឆ្លងរោគតាមការរួមភេទ |
| ស.ស.ប | សង្គមស្ត្រីប្តូរភេទនៅប្រទេសហ្វីលីពីន |
| ម.អ.ផ.ស | មូលនិធិអ្នករកស៊ីផ្តល់សេវាជាក្រុម |
| ស.ប.ស.ស | សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស |
| ចក្រភពអង់គ្លេស | ចក្រភពអង់គ្លេស |
| ស.ហ | សហប្រជាជាតិ |
| យូណេស្កូ | អង្គការសហប្រជាជាតិស្តីពីការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ |
| ក.ស.ម.អ.ស.ប | ក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ |
| របាយការណ៍ ស.ហ | របាយការណ៍របស់ ឧត្តមស្នងការសិទ្ធិមនុស្សសហប្រជាជាតិ ស្តីពី "ច្បាប់ និងការអនុវត្តន៍ដែលមានភាពរើសអើង និងសកម្មភាពហិង្សាមកលើបុគ្គលដោយផ្អែកលើនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ" (១៧ វិច្ឆិកា ២០១១) |
| សេចក្តីសម្រេច អ.ស.ប | សេចក្តីសម្រេចរបស់ អ.ស.ប ស្តីពីសិទ្ធិមនុស្ស និន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ |
| សហរដ្ឋអាមេរិក | សហរដ្ឋអាមេរិក |
| គ.ភ.ឃ.ស | គោលនយោបាយភូមិឃុំមានសុវត្ថិភាព |
| គោលការណ៍យ៉កយ៉ាកាតា | គោលការណ៍ស្តីពីការអនុវត្តន៍ច្បាប់សិទ្ធិមនុស្សអន្តរជាតិពាក់ព័ន្ធនឹងនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ (សម្រេចចុងក្រោយនៅទីក្រុងយ៉កយ៉ាកាតា ឥណ្ឌូណេស៊ី ឆ្នាំ ២០០៦) |
| របាយការណ៍ ឆ្នាំ២០១០ | "ចេញជាចំហរនៅព្រះរាជាណាចក្រកម្ពុជា ៖ ពលរដ្ឋខ្មែរដែលស្រលាញ់ភេទដូចគ្នា" របាយការណ៍ បោះពុម្ពផ្សាយ ដោយ ម.ស.ម.ក ខែធ្នូ ឆ្នាំ២០១០ |

# សន្ទានុក្រម

| | |
|---|---|
| **គ្រូខ្មែរ** | ពាក្យខ្មែរសំដៅដល់គ្រូពេទ្យ ឬអ្នកព្យាបាលបែបបុរាណ ដែលធ្វើការនៅទូទាំងប្រទេស និងជាពិសេសក្នុងតំបន់ជនបទ ហើយប្រើប្រាស់រុក្ខជាតិថ្នាំជាចម្បង។ |
| **ខ្ទើយ** | ពាក្យខ្មែរដែលត្រូវបានប្រើ ដើម្បីពិពណ៌នាពីបុគ្គលទាំងឡាយ ដែលមានសភាពលក្ខណៈភេទជាបុរសឬស្ត្រីពីកំណើត ប៉ុន្តែបង្ហាញនូវចរិតលក្ខណៈ ឬអាកប្បកិរិយារបស់ភេទផ្ទុយ។ ពាក្យនេះតែងតែត្រូវបានប្រើ សម្រាប់ពិពណ៌នាបុរសដែលចូលចិត្តតែងខ្លួនជាស្ត្រី។ ពាក្យនេះក៏ប្រើសំដៅដល់អ្នកប្តូរភេទផងដែរ។ ទោះបីជាអ្នកប្តូរភេទមួយចំនួន ប្រើពាក្យ "ខ្ទើយ" ដើម្បីសំដៅដល់ខ្លួនគេផ្ទាល់ ប៉ុន្តែការប្រើពាក្យនេះត្រូវបានចាត់ទុកថា មានលក្ខណៈប្រមាថនិងមើលងាយប្រសិនបើប្រើប្រាស់ដោយអ្នកដទៃទៀតទៅលើពួកគេ។ |
| **ក្រមា** | ក្រមាមានប្រើតាំងពីបុរមបូរាណនៅកម្ពុជា ហើយគឺជាសញ្ញាជាតិរបស់កម្ពុជា។ |
| **ឡាដឡាដ** | ជាភាសា (ភាសានិយាយរបស់ប្រសហ្វីលីពីន) ដែលសំដៅដល់ "ចេញជាចំហ"។ |

# ខ្លឹមសារសង្ខេប

នៅប៉ុន្មានឆ្នាំចុងក្រោយមកនេះ ទាំងការគាំទ្រនិងភាពសកម្ម ក្នុងការកាត់បន្ថយការរើសអើងដែលកំពុងបន្តកើតមានចំពោះ អ្នកស្រឡាញ់ភេទដូចគ្នា ស្រឡាញ់ទាំងពីរភេទ និងអ្នកប្តូរភេទ (ភ.ដ.ព.ប) មានលក្ខណៈប្រសើរឡើងក្នុងពិភពលោក។ ខណៈដែលឋានៈជាប្រធានអាស៊ានជិតផុតអណត្តិ នេះជាឱកាសមួយដ៏ល្អសម្រាប់កម្ពុជាក្នុងការលើកកម្ពស់មុខមាត់របស់ខ្លួនតាមរយៈការយោគយល់ដល់ក្រុមភ.ដ.ព.ប ហើយនេះនឹងក្លាយជាគំរូល្អមួយ ក្នុងការធ្វើឲ្យប្រសើរឡើង នូវសមភាពនិងការប្រយុទ្ធប្រឆាំងនឹងការរើសអើង។ អាស្រ័យហេតុនេះ របាយការណ៍នេះមានគោលបំណង ផ្តល់អនុសាសន៍ ទាំងក្នុងបរិបទច្បាប់និងមិនមែនច្បាប់ ដើម្បីបង្កើតជាទស្សនវិស័យវិជ្ជមាន គាំទ្រដល់ដំណើរការខាងលើ ដែលនឹងជួយដល់រដ្ឋាភិបាលកម្ពុជា ក្នុងការដឹកនាំប្រទេសឆ្ពោះទៅអនាគតដ៏ត្រចះត្រចង់។

**ជំពូកទី១ (សេចក្តីផ្តើម)** បរិយាយអំពីគោលបំណងនៃរបាយការណ៍នេះ និងធ្វើការពិភាក្សាជុំវិញវិវឌ្ឍនាការនិងការផ្លាស់ប្តូរ ពាក់ព័ន្ធនឹងសិទ្ធិរបស់បណ្តាជនភ.ដ.ព.ប ទាំងនៅលើពិភពលោកនិងនៅកម្ពុជា។

**ជំពូកទី២ (គោលបំណង វិសាលភាព និងវិធីសាស្ត្រ)** ផ្តល់ជាទិដ្ឋភាពរួមនៃវិធីសាស្ត្រដែលបានប្រើប្រាស់សម្រាប់កិច្ចស្រាវជ្រាវ និងពង្រាងរបាយការណ៍នេះ។

**ជំពូកទី៣ (បរិបទកម្ពុជា)** ផ្តល់ទិដ្ឋភាពសង្ខេប អំពីចលនារបស់បណ្តាជនភ.ដ.ព.ប ដែលកំពុងប្រព្រឹត្តទៅក្នុងប្រទេសកម្ពុជា និងបញ្ហាប្រឈមនានាដែលបណ្តាជនភ.ដ.ព.បកំពុងជួបប្រទះ។

**ជំពូកទី៤ (ការផ្តល់អនុសាសន៍ ខាងទិដ្ឋភាពច្បាប់និងទិដ្ឋភាពមិនមែនច្បាប់)** ចាប់ផ្តើមពីចំណុចវិភាគទិដ្ឋភាពច្បាប់ទូទៅនៅកម្ពុជាដោយឆ្លុះបញ្ចាំងលើបញ្ញត្តិមានស្រាប់ ដែលធានាដល់សិទ្ធិភ.ដ.ព.ប និងផ្តល់អនុសាសន៍ជាក់លាក់។ បន្ទាប់មក ជំពូកនេះនឹងធ្វើការពិនិត្យលើទិដ្ឋភាពជាក់លាក់នៃជីវភាពរបស់បណ្តាជនភ.ដ.ព.ប រួមមានគ្រួសារ សហគមន៍ សុភាព អប់រំ ជាដើម ហើយនឹងដាក់ចេញអនុសាសន៍ ទាំងខាងផ្នែកច្បាប់ និងផ្នែកមិនមែនច្បាប់ ដើម្បីឲ្យឆ្លើយតបនឹងទិដ្ឋភាពទាំងអស់នេះ។ សម្រាប់ជំពូកមួយនេះ ច្បាប់និងគំនិតផ្តួចផ្តើមដែលអាចអនុវត្តបាន ដែលដកស្រង់ចេញពីប្រទេសផ្សេងៗ នឹងត្រូវបានលើកយកមកបង្ហាញ សម្រាប់ប្រៀបធៀបនិងតាក់តែងជាអនុសាសន៍ឡើង។

ជាចុងក្រោយ **ជំពូកទី៥ (សេចក្តីសន្និដ្ឋាន)** សង្ខេបនូវចំណុចសំខាន់ៗ និងអនុសាសន៍នានា ដូចមានបានលើកក្នុងជំពូកទី៤ ហើយធ្វើការសន្និដ្ឋានថាមានតម្រូវការចាំបាច់និងជាបន្ទាន់ ក្នុងការបង្កើតយន្តការច្បាប់ជាក់លាក់មួយ ដែលអាចការពារនិងលើកស្ទួយ សិទ្ធិរបស់បណ្តាជនភ.ដ.ព.បនៅកម្ពុជា នោះទើបអាចបង្កើតនូវសង្គមសមភាពមួយពិតប្រាកដបាន ដែលបុគ្គលគ្រប់រូបអាចក្លាយជាអ្វីដែលខ្លួនប្រាថ្នា ហើយមិនរងទុក្ខដោយសារតែលទ្ធផលនៃបំណងប្រាថ្នានោះ។ ការកែប្រែឬការអនុម័តច្បាប់ដែលពាក់ព័ន្ធអាចជាជំនួយដ៏សំខាន់ក្នុងការផ្លាស់ប្តូរគំនិតនិងទស្សនៈ រើសអើងរបស់សាធារណជនលើក្រុមភ.ដ.ព.ប ហើយធ្វើដូច្នេះអាចផ្តួចផ្តើមឲ្យមានការផ្លាស់ប្តូរជាវិជ្ជមានក្នុងជីវភាពរបស់ភ.ដ.ព.ប។ លើសពីនេះទៀតនោះ រដ្ឋាភិបាលត្រូវតែចាត់វិធានការឲ្យ

បានសមស្របដើម្បីធានាថាច្បាប់ឬគោលនយោបាយបច្ចុប្បន្ននឹងមិនត្រូវបានប្រើប្រាស់ដើម្បីរើសអើងមកលើក្រុម ភ.ដ.ព.ប។ បន្ថែមពីលើការអនុម័តច្បាប់ដែលពាក់ព័ន្ធនឹងការប្រឆាំងការរើសអើងដែលរួមបញ្ចូលនូវយន្តការដ៏មានប្រសិទ្ធភាពក្នុងការអនុវត្តន៍ច្បាប់ទាំងនោះ រដ្ឋាភិបាលអាចចូលរួមលើកកម្ពស់ការយល់ដឹងអំពីក្រុម ភ.ដ.ព.ប និងបញ្ហារបស់ពួកគាត់ និងផ្តួចផ្តើមឲ្យមានការអប់រំដល់មន្ត្រីរដ្ឋាភិបាលនិងអាជ្ញាធរមានសមត្ថកិច្ចសាធារណជនទូទៅ និងតាមសាលារៀននិងសកលវិទ្យាល័យ។ ជាចុងក្រោយ គឺតម្រូវឲ្យមានសកម្មភាពទាំងពីសំណាក់រដ្ឋាភិបាល និងសង្គមស៊ីវិលដើម្បីដោះស្រាយបញ្ហារើសអើងមកលើក្រុម ភ.ដ.ព.ប ក្នុងគោលបំណងដើម្បីឲ្យពួកកាត់អាចទទួលបានកន្លែងសមរម្យនិងត្រឹមត្រូវរបស់ពួកគាត់រួមជាមួយនឹងប្រជាពលរដ្ឋទូទៅ ដែរនិងដើម្បីឲ្យពួកកាត់មានអារម្មណ៍ថាមានអំណាចនិងទទួលបានការការពារគ្រប់គ្រាន់ ដើម្បីឲ្យពួកគាត់អាចរួមចំណែកយ៉ាងពេញលេញទៅក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គម និងវប្បធម៌ក្នុងប្រទេសកម្ពុជា។ តាមរយៈការប្រកាន់យកនូវតម្លៃនៃការអត់ឱន និងភាពចម្រុះ កម្ពុជានឹងក្លាយទៅជាប្រទេសដែលមានបាននិងរស់រវើក ហើយនឹងអាចបង្កើតខ្លួនឯងឲ្យទៅជាពន្លឺនាំមុខក្នុងតំបន់បាន។

# ១. សេចក្តីផ្តើម

ក្នុងរយៈពេលពីរឆ្នាំ បន្ទាប់ពីរបាយការណ៍របស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា បានចេញផ្សាយកាលពីខែធ្នូ ឆ្នាំ២០១០ ផ្តោតទៅលើបណ្តាជនភ.ដ.ព.ប នៅប្រទេសកម្ពុជា ដែលមានចំណងជើងថា "ចេញជាចំហនៅព្រះរាជាណាចក្រកម្ពុជា៖ ពលរដ្ឋខ្មែរដែលស្រឡាញ់ភេទដូចគ្នា"[1] យើងសង្កេតឃើញមានការកើនឡើងនៃកិច្ចគាំទ្រនិងភាពសកម្មដើម្បីកាត់បន្ថយភាពរើសអើងមកលើបណ្តាជនភ.ដ.ព.ប នៅលើពិភពលោកយើងនេះ ។ ចលនាអន្តរជាតិនេះ ត្រូវបានបង្ហាញយ៉ាងច្បាស់តាមរយៈសេចក្តីសម្រេចរបស់អង្គការសហប្រជាជាតិ ដែលត្រូវបានអនុម័តដោយក្រុមប្រឹក្សាសិទ្ធិមនុស្ស កាលពីថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ដែលស្នើឲ្យមានការសិក្សាស្រាវជ្រាវលើការរើសអើងនិងនិន្នាការភេទ។[2] យោងតាមសេចក្តីសម្រេចរបស់អង្គការសហប្រជាជាតិ នេះជាលើកទីមួយ ដែលស្ថាប័នអង្គការសហប្រជាជាតិបានដាក់ចេញនូវសេចក្តីថ្លែងការណ៍ដែលមានលក្ខណៈខ្លាំងនិងបិតក្នុងឋានានុក្រមកម្រិតខ្ពស់ក្នុងការបញ្ជាក់អះអាងអំពីសិទ្ធិរបស់បណ្តាជនភ.ដ.ព.ប ឧត្តមស្នងការជាន់ខ្ពស់របស់អង្គការសហប្រជាជាតិ លោកស្រី ណាវី ភីឡៃ បានធ្វើការសិក្សាស្រាវជ្រាវមួយដែលគ្របដណ្តប់ជុំវិញពិភពលោកទាំងអស់ លើប្រធានបទទាំងនេះ។ ហើយលោកស្រីបានធ្វើបទបង្ហាញរបាយការណ៍របស់លោកស្រីជូនចំពោះក្រុមប្រឹក្សាសិទ្ធិមនុស្ស កាលពីខែធ្នូ ឆ្នាំ២០១១ (របាយការណ៍អង្គការសហប្រជាជាតិ)។[3] របាយការណ៍របស់លោកស្រី បានចងក្រងនូវអំពើហិង្សាទៅលើបណ្តាជនភ.ដ.ព.ប ដោយរាប់បញ្ចូលទាំងការរើសអើង ឧក្រិដ្ឋកម្មដែលបណ្តាលមកពីភាពស្អប់ខ្ពើម និងការដាក់បទឧក្រិដ្ឋចំពោះការស្រឡាញ់ភេទដូចគ្នា និងបានដាក់ចេញនូវអនុសាសន៍ឲ្យប្រើប្រាស់ច្បាប់អន្តរជាតិដើម្បីលុបបំបាត់អំពើហិង្សានិងការរំលោភសិទ្ធិមនុស្សដែលកើតចេញពីនិន្នាការភេទនិងអត្តសញ្ញាណយេនឌ័រ "សូជី"។ កាលពីខែមិនា ឆ្នាំ២០១២ លោកស្រី ណាវី ភីឡៃ បានអំពាវនាវដល់ក្រុមការងាររបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សឲ្យចាត់វិធានការនិង "*ទទួលស្គាល់ថាមានអំពើហិង្សានិងការរើសអើងយ៉ាងធ្ងន់ធ្ងរដែលត្រូវបានប្រព្រឹត្តទៅលើក្រុមភ.ដ.ព.ប ខណៈដែលយើងកំពុងតែនិយាយពីបញ្ហាផ្សេងៗទៀត*"។[4]

---

[1] ម.ស.ម.ក, ចេញជាចំហនៅព្រះរាជាណាចក្រកម្ពុជា៖ ពលរដ្ឋខ្មែរដែលស្រឡាញ់ភេទដូចគ្នា <www.cchrcambodia.org/index_old.php?url=media/media.php&p=report_detail.php&reid=8&id=5>។

[2] សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស (ឆ្នាំ២០១១) ឯកសាររបស់អង្គការសហប្រជាជាតិ A/HRC/17/L.9/Rev.1 <http://ap.ohchr.org/documents/dpage_e.aspx?si=A/HRC/17/L.9/Rev.1> ។

[3] របាយការណ៍របស់លោកស្រី ណាវី ភីឡៃ ស្តីអំពី "របាយការណ៍របស់ឧត្តមស្នងការជាន់ខ្ពស់ទទួលបន្ទុកសិទ្ធិមនុស្ស ស្តីពីច្បាប់និងការអនុវត្តន៍បែបរើសអើង និងទង្វើប្រកបដោយភាពហិង្សាលើបុគ្គលដោយហេតុតែនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័ររបស់ពួកគេ" ចេញផ្សាយថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១១។ ឯកសាររបស់អង្គការសហប្រជាជាតិ A/HRC/19/41 www.ohchr.org/Documents/HRBodies/HRCouncil/RegularSession/Session19/A-HRC-19-41_en.pdf។

[4] សេចក្តីថ្លែងការណ៍របស់លោកស្រី ណាវី ភីឡៃ ស្តីអំពី "សេចក្តីថ្លែងការណ៍របស់លោកស្រី ណាវី ភីឡៃ ឧត្តមស្នងការជាន់ខ្ពស់ទទួលបន្ទុកសិទ្ធិមនុស្ស ដាក់ជូនក្រុមការងារជុំវិញកិច្ចបញ្ចប់អំពើហិង្សា និងការរើសអើងប្រឆាំងនឹងបណ្តាជន

រដ្ឋបាលបច្ចុប្បន្នរបស់ប្រធានាធិបតីលោក បារ៉ាក់ អូបាម៉ា ក៏បានសម្តែងនូវជំហរគាំទ្ររបស់ខ្លួនដែលគួរឲ្យសរសើរ ដល់កិច្ចប្រឹងប្រែងនានាដើម្បីសមភាពរបស់បណ្តាជនក.ដ.ព.បជុំវិញពិភពលោក ស្របពេលដែលរដ្ឋមន្ត្រីក្រសួងការបរទេស លោកស្រី ហ៊ីឡារី គ្លីនតុន បានប្រកាសជាសាធារណៈថា *"សិទ្ធិរបស់ក.ដ.ព.ប គឺជាសិទ្ធិមនុស្ស ហើយមិនគួរត្រូវបានគេដាក់ជាបទល្មើសឧក្រិដ្ឋដោយសារហេតុផលជាក.ដ.ព.បនោះឡើយ"*។[5] លោកស្រីក៏បានប្រសាសន៍បន្ថែមទៀតថាប្រពៃណីវប្បធម៌ឬសាសនារបស់ប្រទេសមួយ មិនគួរត្រូវបានលើកមកជាសម្អាង ដើម្បីជាបុព្វហេតុរើសអើងនោះឡើយ។[6] បន្ថែមលើសនេះទៀត លោកប្រធានាធិបតី អូបាម៉ា ផ្ទាល់បានសម្តែងយ៉ាងចំហ ពីការគាំទ្ររបស់លោកចំពោះសិទ្ធិរៀបអាពាហ៍ពិពាហ៍របស់អ្នកស្រឡាញ់ភេទដូចគ្នាដោយលោកបានថ្លែងយ៉ាងដូច្នេះថា *"ខ្ញុំចង់ឲ្យមនុស្សគ្រប់គ្នាត្រូវបានគេគោរពដូចៗគ្នា [...] យើងនឹងមិនដើរផ្លូវខុសនោះទេ បើគ្រាន់តែយើងពង្រីកនូវវិសាលភាពសិទ្ធិ និងទំនួលខុសត្រូវដល់មនុស្សគ្រប់រូប។ នេះនឹងមិនធ្វើឲ្យសង្គមគ្រួសារធ្លាក់ចុះនោះទេ តែនឹងធ្វើឲ្យសង្គមគ្រួសារនោះរឹងមាំថែមទៀត។ នេះជារឿងត្រឹមត្រូវដែលគួរធ្វើ"*។[7]

សម្រាប់ថ្នាក់តំបន់វិញ អ្វីដែលគួរចង់ចាំនោះគឺថា ក្រុមអ្នកជំនាញអន្តរជាតិល្បីល្បាញផ្នែកសិទ្ធិមនុស្សអន្តរជាតិមួយក្រុមបានជួបប្រជុំគ្នានៅទីក្រុងយ៉កយ៉ាកាតានៃប្រទេសឥណ្ឌូនេស៊ី កាលពីឆ្នាំ២០០៦ ដើម្បីដាក់ចេញនូវគោលការណ៍អន្តរជាតិមួយ ពាក់ព័ន្ធនឹងនិន្នាការភេទនិងអត្តសញ្ញាណយេនឌ័រ សំដៅជាកិច្ចឆ្លើយតបនឹងការបំពានជាហូរហែរ ដែលត្រូវបានចងក្រងយ៉ាងត្រឹមត្រូវ។ លទ្ធផលនោះគឺដាក់ចេញនូវ *"មគ្គុទ្ទេសក៍ជាសកលស្តីពីសិទ្ធិមនុស្សមួយ ដែលធានាគាំពារនូវបទដ្ឋានច្បាប់អន្តរជាតិ ដោយភ្ជាប់នូវលក្ខខណ្ឌដែលរដ្ឋនីមួយៗត្រូវតែគោរព ...[និងដែល] ធានាអះអាងនូវអនាគតផ្សេងមួយ ដែលមនុស្សគ្រប់រូបកើតមកត្រូវមានសេរីភាពនិងសមភាព ខាងសេចក្តីថ្លៃថ្នូរនិងសិទ្ធិ"* ពោលគឺ "គោលការណ៍យ៉កយ៉ាកាតា"។

ខណៈដែលឋានៈជាប្រធានអាស៊ានជិតផុតអណត្តិ នេះជាឱកាសមួយដ៏ល្អសម្រាប់កម្ពុជា ក្នុងការលើកកម្ពស់មុខមាត់របស់ខ្លួនតាមរយៈការយោគយល់ដល់ក្រុមក.ដ.ព.ប ហើយនេះនឹងក្លាយជាគំរូល្អមួយក្នុងការធ្វើឲ្យប្រសើរឡើង នូវសមភាពនិងការប្រយុទ្ធប្រឆាំងនឹងការរើសអើង។ អាស្រ័យហេតុនេះ របាយការណ៍នេះមានគោលបំណងផ្តល់អនុសាសន៍ ទាំងក្នុងបរិបទច្បាប់និងមិនមែនច្បាប់ ដើម្បីបង្កើតជាទស្សនវិស័យវិជ្ជមាន គាំទ្រ

---

ដោយសារតែនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័ររបស់ពួកគេ" ( កិច្ចប្រជុំក្រុមប្រឹក្សាសិទ្ធិមនុស្សលើកទី១៩ នាថ្ងៃទី០៧ ខែមិនា ឆ្នាំ២០១២ )។ <www.ohchr.org/en/NewsEvents/Pages/DisplayNews.aspx?NewsID=11917&LangID=E> ។

[5] បទអន្តរាគមន៍របស់លោកស្រីហ៊ីឡារី គ្លីនតុន "ប្រសាសន៍ទទួលស្គាល់ទិវាសិទ្ធិមនុស្សអន្តរជាតិ" ( សាលអង្គការសហប្រជាជាតិ នៅហ្សឺណែវ នៃប្រទេសស្វីស នាថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១១។ <www.state.gov/secretary/rm/2011/12/178368.htm>

[6] ដូចខាងលើ។

[7] បទអន្តរាគមន៍របស់លោកប៉ារាក់ អូបាម៉ា "ប្រសាសន៍របស់ប្រធានាធិបតីក្នុងព្រឹត្តការណ៍យុទ្ធនាការមួយ" ( សារៈមន្ទីរសិល្បៈរូប៊ីន នៅទីក្រុងញូយ៉ក នាថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០១២។ <www.whitehouse.gov/the-press-office/2012/05/14/remarks-president-campaign-event> ។

ដល់ដំណើរការខាងលើ ដែលនឹងជួយដល់រដ្ឋាភិបាលកម្ពុជា ក្នុងការដឹកនាំប្រទេសឆ្ពោះទៅអនាគតដ៏ត្រចះត្រចង់។

ទោះបីជាយ៉ាងនេះក្តី កិច្ចការដែលប្រឈមបំផុតក្នុងការលើកកម្ពស់សមភាពនិងលុបបំបាត់ភាពលម្អៀង ភាពមិនពេញចិត្តនិងភាពរើសអើងមកលើបណ្តាជនក.ជ.ព.ប គឺការធ្វើឲ្យមានបន្លាស់ប្តូរវប្បធម៌មួយក្នុងសង្គមដែលនៅប្រកាន់ភ្ជាប់ភាពអភិរក្សនិយមនៅឡើយ។ ថ្វីត្បិតតែមានសញ្ញាណវិជ្ជមានក្តី ក៏ជោគជ័យទៅអនាគត នឹងទាមទារឲ្យមាន មិនត្រឹមតែការចូលរួមពីសំណាក់រាជរដ្ឋាភិបាលនិងអង្គការសង្គមស៊ីវិលនោះទេ តែថែមទាំងយន្តការសហការរវាងដៃគូនានាពីគ្រប់វិស័យទាំងអស់។

# ២. គោលបំណង វិសាលភាព និងវិធីសាស្ត្រ

របាយការណ៍កាលពីឆ្នាំ២០១០ បានបរិយាយអំពីទិដ្ឋភាពដែលសង្គមកម្ពុជាយល់ឃើញ ចំពោះការស្រឡាញ់ភេទដូចគ្នា ដោយបញ្ចូលទាំងទស្សនៈវប្បធម៌ សាសនា និងនយោបាយ និងវិភាគបញ្ហាប្រឈមដែលបណ្តាជនភ.ដ.ព.បប្រឈម ក្នុងនោះរួមមានការរើសអើងក្នុងមជ្ឈដ្ឋានការងារ នៅគេហដ្ឋាន សហគមន៍ និងនៅទីសាធារណៈ ជាពិសេសនោះគឺពីសំណាក់ភ្នាក់ងារអនុវត្តន្តច្បាប់ ដូចជាប៉ូលីសជាដើម។ របាយការណ៍កាលពីឆ្នាំ២០១០បានគូសបញ្ជាក់ថាបណ្តាជនភ.ដ.ព.បមានសិទ្ធិដូចបុគ្គលដទៃទៀតដែរ ដែលសិទ្ធិនេះត្រូវបានធានាដោយច្បាប់ជាតិនិងអន្តរជាតិ ហើយក៏បានធ្វើការកត់សម្គាល់ចំពោះការងើបឡើងនៃចលនាភ.ដ.ព.បនៅកម្ពុជាផងដែរ។

របាយការណ៍នេះមិនមានបំណងផ្តល់នូវទិដ្ឋភាពស្ថានភាព របស់ភ.ដ.ព.បនោះឡើយ តែរបាយការណ៍នេះនឹងផ្តល់នូវទស្សនៈវិស័យដែលថាបណ្តាជនភ.ដ.ព.បគួរត្រូវបានការពារដោយច្បាប់ ត្រូវបានគោរពនិងទទួលស្គាល់ជាសកល។ របាយការណ៍នេះផ្តោតលើយន្តការដាក់លាក់ដែលសម្លឹងមើលលើទិដ្ឋភាពផ្សេងៗនៃជីវិតរបស់បណ្តាជនភ.ដ.ព.ប ហើយថែមទាំងដាក់ចេញនូវអនុសាសន៍វិជ្ជមាន រួមបញ្ចូលទាំងបរិបទច្បាប់និងមិនមែនច្បាប់ ដែលនេះសំដៅគាំទ្រនិងជំរុញ ឲ្យទស្សនៈវិស័យនោះបានជោគជ័យ។ យើងត្រូវទទួលស្គាល់ស្ថានភាពបច្ចុប្បន្នដើម្បីធានាថារាល់អនុសាសន៍នានាដែលបានស្នើឡើងនៅក្នុងរបាយការណ៍នេះគឺសមហេតុផល ក៏ប៉ុន្តែ ទុកគ្រាន់តែជាសាវតារប៉ុណ្ណោះ ដោយរួមទាំង សេចក្តីសង្ខេបខ្លីអំពី "បរិបទកម្ពុជា" ដើម្បីជាកិច្ចនៃការចាប់ផ្តើមខ្លឹមសាររបាយការណ៍នេះ។ ខណៈដែលរបាយការណ៍ឆ្នាំ២០១០ ធ្វើការកំណត់នូវបញ្ហានានា របាយការណ៍ថ្មីនេះ ផ្តល់ជាដំណោះស្រាយ។

សម្រាប់អនុសាសន៍ផ្នែកច្បាប់ ដែលសំដៅដាក់ជូនទៅរដ្ឋាភិបាល និងគណបក្សជំទាស់ ដែលជាតួអង្គសំខាន់ក្នុងការផ្តើមគំនិតខាងនីតិបញ្ញត្តិនោះ ម.ស.ម.កបានវិភាគទិដ្ឋភាពច្បាប់របស់ប្រទេសកម្ពុជាដែលអាចអនុវត្តចំពោះបណ្តាជនភ.ដ.ព.ប ហើយបានកំណត់នូវចំណុចនានាដែលគួរត្រូវបានធ្វើការកែសម្រួលឲ្យប្រសើរឡើង។ បន្ថែមលើសនេះទៀតនោះ ក្នុងដំណាក់កាលនៃការធ្វើរបាយការណ៍នេះ កិច្ចស្រាវជ្រាវលម្អិតមួយពាក់ព័ន្ធនឹងនីតិបញ្ញត្តិជុំវិញប្រធានបទបណ្តាជនភ.ដ.ព.ប ត្រូវបានធ្វើឡើងនៅប្រទេសចំនួន ៨ គឺ ហុងកុង ឥណ្ឌា ណេប៉ាល់ ហូឡង់ សឹង្ហបុរី ថៃឡង់ដ៍ ចក្រភពអង់គ្លេស និងសហរដ្ឋអាមេរិក។ កិច្ចស្រាវជ្រាវលម្អិតនេះ ធ្វើឡើងដើម្បីគូសបញ្ជាក់ឲ្យច្បាស់ ថាតើរាល់បញ្ញត្តិរបស់ប្រទេសទាំងអស់នេះបានធានាការពារដោយជោគជ័យចំពោះសិទ្ធិរបស់បណ្តាជនភ.ដ.ព.បដែរឬយ៉ាងណា ហើយក៏ដើម្បីគូសបញ្ជាក់នូវវិសាលភាពបញ្ញត្តិស្រដៀងគ្នាដែលអាចមានផលវិជ្ជមានចំពោះសិទ្ធិនិងជីវភាពរបស់បណ្តាជនភ.ដ.ព.ប នៅកម្ពុជា។ ប្រទេសមួយចំនួនដូចជា ហូឡង់ ថៃឡង់ដ៍ ចក្រភពអង់គ្លេស និងសហរដ្ឋអាមេរិក ត្រូវបានជ្រើសរើសជាគោលដៅសិក្សាដោយសារតែប្រទេសនេះមានជំហរសេរីនិងជឿនលឿនចំពោះបណ្តាជនភ.ដ.ព.បនិងបញ្ហាពាក់ព័ន្ធនាននា។ ប្រទេសផ្សេងទៀតត្រូវបានជ្រើសរើសដោយសារតែប្រទេសទាំងនោះមានបរិបទសង្គមនិងវប្បធម៌ស្រដៀងគ្នា (កម្ពុជាមានលក្ខណៈស្រដៀងគ្នានឹងប្រទេសថៃឡង់ដ៍ ឥណ្ឌា និងណេប៉ាល់) ហើយប្រទេសផ្សេងទៀតក៏ត្រូវបានលើកយកមកសិក្សាដែរ ដោយសារតែកត្តាភូមិសាស្ត្រនិងជាសមាជិកនៃសមាគមន៍អាស៊ានដូចគ្នា រួមមានថៃឡង់ដ៍ និងសឹង្ហបុរី។ ប្រទេស ដូចជា ប្រ៊ុយណេ ភូមា និងម៉ាឡេស៊ី ដែលបរិបទច្បាប់សម្រាប់ការស្រឡាញ់ភេទដូចគ្នាមាន

ភាពតឹងរឹងខ្លាំងនោះ គឺមិនត្រូវបានលើកយកមកសិក្សានោះទេ ពីព្រោះប្រទេសទាំងនេះមិនមានច្បាប់ពាក់ព័ន្ធឬលទ្ធភាពដែលអាចចូលរកមើលព័ត៌មានទាំងនេះមានកម្រិត ដូចជាប្រទេសឡាវ និងវៀតណាម ជាដើម។

សម្រាប់អនុសាសន៍មិនមែនច្បាប់ ដែលសំដៅដាក់ជូនដៃគូរសង្គមស៊ីវិល រួមមានអង្គការមិនមែនរដ្ឋាភិបាលនិងស្ថាប័នដែលធ្វើការលើវិស័យសិទ្ធិមនុស្ស សុខភាព (រាប់បញ្ចូលជំងឺអេដស៍ជាដើម) បញ្ហារបស់បណ្តាជនភ.ជ.ព.ប និងវិស័យអប់រំ ម.ស.ម.កបានត្រួតពិនិត្យឡើងវិញនូវរបកគំហើញដែលខ្លួនបានដកស្រង់ចេញពីការងារតស៊ូមតិរបស់ខ្លួនទាក់ទងនឹងកិច្ចពិគ្រោះយោបល់ជាមួយដៃគូរក្នុងស្រុក ថ្នាក់តំបន់ និងអន្តរជាតិ និងរៀបចំកិច្ចស្រាវជ្រាវផ្ទាល់ដោយខ្លួនឯង។ កិច្ចស្រាវជ្រាវនេះ ត្រូវបានដកស្រង់តាមរយៈសិក្ខាសាលា ដំណើរស្រាវជ្រាវនៅមូលដ្ឋាន និងការឃ្លាំមើលសកម្មភាពបណ្តាញភ.ជ.ព.ប ដែលរាល់សកម្មភាពរបស់ម.ស.ម.កនេះត្រូវបានរៀបចំធ្វើឡើងនៅតាមទីក្រុងនិងខេត្តដែលមានសហគមន៍ភ.ជ.ព.បច្រើនគួរឲ្យកត់សម្គាល់ ដូចជាភ្នំពេញ សៀមរាប បាត់ដំបង និងប៉ោយប៉ែត។ ទិន្នន័យត្រូវបានប្រមូលតាមរយៈកិច្ចសម្ភាសន៍ដែលមានលក្ខណៈពាក់កណ្តាលរៀបចំនិងមិនរៀបចំជាមួយអ្នកចូលរួមចំនួន ៣០០ នាក់ ក្នុងនោះមានបណ្តាជនភ.ជ.ព.ប និងឪពុកម្តាយរបស់ពួកគាត់ សកម្មជនភ.ជ.ព.ប អាជ្ញាធរ និងប៉ូលីសមូលដ្ឋាន ជាដើម។ អំឡុងពេលសិក្ខាសាលាដែលម.ស.ម.កបានរៀបចំឡើង ក្រុមពិភាក្សាត្រូវបានបែងចែក ដើម្បីធ្វើការពិភាក្សាលើសំណួរដូចជា៖ ១.តើអ្នកយល់យ៉ាងដូចម្តេចដែរចំពោះបញ្ហាភ.ជ.ព.ប? ២.តើអ្នកធ្លាប់ទទួលរងការរំលោភបំពានសិទ្ធិមនុស្សយ៉ាងដូចម្តេចខ្លះ ក្នុងនាមអ្នកជាភ.ជ.ព.ប? ៣.តើដៃគូរពាក់ព័ន្ធនានា អាចឆ្លើយតបនឹងបញ្ហាប្រឈមទាំងនេះយ៉ាងដូចម្តេចដែរ?

ម.ស.ម.ក ក៏បានដកស្រង់ព័ត៌មានពាក់ព័ន្ធនឹងបញ្ហាភ.ជ.ព.ប និងគំនិតផ្តួចផ្តើមនានា នៅជុំវិញពិភពលោកតាមរយៈការឃ្លាំមើលជាប្រចាំរបស់ខ្លួន លើបណ្តាញសារព័ត៌មាននិងការបោះពុម្ពផ្សាយនានា ដែលអាចស្វែងរកបានជាសាធារណៈ ទាំងអត្ថបទជាភាសាអង់គ្លេសនិងខ្មែរ ទាំងក្នុងស្រុកនិងក្រៅស្រុក និងទាំងបោះពុម្ពឬតាមប្រព័ន្ធអេឡិចត្រូនិក។ គោលបំណងនៃការដាក់ចេញ នូវអនុសាសន៍មិនមែនច្បាប់នេះឡើង គឺដើម្បីជួយពង្រឹង និងជំរុញនូវចលនាទាមទារសមភាពរបស់បណ្តាជនភ.ជ.ព.ប ក្នុងរូបភាពគំនិតផ្តួចផ្តើមដែលងាយអនុវត្ត ហើយដែលដៃគូរការងារពាក់ព័ន្ធអាចចូលរួមអនុវត្តបាន។

# ៣. បរិបទប្រទេសកម្ពុជា

ដូចបានរៀបរាប់ក្នុងជំពូក«គោលបំណង វិសាលភាព និងវិធីសាស្ត្រ»ខាងលើ របាយការណ៍ឆ្នាំ២០១០ បានពិភាក្សានិងវិភាគទស្សនៈវប្បធម៌ទូទៅរបស់ពលរដ្ឋកម្ពុជាដែលមានចំពោះបណ្តាជនភ.ដ.ព.ប។ ជំពូកនេះមានគោលបំណងផ្តល់នូវទិដ្ឋភាពសង្ខេបអំពីចលនារបស់បណ្តាជនភ.ដ.ព.បដែលកំពុងប្រព្រឹត្តទៅក្នុងប្រទេសកម្ពុជានិងបញ្ហាប្រឈមនានាដែលបណ្តាជនភ.ដ.ព.បកំពុងជួបប្រទះ។ ចាប់តាំងពីរបាយការណ៍ឆ្នាំ២០១០ បានបោះពុម្ពផ្សាយរួចមក ចលនារបស់បណ្តាជនភ.ដ.ព.ប នៅប្រទេសកម្ពុជាហាក់ដូចជាបន្តដុះដាល និងពង្រីកនូវកម្លាំងរបស់ខ្លួន។ អង្គការនិងសកម្មជន បានបន្តចូលរួមសកម្មភាពនានា ដែលព្យាយាមលើកកម្ពស់ការយល់ដឹង ពីនិន្នាការភេទនិងអត្តសញ្ញាណយេនឌ័រ ហើយបានជំរុញឲ្យមានការគោរពដល់សិទ្ធិរបស់បណ្តាជនភ.ដ.ព.ប។ ជាពិសេស យើងសង្កេតឃើញមានវឌ្ឍនភាពគួរឲ្យកត់សម្គាល់ ជុំវិញការបង្កើតបណ្តាញអង្គការនិងបុគ្គលភ.ដ.ព.បនៅតំបន់អាស៊ាន និងមានការកើនឡើងនៃកិច្ចសហការ ទំនាក់ទំនង និងការបែងចែកចំណេះដឹងរវាងគ្នា ដើម្បីធ្វើយ៉ាងណាឲ្យសម្រេចបាននូវការគោរពសិទ្ធិរបស់ភ.ដ.ព.បនៅថ្នាក់តំបន់។

ថ្វីត្បិតមានភាពប្រសើរឡើងក្នុងការបង្កើតចលនាភ.ដ.ព.បក្តី បញ្ហាជាច្រើននៅតែមាន ដែលទាមទារឲ្យយើងធ្វើការដោះស្រាយជាបន្ទាន់ ទាំងតាមរយៈនីតិបញ្ញត្តិនិងវិធានការពីសង្គមស៊ីវិល។ បើទោះបីជាគំនាបមកលើបណ្តាជនភ.ដ.ព.បនៅកម្ពុជាមិនទាន់មានលក្ខណៈធ្ងន់ធ្ងរដូចប្រទេសដទៃមួយចំនួន ដែលការស្រឡាញ់ភេទដូចគ្នាឬការប្រព្រឹត្តសេពភេទដូចគ្នាជាបទល្មើសឬការដែលមានការជំរុញពីប្រពៃណីសាសនាឲ្យមានការស្អប់ខ្ពើមដល់ការស្រឡាញ់ភេទដូចគ្នា យ៉ាងណាក៏ដោយក៏បណ្តាជនភ.ដ.ព.បនៅកម្ពុជា នៅតែរងនូវការរំលោភបំពានសិទ្ធិ ការរើសអើង និងការឃាយី ជាដើម។ ការរំលោភដល់សិទ្ធិភ.ដ.ព.ប កើតឡើងដោយសារកង្វះការយល់ដឹងពីសំណាក់គ្រួសារនិងសហគមន៍ ដែលជាលទ្ធផលបណ្តាលឲ្យមានគំនាបសេដ្ឋកិច្ច ការបំពានពីសំណាក់អាជ្ញាធរមានសមត្ថកិច្ច និងការរើសអើងពីគ្រប់មជ្ឈដ្ឋាន ដែលរួមមានសាលារៀន ប្រព័ន្ធថែទាំសុខភាព និងកន្លែងធ្វើការ។ ថ្វីបើប្រព័ន្ធទិន្នន័យពាក់ព័ន្ធនឹងបញ្ហាទាំងអស់នេះនៅមិនទាន់មានលក្ខណៈគ្រប់គ្រាន់នៅកម្ពុជាក្តី ភស្តុតាងផ្ទាល់និងការពិគ្រោះយោបល់ជាមួយបណ្តាជនភ.ដ.ព.ប ឆ្លុះបញ្ចាំងឲ្យឃើញថាបញ្ហាទាំងអស់នេះគឺជាផលប៉ះពាល់។ របាយការណ៍នេះ នឹងលើកយកចំណុចជាក់លាក់មួយចំនួនដែលសិទ្ធិរបស់បណ្តាជនភ.ដ.ព.បត្រូវបានប្រឈមមកពិភាក្សាជាលម្អិតនៅជំពូកបន្ទាប់។ ឋិតក្នុងបរិបទនេះ យើងឃើញថានៅមានឱកាសជាច្រើនដែលចលនាភ.ដ.ព.ប អាចជំរុញឲ្យមានការកើនឡើងក្នុងសង្គមស៊ីវិលនិងកម្មវិធីនានាដែលធ្វើការជាពិសេសដើម្បីលើកស្ទួយនិងការពារសិទ្ធិរបស់បណ្តាជនភ.ដ.ព.ប។

ទោះជាយ៉ាងនេះក្តី ការប្រឈមរបស់បណ្តាជនភ.ដ.ព.បនៅកម្ពុជា គឺជាលទ្ធផលមិនត្រឹមតែដោយសារកង្វះការយល់ដឹងពីនិន្នាការភេទនិងអត្តសញ្ញាណយេនឌ័រនិងកម្រិតតិចតួចនៃកម្មវិធីនានានោះទេ តែដោយសារតែវិសាលភាពផ្នែកច្បាប់ពាក់ព័ន្ធនឹងសិទ្ធិភ.ដ.ព.ប ផងដែរ។ និយាយជាទូទៅ អវត្តមាននៃបម្រាមច្បាប់ចំពោះទង្វើស្រឡាញ់ភេទដូចគ្នានៅកម្ពុជា អាចផ្តល់កម្រិតការពារដ៏ប្រសើរមួយ ខណៈពេលដែលប្រទេសផ្សេងបានដាក់ទង្វើនោះជាបទឧក្រិដ្ឋ។ ប៉ុន្តែ បើយោងតាមសមាគមអន្តរជាតិស្ត្រីស្រឡាញ់ស្ត្រី បុរសស្រឡាញ់បុរស អ្នកស្រឡាញ់ភេទទាំងពីរ អ្នកប្តូរភេទ និងអន្តរភេទ (ហៅកាត់ថា "អ៊ិលហ្គា") បានថ្លែងក្នុងរបាយការណ៍ចេញផ្សាយកាលពីខែឧសភា ឆ្នាំ២០១២ ជុំវិញការស្អប់ខ្ពើមអ្នកស្រឡាញ់ភេទដូចគ្នា ដែលជំរុញដោយរដ្ឋមាន

សមត្ថកិច្ច ថា *"ការរួមដែលរស់នៅក្នុងប្រទេសមួយដែលការរួមភេទដោយស្មគ្រ័ចិត្តរបស់បុគ្គលពេញវ័យស្រឡាញ់ភេទដូចគ្នា មិនត្រូវបានដាក់ជាបទល្មើសព្រហ្មទណ្ឌ មិនមានន័យថាបុគ្គលដែលជាស្ត្រីស្រឡាញ់ស្ត្រី បុរសស្រឡាញ់បុរស ឬអ្នកប្តូរភេទ មានសុវត្ថិភាពនោះឡើយ ដោយសារថា អំពើហិង្សា ការកាត់ទោស និងការរើសអើងផ្សេងៗ ត្រូវបានប្រព្រឹត្តពីសំណាក់ភ្នាក់ងារមិនមែនរដ្ឋ មិនថាជាការរៀបចំឬមិនរៀបចំ និងករណីខ្លះទៀតត្រូវបានគាំពារពីសំណាក់អាជ្ញាធរមានសមត្ថកិច្ចថែមទៀត"*។[8]

កម្ពុជាបានធ្វើដំណើរយ៉ាងវែងឆ្ងាយរួចមកហើយ ប៉ុន្តែនៅមានផ្លូវវែងឆ្ងាយថែមទៀតដែលត្រូវដើរ។ គោលបំណងនៃរបាយការណ៍នេះ គឺស្នើនូវជំហានដែលអាចអនុវត្តបានដើម្បីឆ្លើយតបទៅនឹងចំណុចដាក់លាក់ទាំងឡាយជុំវិញការរើសអើង ធ្វើយ៉ាងណាជួយដល់កម្ពុជា ក្នុងការធ្វើដំណើរលើផ្លូវដ៏វែងឆ្ងាយនេះ។

[8] អ៊ិលហ្គា "ការស្អប់ខ្ពើមអ្នកស្រឡាញ់ភេទដូចគ្នាដែលជំរុញដោយរដ្ឋមានសមត្ថកិច្ច៖ កាស្ទាបស្ទង់មតិជាសកលមួយជុំវិញបញ្ញត្តិដែលដាក់ការរួមភេទរបស់បុគ្គលពេញវ័យស្រឡាញ់ភេទដូចគ្នា ជាបទឧក្រិដ្ឋ" ចេញផ្សាយនាខែឧសភា ឆ្នាំ២០១២ <http://old.ilga.org/Statehomophobia/ILGA_State_Sponsored_Homophobia_2012.pdf> ។

# ៤. ការផ្ដល់អនុសាសន៍ ខាងទិដ្ឋភាពច្បាប់និងទិដ្ឋភាពមិនមែនច្បាប់

ជំពូកនេះ ចាប់ផ្ដើមដោយការវិភាគទិដ្ឋភាពច្បាប់ទូទៅនៅកម្ពុជា ដោយឆ្លុះបញ្ចាំងលើបញ្ញត្តិមានស្រាប់ដែលធានាដល់សិទ្ធិក.ដ.ព.ប និងផ្ដល់អនុសាសន៍ជាក់លាក់។ បន្ទាប់មក ជំពូកនេះនឹងធ្វើការពិនិត្យលើទិដ្ឋភាពផ្សេងៗគ្នាដែលពាក់ពន្ធ័នឹងជីវភាពរបស់បណ្ដាជនក.ដ.ព.ប រួមមានគ្រួសារ សហគមន៍ សុភាព អប់រំ ជាដើម ហើយនឹងដាក់ចេញជាអនុសាសន៍ជាបទបញ្ញត្តិ ឬមិនមានបញ្ញត្តិជាក់លាក់ ឆ្លើយតបនឹងទិដ្ឋភាពទាំងអស់នេះ។ សម្រាប់ជំពូកមួយនេះ ច្បាប់និងគំនិតផ្ដួចផ្ដើមដែលអាចអនុវត្តបានទាំងឡាយដែលដកស្រង់ចេញពីប្រទេសផ្សេងៗ នឹងត្រូវបានលើកយកមកបង្ហាញសម្រាប់ប្រៀបធៀបនិងតាក់តែងជាអនុសាសន៍ឡើង។

## ៤.១. ការរើសអើងទូទៅប្រឆាំងនឹងបណ្ដាជនក.ដ.ព.ប

ទិដ្ឋភាពច្បាប់របស់ប្រទេសកម្ពុជា ដែលមាននាពេលបច្ចុប្បន្ននេះ ផ្ដល់នូវកិច្ចការពារតិចតួចដល់សិទ្ធិក.ដ.ព.ប ដោយសារតែបញ្ញត្តិទាំងអស់នេះមិនបានដាក់និន្នាភេទនិងអត្តសញ្ញាណយេនឌ័រ ជាបទព្រហ្មទណ្ឌ ហើយក៏មិនមានចែងក្នុងលក្ខខណ្ឌការពារសិទ្ធិនេះដែរ។ ឧទាហរណ៍ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រ កម្ពុជា (ហៅកាត់ថា "រដ្ឋធម្មនុញ្ញ") ដែលកំណត់នូវមូលដ្ឋានប្រព័ន្ធច្បាប់និងបទដ្ឋានសិទ្ធិមនុស្សនៅកម្ពុជា មិនបានបញ្ចូលនិន្នាការភេទនិងអត្តសញ្ញាណយេនឌ័រក្នុងបញ្ញត្តិសមភាពរបស់ខ្លួននោះទេ គ្រាន់តែចែងក្នុងមាត្រា៣១ថា *"ប្រជាពលរដ្ឋខ្មែរ មានភាពស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិ សេរីភាព និងករណីកិច្ចដូចគ្នាដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ។"*

កង្វះភាពជាក់លាក់ក្នុងរដ្ឋធម្មនុញ្ញពាក់ព័ន្ធនឹងនិន្នាការភេទនិងអត្តសញ្ញាណយេនឌ័រគឺជាបញ្ហា ជាពិសេស ខណៈអវត្តមានបញ្ញត្តិជាក់លាក់ជាច្រើន ដូចជាច្បាប់ប្រឆាំងភាពរើសអើង និងប្រឆាំងឧក្រិដ្ឋកម្មដែលបណ្ដាលមកពីភាពស្អប់ខ្ពើម ដែលនេះនឹងបើកឱកាសឲ្យមានការរើសអើងនៅក្នុងវិស័យជាច្រើននៅក្នុងសង្គមកម្ពុជា។ ដោយសារថារដ្ឋធម្មនុញ្ញជាច្បាប់កំពូលនៃប្រទេសនេះ បណ្ដាជនក.ដ.ព.បនឹងអាចទទួលបាននូវកិច្ចគាំពារស្របច្បាប់បន្ថែម ប្រសិនណាមានការធ្វើវិសោធនកម្មលើមាត្រា៣១ ដើម្បីបញ្ចូលនិន្នាការភេទនិងអត្តសញ្ញាណយេនឌ័រជាមូលដ្ឋានក្នុងការហាមប្រាមដល់រាល់ទម្រង់នៃការរើសអើង។

ជាសារៈប្រយោជន៍មួយ ក្នុងការប្រៀបធៀបរដ្ឋធម្មនុញ្ញនេះទៅនឹងរដ្ឋធម្មនុញ្ញរបស់ប្រទេសដទៃ ដូចជាប្រទេសថៃឡង់ដ៍ ដែលមានរដ្ឋធម្មនុញ្ញស្រដៀងគ្នានឹងប្រទេសកម្ពុជាដែរ ដើម្បីស្នើឲ្យមានវិសោធនកម្មសមស្របមួយ។ ផ្នែកទី៣០ នៃរដ្ឋធម្មនុញ្ញរបស់ប្រទេសថៃឡង់ដ៍ បញ្ចូលបញ្ញត្តិមួយហាមប្រាមការរើសអើង ដោយសារ "ស្ថានភាពបុគ្គល" ដែលបញ្ញត្តិនេះហាក់នៅមានលក្ខណៈទូលាយនិងមិនគួរជាទីពេញចិត្តនៅឡើយ។ ទោះបីជាយ៉ាងនេះក្ដី កាលពីឆ្នាំ២០០៧ មានកិច្ចប្រឹងប្រែងមួយក្នុងការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញនៃប្រទេសថៃឡង់ដ៍នេះ ដើម្បីស្នើឲ្យដាក់បញ្ចូលនូវវាក្យស័ព្ទ "ចម្រុះបែបនៃភេទ" ទៅក្នុងលក្ខខណ្ឌហាមប្រាមការរើសអើង។ បើទោះបីជាសំណើនោះមិនបានសម្រេច ដោយសារការបោះឆ្នោតមិនគាំទ្រ ដែលមានសំឡេង ៥៤ ទល់នឹង

២៣ យ៉ាងណាក៏ដោយ ក៏កិច្ចប្រឹងប្រែងនេះបង្ហាញឲ្យឃើញ នូវវឌ្ឍនភាពរបស់ប្រទេសថៃឡង់ដ៍ជុំវិញកិច្ចការបញ្ចូលបទដ្ឋាននិន្នាការភេទនិងអត្តសញ្ញាណយេនឌ័រក្នុងរដ្ឋធម្មនុញ្ញនោះដែរ។[9]

ប្រទេសឯទៀតទទួលបានវិវឌ្ឍនាការប្រសើរជាងនេះទៀត។ ជាឧទាហរណ៍ នៅប្រទេសណេប៉ាល់ ព្រឹត្តការណ៍មួយបានកើតឡើងក្នុងប្រវត្តិសាស្ត្រ កាលពីឆ្នាំ២០០៧ ដោយសារថាតុលាការកំពូលបានសម្រេចប្រឆាំងការរើសអើងដោយសារមូលដ្ឋាននិន្នាការភេទនិងអត្តសញ្ញាណយេនឌ័រ។ នេះអាចមានទំនោរថា រដ្ឋធម្មនុញ្ញរបស់ប្រទេសណេប៉ាល់ដែលត្រូវបានរង់ចាំជាយូរណាស់មកហើយនឹងអាចយកគំរូតាមសេចក្តីសម្រេចរបស់តុលាការនេះ ហើយបញ្ចូលនូវបញ្ញត្តិសិទ្ធិស្មើគ្នារបស់បណ្តាជនក.ដ.ព.ប។[10] សម្រាប់ប្រទេសជិតខាង គឺប្រទេសឥណ្ឌាវិញ ច្បាប់ចក្រភពអង់គ្លេសដែលត្រូវបានតាក់តែងឡើងជាយូរយាណាស់មកហើយ និងដែលបានដាក់ការស្រឡាញ់ភេទដូចគ្នាជាទោសព្រហ្មទណ្ឌដោយចែងជាបទល្មើសផ្ទុយពីធម្មជាតិនោះ ត្រូវបានតុលាការកំពូលរបស់ប្រទេសឥណ្ឌាច្រានចោលកាលពីឆ្នាំ២០០៩។ តុលាការកំពូល បានសម្រេចថា បញ្ញត្តិនោះគឺបានបំពានមាត្រាជាច្រើនរបស់រដ្ឋធម្មនុញ្ញឥណ្ឌាពាក់ព័ន្ធនឹងសិទ្ធិស្មើគ្នាក្នុងការរស់នៅនិងសេរីភាព ការទទួលបានការការពារស្មើគ្នាចំពោះច្បាប់ និងបញ្ញត្តិប្រឆាំងការរើសអើង។[11] អ្វីដែលសំខាន់ គឺថា រដ្ឋាភិបាលឥណ្ឌាបានសម្រេចមិនប្តឹងតបនឹងករណីនេះ ដែលនេះបង្ហាញនូវការទទួលស្គាល់ប្រកបដោយអត្ថន័យស្វាគមន៍ចំពោះកិច្ចគាំពារសិទ្ធិស្មើគ្នារបស់បណ្តាជនក.ដ.ព.ប ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញឥណ្ឌា។

អ្វីដែលគួរឲ្យខកចិត្តនោះគឺថា លិខិតូបករណ៍អន្តរជាតិទាំងឡាយ មានដូចជាកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ហៅកាត់ថា "ក.អ.ស.ព.ន") និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ហៅកាត់ថា ក.អ.ស.ស.វ) បានខកខានក្នុងការចែងឲ្យបានជាក់លាក់នូវវាក្យស័ព្ទនិន្នាការភេទនិងអត្តសញ្ញាណយេនឌ័រជាមូលដ្ឋានហាមប្រាមដល់ការរើសអើង។ ប៉ុន្តែ លិខិតូបករណ៍ទាំងនេះបានរាប់បញ្ចូលនូវពាក្យថា "ស្ថានភាពដទៃទៀត" ជាប្រភេទមូលដ្ឋានបម្រាមក្នុងការរើសអើងផងដែរ ហើយស្ថាប័នសន្ធិសញ្ញារបស់អង្គការសហប្រជាជាតិបានអះអាងម្តងហើយម្តងទៀតថា "ស្ថានភាពដទៃទៀត" ក្នុងន័យនេះ គឺសំដៅដល់និន្នាការភេទនិងអត្តសញ្ញាណយេនឌ័រ។ ជាឧទាហរណ៍ ក្នុងសេចក្តីអធិប្បាយទូទៅលេខ២០ គណៈកម្មាធិការអង្គការសហប្រជាជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ បានប្រកាន់ភ្ជាប់ថា"ស្ថានភាពដទៃទៀត" ដែលមានចែងក្នុងក.អ.ស.ស.ស.វ នោះ គឺរាប់បញ្ចូល "និន្នាការភេទ" ហើយថា *"រដ្ឋភាគីជាហត្ថលេខីត្រូវធានាថា និន្នាការភេទរបស់បុគ្គល នឹងមិនក្លាយជាឧបសគ្គ ក្នុងការទទួលបានសិទ្ធិនានាដែលមានចែងក្នុងកតិកាសញ្ញានេះជាដាច់ខាត" ហើយ "អត្តសញ្ញាណយេនឌ័រ គឺត្រូវតែបានទទួលស្គាល់ជាមូលដ្ឋានមួយក្នុង*

---

[9] ចេសុន អាមប្រឹដ "ការផ្លាស់ប្តូរភេទ និងច្បាប់របស់ប្រទេសថៃឡង់ដ៍" (វេទិកាច្បាប់ប្រទេសថៃឡង់ដ៍ នាថ្ងៃទី១១ ខែមេសា ឆ្នាំ២០០៨។<http://www.thailawforum.com/Transsexuals-and-Thai-Law.html>។

[10] ក្រាមេ រីដ "សមយុទ្ធទាមទារសិទ្ធិក.ដ.ព.បជាសកល" (គ្លូបិល ប៉ុស្ដិ៍ ចេញផ្សាយនាថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១១) http://www.globalpost.com/dispatch/news/culture-lifestyle/111101/opinion-the-globalization-lgbt-rights-fight>។

[11] "មូលដ្ឋានណាស់ និងរដ្ឋាភិបាល" ឆ្នាំ២០១០ CriLJ ៩៩. ១៦០ (២០០៩) DLT ២៧៧ (ប្រទេសឥណ្ឌា) <www.nazindia.org/advocacy.htm>។

*មូលដ្ឋានបម្រាមនានាដល់ការរើសអើង*។[12] ការអះអាងស្រដៀងគ្នានេះ ក៏ត្រូវបានលើកឡើងផងដែរ ពីសំណាក់ស្ថាប័នសន្ធិសញ្ញានានា ដែលតាមដានឃ្លាំមើលក.អ.ស.ព.ន កតិកាសញ្ញាប្រឆាំងនឹងទារុណកម្ម កតិកាសញ្ញាស្តីពីសិទ្ធិកុមារ និងកតិកាសញ្ញាស្តីពីការលុបបំបាត់ការរើសអើងលើស្ត្រី។[13]

លិខិតូបករណ៍ទាំងអស់នេះ គឺពាក់ព័ន្ធយ៉ាងសំខាន់សម្រាប់កម្ពុជា ដោយសារថា មាត្រា៣១ នៃរដ្ឋធម្មនុញ្ញ បានចែងថា *"ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្សដូចមានចែងក្នុងធម្មនុញ្ញនៃ អង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ"*។ កតិកាសញ្ញានិងអនុសញ្ញាទាំងអស់នេះត្រូវបានដាក់បញ្ចូលទៅក្នុងច្បាប់ជាតិដែលកម្ពុជាបានធ្វើសច្ចានុម័តក្នុងឆ្នាំ១៩៩២ ដែលការដាក់បញ្ចូលនេះត្រូវបានអះអាងតាមរយៈសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧ ដែលចែងថា "កតិកាសញ្ញាអន្តរជាតិទាំងឡាយត្រូវបានកម្ពុជាទទួលស្គាល់" ជាផ្នែកមួយនៃច្បាប់ជាតិ។[14] ផលប្រយោជន៍របស់បណ្តាជនភ.ដ.ព.ប នឹងត្រូវបានលើកស្ទួយយ៉ាងខ្លាំងប្រសិនបើក.អ.ស.ព.ន និងក.អ.ស.ស.ស.វ ត្រូវបានធ្វើវិសោធនកម្មដើម្បីទទួលស្គាល់និន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ ជាមូលដ្ឋានបម្រាមដល់ការរើសអើង ហើយតួអង្គពាក់ព័ន្ធនានា គួរបន្តដាក់សម្ពាធនៅកម្រិតអន្តរជាតិដល់ការទាមទារឲ្យមានវិសោធនកម្មកើតឡើង។

បន្ថែមលើសនេះទៀត ច្បាប់ជាតិនានាដែលផ្តោតជាពិសេសលើការរើសអើងដោយសារការស្រឡាញ់ភេទដូចគ្នា គួរត្រូវបានអនុម័តនៅកម្ពុជា ដែលនេះជាបច្ច័យដល់ការទទួលស្គាល់ នូវការរើសអើងដោយមូលហេតុនិន្នាការភេទនិងអត្តសញ្ញាណយេនឌ័រ។ ក្នុងរបាយការណ៍របស់អង្គការសហប្រជាជាតិ លោកស្រីណាវី ភីឡៃ បានរាយការណ៍ថា *"អវត្តមានច្បាប់ជាតិដែលត្រូវអនុវត្តដើម្បីការពារបណ្តាជនភ.ដ.ព.ប ជួយសម្រួលដល់ការរើសអើងពីសំណាក់តួអង្គឯកជនដទៃទៀត"*។[15] របាយការណ៍របស់អង្គការសហប្រជាជាតិបានអធិប្បាយបន្ថែមទៀតថា មាត្រា២១(១) នៃក.អ.ស.ស.ស.វ ដែលកម្ពុជាបានធ្វើសច្ចានុម័តកាលពីឆ្នាំ១៩៩២ ចែងថា "រដ្ឋភាគីនៃកតិកាសញ្ញានេះទទួលស្គាល់សិទ្ធិរបស់បុគ្គលគ្រប់រូបមានកម្រិតសុខភាព ទាំងខាងរាងកាយ និងខាងស្មារតីខ្ពស់បំផុត តាមដែលអាចធ្វើទៅបាន"។[16] នៅកម្ពុជា កង្វះបញ្ញត្តិដែលមានលក្ខណៈគ្រប់គ្រាន់ ត្រឹមត្រូវ និងជាក់លាក់ ប៉ះពាល់ដល់បណ្តាជនភ.ដ.ព.ប ក្នុងការអាចទទួលបានកម្រិតជីវភាពមួយដ៏ត្រឹមត្រូវ។

---

[12] គណៈកម្មការអង្គការសហប្រជាជាតិស្តីពីស.ស.ស.វ "សេចក្តីអធិប្បាយលេខ២៧ ចែងក្នុងសេចក្តីអធិប្បាយទូទៅលេខ ២០ ស្តីពី "ការមិនរើសអើងចំពោះសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌" (មាត្រា២ ឃ្លាទី២ នៃក.អ.ស.ស.ស.វ" (ចេញផ្សាយថ្ងៃទី ០២ ខែកក្កដា ឆ្នាំ២០០៩) ឯកសាររបស់អង្គការសហប្រជាជាតិ /C.12/GC/20 <http://www2.ohchr.org/english/bodies/cescr/comments.htm>។

[13] អាលី ជៀណូ, "និន្នាការភេទនិងអត្តសញ្ញាណយេនឌ័រ ក្នុងបរិបទច្បាប់សិទ្ធិមនុស្សអន្តរជាតិ" (IntLawGrrls, ៩ មីនា ២០១២) <www.intlawgrrls.com/2012/03/sogi-in-international-human-rights-law.html>។

[14] ក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា សេចក្តីសម្រេចចុះលេខ០៩២/០០៣/២០០៧ (ថ្ងៃទី១០ ខែកក្កដា ឆ្នាំ ២០០៧)។

[15] ណាវី ភីឡៃ "របាយការណ៍របស់អង្គការសហប្រជាជាតិ" (ចេញផ្សាយនៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១១) ទំព័រទី១៦។

[16] ដូចខាងលើ ទំព័រទី១៧។

កាលពីឆ្នាំ២០១១ ម.ស.ម.ក បានរៀបចំសិក្ខាសាលាស្តីពីសិទ្ធិក.ដ.ព.បជាច្រើន នៅតាមបណ្តាខេត្ត សៀមរាប បាត់ដំបង និងភ្នំពេញ។ សិក្ខាកាមបានលើកពីកង្វល់របស់ពួកគាត់ជុំវិញកង្វះកិច្ចការពារសិទ្ធិដល់បណ្តាជនក.ដ.ព.ប ហើយក៏បានសង្កត់ធ្ងន់ពីភាពចាំបាច់ដែលរដ្ឋសភាគួរអនុម័តច្បាប់ដែលអាចការពារ និងលើកស្ទួយសិទ្ធិ របស់ក.ដ.ព.ប។ នៅប៉ុន្មានឆ្នាំចុងក្រោយនេះ តម្រូវការឲ្យមានច្បាប់ដែលអាចឆ្លើយតបនឹងការរើសអើងគឺកាន់តែចាំបាច់ខ្លាំងឡើង ដោយសារថាមិនត្រឹមតែការរើសអើងចំពោះបណ្តាជនក.ដ.ព.ប ពីសំណាក់និយោជក និងអ្នកផ្តល់សេវាថែទាំសុខភាព (សូមមើលព័ត៌មានលម្អិតនៅជំពូកបន្ទាប់) នៅបន្តនោះទេ តែថែមទាំងមានរបត់មួយដែលបញ្ញត្តិមានស្រាប់ ត្រូវបានបំពានដើម្បីជាសម្អាង ដល់ការរើសអើងប្រឆាំងលើបណ្តាជនក.ដ.ព.ប។ បើយោងតាមបណ្តាញក្រុមក.ដ.ព.ប នៅតាមបណ្តាខេត្តមួយចំនួន បញ្ញត្តិជាក់លាក់ខ្លះ ដូចជា នៅក្នុងច្បាប់គ្រប់គ្រងគ្រឿងញៀនឆ្នាំ២០០៥ អនុញ្ញាតិឲ្យមន្ត្រីមានសមត្ថកិច្ចអាចមានឆន្ទានុសិទ្ធិមួយចំនួនធំ ក្នុងការអនុវត្តន៍ច្បាប់របស់ខ្លួន ដែលនេះបានបណ្តាលឲ្យឈានដល់ការកេងប្រវ័ញ្ចលើច្បាប់ ហើយបង្កឲ្យមានការរើសអើងដល់ក្រុមជាក់លាក់មួយចំនួន ដូចជាបណ្តាជនក.ដ.ព.ប ជាដើម។ ច្បាប់ជាក់លាក់ដែលហាមប្រាមដល់ការរើសអើងឈរលើមូលដ្ឋាននិន្នាការភេទនិងអត្តសញ្ញាណយេនឌ័រ ដែលត្រូវបានអនុម័តនៅប្រទេសដទៃនោះ បានសរឲ្យឃើញថាមានប្រសិទ្ធិភាពក្នុងការកាត់បន្ថយការរើសអើង និងបានជំរុញឲ្យមានសន្តិភាពខាងផ្លូវចិត្តដល់បណ្តាជនក.ដ.ព.ប។ គ្មានហេតុផលណា ឬការពន្យល់ណាមួយអាចបង្ហាញថាច្បាប់ស្រដៀងគ្នានេះមិនអាចមានប្រសិទ្ធិភាពសម្រាប់កម្ពុជាដែរនោះទេ ប៉ុន្តែក្នុងលក្ខខណ្ឌមួយដែលតុលាការកម្ពុជាត្រូវតែអនុវត្តតាមនិតិវិធីច្បាប់ត្រឹមត្រូវផងដែរ។

បិតក្នុងការពិចារណាដល់ការអនុម័តច្បាប់ប្រឆាំងការរើសអើង ពិតជាមានប្រយោជន៍ ប្រសិនបើយើងធ្វើការពិនិត្យមើលច្បាប់ដែលមានកម្រិតជឿនលឿន គួយ៉ាងដូចការច្បាប់ដែលកំពុងអនុវត្តនៅចក្រភពអង់គ្លេស ហូឡង់ និងសហរដ្ឋអាមេរិកជាដើម។ ច្បាប់ស្តីពីការមិនរើសអើងដោយសារនិន្នាការភេទនៅទីក្រុងញូយ៉ក (ហៅកាត់ថា "ស៊ុនដា") កាលពីឆ្នាំ២០០៣ បានបង្កើនកម្រិតការពារសិទ្ធិរបស់បណ្តាជនក.ដ.ព.ប តាមរយៈការធ្វើវិសោធនកម្មច្បាប់សិទ្ធិមនុស្សរដ្ឋញូយ៉ក។[17] ច្បាប់ស៊ុនដា ហាមប្រាមដល់ការរើសអើងចំពោះនិន្នាការភេទដោយរាប់បញ្ចូលគ្រប់បរិបទរួមមាន ការងារ ទីតាំងស្នាក់អាស្រ័យជាសាធារណៈ ទីកម្សាន្តឬសួនកម្សាន្ត ស្ថាប័នអប់រំ ផ្ទះសម្រាប់ជួយដល់សាធារណជន ទីតាំងស្នាក់អាស្រ័យឯកជន និងទីលំហពាណិជ្ជកម្ម និងការងារពាក់ព័ន្ធនឹងកម្ចីជាដើម។[18] ច្បាប់ស៊ុនដា ផ្តល់នូវកិច្ចគាំពារស៊ីជម្រៅ និងកិច្ចប្រឹងប្រែងដល់ការលុបបំបាត់ការរើសអើងចំពោះបណ្តាជនក.ដ.ព.ប នៅគ្រប់ទិដ្ឋភាពសង្គមទាំងអស់។

នៅប្រទេសហូឡង់វិញ ច្បាប់ប្រព្រឹត្តកម្មស្មើភាពគ្នា (ហៅកាត់ថា "អ៊ីតា") ត្រូវបានអនុម័តនៅក្នុងឆ្នាំ១៩៩៤។ ច្បាប់អ៊ីតា បានពង្រីកវិសាលភាពគោលការណ៍ប្រឆាំងនឹងការរើសអើង លើសពីអ្វីដែលបានចែងក្នុងរដ្ឋធម្មនុញ្ញរបស់ហូឡង់។ ក្នុងចំណោមបញ្ញត្តិនានាជាច្រើន មាត្រា១១ និង១២ ចែងអំពីកការបង្កើតនូវ "គណៈកម្មាធិការប្រព្រឹត្តកម្មស្មើភាពគ្នា" ដែលបញ្ចូលសមាសភាពទីប្រឹក្សាឯករាជ្យ និងដោះស្រាយជម្លោះដែលកើតមានដោយសារការរើសអើង។ ស្ថាប័ននេះ មានអំណាចក្នុងការស៊ើបអង្កេត ចំពោះការចោទប្រកាន់ទាំងឡាយ

[17] ច្បាប់សិទ្ធិមនុស្សរដ្ឋញូយ៉ក (ច្បាប់និតិប្រតិបត្តិរដ្ឋញូយ៉ក មាត្រា១៥ (២៩០-៣០១) សហរដ្ឋអាមេរិក។

[18] ច្បាប់ស្តីពីការមិនរើសអើងដោយសារនិន្នាការភេទរដ្ឋញូយ៉ក ឆ្នាំ២០០៣ (សហរដ្ឋអាមេរិក)។

ពាក់ព័ន្ធនឹងការរើសអើង។[19] ពលរដ្ឋកម្ពុជាទាំងអស់គ្នា នឹងទទួលបានផលប្រយោជន៍ពីការបង្កើតស្រដៀងគ្នានូវ "គណៈកម្មាធិការប្រព្រឹត្តកម្មស្មើភាពគ្នា" ដែលអាចជានាសិទ្ធិមនុស្សសម្រាប់មនុស្សគ្រប់គ្នា មិនថាពួកគាត់ជាអ្នកណាឡើយ។ យន្តការដែលមានភ្ជាប់ជាមួយនឹងច្បាប់បែបនេះ ផ្តល់នូវលទ្ធភាពគ្រប់គ្រាន់និងប្រកបដោយសក្តានុពលដល់ការទាមទារសំណង ដែលនេះជាអ្វីដែលពលរដ្ឋ និងសហគមន៍ខ្មែរកន្លងមកតែងត្រូវបានដកហូតនូវលទ្ធភាពនេះ ដោយសារតែកង្វះនូវតុលាការឯករាជ្យមួយ។[20]

នៅចក្រភពអង់គ្លេស ច្បាប់ស្មើភាពឆ្នាំ២០១០បានចែងថា គោលបំណងនៃការតាក់តែងច្បាប់នេះឡើងគឺដើម្បីសម្រេចបាននូវ "សុខដុមនីយកម្ម សាមញ្ញភាវូបនីយកម្ម និងទំនើបកម្មនៃច្បាប់សមធម៌"។[21] ច្បាប់សមធម៌នេះគ្របដណ្តប់ចរិតលក្ខណៈគាំពារចំនួន ៩ រួមមាន៖ (១)អាយុ, (២)ពិការភាព, (៣)ការផ្លាស់ប្តូរយេនឌ័រ, (៤) អាពាហ៍ពិពាហ៍និងដៃគូរជីវិត, (៥)ការមានគភ៌និងមាតុភាព, (៦)ជាតិសាសន៍, (៧)សាសនាឬជំនឿ, (៨)ភេទ, និង(៩)និន្នាការភេទ។[22] ច្បាប់នេះកំណត់ភាពមិនស្របច្បាប់ក្នុងការប្រព្រឹត្តចំពោះនរណាម្នាក់ ដែលរាប់បញ្ចូលទាំង "ការរើសអើង យាយី និងធ្វើឲ្យអ្នកដទៃរងគ្រោះ ដោយផ្ទាល់និងប្រយោល"។[23] គណៈកម្មការសមធម៌ និងសិទ្ធិមនុស្សរបស់ចក្រភពអង់គ្លេសត្រូវបានផ្តល់អំណាចក្នុងការអនុវត្តច្បាប់សមធម៌ និងផ្តល់ជាព័ត៌មាន និងប្រឹក្សាយោបល់តាមរយៈបណ្តាញទូរស័ព្ទជំនួយ គេហទំព័រ និងការបោះពុម្ពផ្សាយ។ គណៈកម្មការនេះ ក៏ជួយតាក់តែងនូវគោលនយោបាយនានា និងជំរុញឲ្យមានបញ្ញត្តិដែលអាចធ្វើឲ្យភាពស្មើភាពគ្នាកាន់តែប្រសើរឡើងថែមទៀត។[24]

ខណៈដែលនីតិកម្មស្តីពីការប្រឆាំងនឹងការរើសអើងកំពុងត្រូវបានធ្វើការពិភាក្សា ជំហានជាក់លាក់មួយសម្រាប់គោលបំណងវែងឆ្ងាយនោះគឺថា រដ្ឋាភិបាលកម្ពុជាគួរតែដាក់ចេញនូវផែនការយុទ្ធសាស្ត្រលម្អិតស្តីពីនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ ដើម្បីផ្តល់ជាគំនិតយោបល់ និងគោលការណ៍ច្បាស់លាស់មួយសម្រាប់នាយកដ្ឋាននានារបស់ខ្លួន។ ស្រដៀងគ្នានឹងផែនការយុទ្ធសាស្ត្ររយៈពេល៥ឆ្នាំរបស់រាជរដ្ឋាភិបាលកម្ពុជាពាក់ព័ន្ធនឹងស្ត្រី និងការបញ្ជ្រៀបយេនឌ័រ[25] ទីស្តីការគណៈរដ្ឋមន្ត្រីគួរតាក់តែងនូវយុទ្ធសាស្ត្រជាក់លាក់ស្តីពីនិន្នាការ

---

[19] ចេននី អ័រ ឌីយេ និងភីដទី អ័រ រូទ្រីដ "ច្បាប់ស្តីពីប្រព្រឹត្តកម្មស្មើភាពគ្នារបស់ហូឡង់ តាមទ្រឹស្តី និងការអនុវត្តជាក់ស្តែង" (មជ្ឈមណ្ឌលសិទ្ធិរ៉ូម៉ាសហគមន៍អ៊ឺរ៉ុប ចេញផ្សាយថ្ងៃទី១០ ខែឧសភា ឆ្នាំ២០០៣) www.errc.org/article/the-dutch-equal-treatment-act-in-theory-and-practice/1400>។

[20] មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា "កម្រងសលកប័ត្រស្ថាប័ន៖ ការបែងចែកអំណាច និងនិតិរដ្ឋ" (សលកប័ត្រឆ្នាំ២០១១) <www.cchrcambodia.org/index_old.php?url=media/media.php&p=factsheet_detail.php&fsid=3&id=5>។

[21] ច្បាប់ស្មើភាពគ្នា ឆ្នាំ២០១០ (ចក្រភពអង់គ្លេស) <www.homeoffice.gov.uk/equalities/equality-act/>។

[22] ដូចខាងលើ។

[23] ដូចខាងលើ។

[24] គណៈកម្មាការសិទ្ធិមនុស្សនិងសមភាព, "យើងគឺជាយើង និងអ្វីដែលយើងត្រូវធ្វើ" <www.equalityhumanrights.com/uploaded_files/who_we_are.pdf>។

[25] ក្រសួងកិច្ចការនារី, "នារីរតនៈ III" (២០០៩)។

ភេទ និងអត្តសញ្ញាណយេនឌ័រមួយ ហើយបញ្ចូលនូវមគ្គុទេសក៍ស្តីពីរបៀបបញ្ចូលនិន្នាការភេទ ទៅក្នុងអនុយុទ្ធសាស្ត្រឯទៀត។ ឧទាហរណ៍ដ៏ល្អមួយ គឺគោលការណ៍ក.ដ.ព.ប ឆ្នាំ២០០៨-២០១១ របស់ប្រទេសហូឡង់ ដែលមានចំណងជើងថា *"គ្រាន់តែជាអ្នកស្រឡាញ់ភេទដូចគ្នា"* ដែលដាក់ចេញនូវមគ្គុទេសក៍យុទ្ធសាស្ត្រទូទៅសម្រាប់ក្រសួងទាំងឡាយរបស់រដ្ឋាភិបាលហូឡង់ ដើម្បីធ្វើយ៉ាងណាអាចសម្រេចបាននូវគោលបំណងរួមរបស់គោលការណ៍នោះ គឺថា៖ "លើកស្ទួយការទទួលស្គាល់របស់សង្គមចំពោះបណ្តាជនក.ដ.ព.ប ក្នុងចំណោមប្រជាពលរដ្ឋហូឡង់ទាំងអស់"។[26]

អនុសាសន៍សម្រាប់រដ្ឋាភិបាល/រដ្ឋសភា៖ ធ្វើវិសោធនកម្មទៅលើបញ្ញត្តិដែលមានវាក្យស័ព្ទ "ស្ថានភាពដទៃទៀត" ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ ដើម្បីបញ្ចូលនូវវាក្យស័ព្ទយោងជាក់លាក់មួយសម្រាប់ជាមូលដ្ឋានក្នុងការហាមប្រាមការរើសអើងនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ ។

អនុសាសន៍សម្រាប់រដ្ឋាភិបាល/រដ្ឋសភា៖ ធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញដើម្បីបញ្ចូលនូវបញ្ញត្តិដែលអាចការពារ និងលើកស្ទួយជាពិសេសដល់សិទ្ធិក.ដ.ព.ប។

អនុសាសន៍ដល់រដ្ឋាភិបាល/រដ្ឋសភា៖ បង្កើតឲ្យមានច្បាប់ប្រឆាំងនឹងការរើសអើង ដោយផ្តោតជាពិសេសទៅលើការរើសអើងក.ដ.ព.ប ក្នុងគោលបំណងលើកស្ទួយ និងការពារសិទ្ធិមនុស្សរបស់បណ្តាជនក.ដ.ព.ប ដោយមិនប្រកាន់និន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ។

អនុសាសន៍ដល់រដ្ឋាភិបាល៖ បង្កើតស្ថាប័នមួយ តួយ៉ាងដូចជាគណៈកម្មាធិការប្រឆាំងនឹងការរើសអើង ដែលអណត្តិរបស់គណៈកម្មាធិការនេះគឺការពារសិទ្ធិមនុស្សទាំងអស់គ្នាដោយមិនប្រកាន់ថាអ្នកណាជាអ្នកណាឡើយ។

អនុសាសន៍ដល់រដ្ឋាភិបាល៖ តាក់តែងនូវយុទ្ធសាស្ត្រជាតិលម្អិតមួយស្តីពីនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ ដើម្បីផ្តល់ជាគំនិតយោបល់ និងគោលការណ៍ច្បាស់លាស់មួយដល់គ្រប់នាយកដ្ឋាន និងស្ថាប័នរដ្ឋបាលរបស់រដ្ឋាភិបាលទាំងអស់។

---

[26] សូមមើល www.dayagainsthomophobia.org/IMG/pdf/Simply_Gay_engelstalige_versie_Hnota.pdf។

## ៤.២. អាស៊ាន

សិក្ខាសាលារបស់វេទិកាអ្នកស្រឡាញ់ភេទដូចគ្នា ស្រឡាញ់ទាំងពីរភេទ អ្នកប្តូរភេទ អន្តរភេទ និងភេទមិនច្បាស់ នៃអាស៊ាន (ហៅកាត់ថា "វេទិកាភ.ដ.ព.ប.អ.ម.អ") ដែលបានរៀបចំធ្វើឡើងនៅទីក្រុងភ្នំពេញ កាលពីថ្ងៃទី២៩ និង៣០ ខែមេសា ឆ្នាំ២០១២ និងម្តងទៀតនៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១២ ស្របពេលនឹងកិច្ចប្រជុំកំពូលរបស់អាស៊ាន ជាឱកាសមួយមិនត្រឹមតែចូលរួមអបអរដល់ភាពចម្រុះបែប តែថែមទាមរំឭកដល់រដ្ឋាភិបាល និងសមាជិកសង្គមស៊ីវិលទាំងឡាយនៅតំបន់នេះឲ្យទទួលស្គាល់ លើកស្ទួយ និងការពារដល់សិទ្ធិបណ្តាជនភ.ដ.ព.ប។ ក្នុងចំណោមបណ្តាប្រទេសអាស៊ាន សិទ្ធិមនុស្ស ដូចជាសិទ្ធិទទួលបានការថែទាំសុខភាព សិទ្ធិលំនៅដ្ឋាននិងអប់រំ ដោយមិនទាន់រាប់បញ្ចូលនូវសិទ្ធិមូលដ្ឋាន សេរីភាពក្នុងការបញ្ចេញមតិ និងប្រមូលផ្តុំផងនោះ សិទ្ធិទាំងអស់នេះជាញឹកញយត្រូវបានគេបដិសេធចំពោះបណ្តាជនភ.ដ.ព.ប។ ប្រទេសប្រ៊ុយណេ ភូមា ម៉ាឡេស៊ី និងសឹង្ហបុរី ក៏ដូចជាទីក្រុងម៉ារ៉ាវី នៃប្រទេសហ្វីលីពីន និងខេត្តសូមាត្រាខាងត្បូងនៃប្រទេសឥណ្ឌូនេស៊ី នៅតែរក្សាច្បាប់នាសម័យអណានិគម នៅក្នុងអត្ថបទច្បាប់របស់ខ្លួន ដែលច្បាប់ទាំងនោះបានដាក់ការស្រឡាញ់ភេទដូចគ្នាជាបទឧក្រិដ្ឋ។ ស្ទើរតែគ្រប់ប្រទេសទាំងអស់នៃតំបន់អាស៊ាន បានប្រើប្រាស់បញ្ញត្តិដែលមិនពាក់ព័ន្ធទាល់តែសោះមកជាសម្អាងក្នុងការឃាឃី ចាប់ខ្លួន ឃុំខ្លួន កាត់ទោស និងគំរាមកំហែងយកលុយ ឬក៏ទាមទារឲ្យបណ្តាជនភ.ដ.ព.ប បំពេញចំណង់ផ្លូវភេទដល់ខ្លួន។

កិច្ចពិភាក្សាជាច្រើនក្នុងសិក្ខាសាលារបស់វេទិកាភ.ដ.ព.ប.អ.ម.អ បានផ្តោតលើសេចក្តីប្រកាសស្តីពីសិទ្ធិមនុស្សអាស៊ាន (ហៅកាត់ថា "ស.ប.ស.អ")។ គោលបំណងសំខាន់នៃស.ប.ស.អ គឺដាក់ក្រមសិទ្ធិមនុស្សសម្រាប់តំបន់អាស៊ាន និងផ្តល់ជាបទដ្ឋានទូទៅមួយសម្រាប់បណ្តាប្រទេសអាស៊ានទាំងអស់។ ទោះជាយ៉ាងនេះក្តី ឯកសារសេចក្តីប្រកាសចុងក្រោយបំផុត ដែលបណ្តាប្រទេសអាស៊ានទាំងអស់បានចុះហត្ថលេខាកាលពីថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១២ នៅឯសន្និសីទកំពូលអាស៊ាននៅទីក្រុងភ្នំពេញនោះ គ្មានបញ្ញត្តិណាមួយបានចែងជាក់លាក់ចំពោះកិច្ចគាំពារដល់បណ្តាជនភ.ដ.ព.ប ហើយក៏គ្មានបញ្ញត្តិណាមួយបានចែងអំពីនិន្នាការភេទនិងអត្តសញ្ញាណយេនឌ័រជាមូលដ្ឋានក្នុងការហាមប្រាមការរើសអើងនោះដែរ។ ឯកសារសេចក្តីប្រកាសចុងក្រោយនេះត្រូវបានអនុម័តឡើង ថ្វីបើមានការតស៊ូមតិយ៉ាងខ្លាំងក្លាក្តីពីសំណាក់ប្រទេសថៃឡង់ដ៍ ហ្វីលីពីន និងឥណ្ឌូនេស៊ី ទាមទារឲ្យបញ្ចូលនិន្នាការភេទនិងអត្តសញ្ញាណយេនឌ័រទៅក្នុងបញ្ញត្តិដែលនិយាយពីការមិនរើសអើង។ ក្នុងអំឡុងដំណើរការព្រាងសេចក្តីប្រកាសនេះ ក្រុមសង្គមស៊ីវិលអាស៊ានបានសម្តែងនូវកង្វល់ពាក់ព័ន្ធនឹងទិដ្ឋភាពនៃស.ប.ស.អ បើទោះបីជាពួកគាត់ត្រូវបានផាត់ចេញពីដំណើរការពិគ្រោះយោបល់យ៉ាងក៏ដោយ។ សេចក្តីថ្លែងការណ៍រួមមួយ[27] សម្តែងពីការខកចិត្តចំពោះការដកចេញនូវនិន្នាការភេទនិងអត្តសញ្ញាណយេនឌ័រពីសេចក្តីព្រាងនៃស.ប.ស.អ ត្រូវបានចេញផ្សាយកាលពីថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១២ ដោយមានអង្គការជាហត្ថលេខីចំនួន១៤ ដែលបន្ទាប់មកមានអង្គការចំនួន១២ បន្ថែមទៀតបានចូលរួមគាំទ្រលើសេចក្តីថ្លែងការណ៍នោះ ហើយដែលជាផ្លូវការគាំទ្រដោយគណៈកម្មការអន្តរជាតិស្តីពីសិទ្ធិបុរសស្រឡាញ់បុរស និងស្ត្រីស្រឡាញ់ស្ត្រី និង

---

[27] សេចក្តីថ្លែងការណ៍របស់វេទិកាភ.ដ.ព.ប.អ.ម.អ "ដាក់បញ្ចូលនិន្នាការភេទ និងសិទ្ធិទៅក្នុងវេទិកាសង្គមស៊ីវិល និងវេទិកាពលរដ្ឋអាស៊ាន និងក្នុងសេចក្តីប្រកាសសិទ្ធិមនុស្សអាស៊ាន" (ឆ្នាំ២០១២) <www.boell-southeastasia.org/downloads/PRESS_RELEASE_-LGBTQI.pdf>។

ដោយអង្គការអ៊ិលហ្គា។ បន្ទាប់ពីស.ប.ស.អត្រូវបានអនុម័តរួច សេចក្តីថ្លែងការណ៍រួម[28]មួយផ្សេងទៀត ត្រូវបានចេញផ្សាយ ដោយវេទិកាភ.ជ.ព.ប.អ.ម.អ ដែលមានខ្លឹមសារថា ៖

*"យើងជាសមាជិកនៃវេទិកាភ.ជ.ព.ប.អ.ម.អ មានការខឹងសម្បារ និងខកចិត្តយ៉ាងខ្លាំងចំពោះសេចក្តីសម្រេចចិត្តរបស់ថ្នាក់ដឹកនាំអាស៊ាន ក្នុងការអនុម័តស.ប.ស.អ ក្នុងចេតនាលុបចេញនូវនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ [...]។ ស.ប.ស.អដែលបាននអនុម័តនេះមិនត្រឹមបង្ហាញឲ្យឃើញនូវកង្វះការគោរពសិទ្ធិរបស់បណ្តាជនភ.ជ.ព.ប.អ.មប៉ុណ្ណោះទេ តែថែមទាំងជាការចំអកដល់គុណតម្លៃ និងគោលការណ៍សិទ្ធិមនុស្សអន្តរជាតិ ដែលរដ្ឋ និងពលរដ្ឋទាំងអស់ត្រូវគោរពតាម និងត្រូវប្រកាន់យកជាទំនួលខុសត្រូវមួយ"។*[29]

ម.ស.ម.ក បានសម្តែងនូវការខកចិត្តស្រដៀងគ្នាចំពោះស.ប.ស.អ តាមរយៈការចេញនូវសេចក្តីថ្លែងការណ៍មួយដែលគូសបញ្ជាក់ពីកង្វល់របស់ម.ស.ម.កចំពោះស.ប.ស.អ ដោយរាប់បញ្ចូលទាំងការដកចេញនូវមូលដ្ឋានគ្រឹះក្នុងការរើសអើង គឺនិន្នាការភេទនិងអត្តសញ្ញាណយេនឌ័រចេញពីសេចក្តីប្រកាស។[30] ក្នុងនាមជាប្រធានអាស៊ានដ៏លេចធ្លោមួយ កម្ពុជាបិតក្នុងតួនាទីដ៏ល្អមួយក្នុងការកំណត់របៀបវារៈអាស៊ាន និងធ្វើការតស៊ូមតិឲ្យមានការធ្វើវិសោធនកម្មលើស.ប.ស.អនេះ ដោយទាមទារឲ្យដាក់បញ្ចូលនូវបញ្ញត្តិនោះវិញ ដើម្បីអាចឲ្យបណ្តាជនភ.ជ.ព.បអាចទទួលបានការការពារពេញលេញ និងរាល់ទម្រង់រើសអើងដោយសារនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រត្រូវបានហាមឃាត់ជាដាច់ខាត។ ម.ស.ម.ក ជំរុញឲ្យរដ្ឋាភិបាលកម្ពុជាប្រើប្រាស់តួនាទីរបស់ខ្លួនជាប្រធានអាស៊ានក្នុងការធ្វើវិសោធនកម្មនេះ ហើយបញ្ចូលនូវកិច្ចគាំពារទាំងឡាយដល់សិទ្ធិភ.ជ.ព.បទៅក្នុងស.ប.ស.អ មុនពេលសេចក្តីប្រកាសនេះនឹងត្រូវបានគេអនុវត្តពេញលេញជាស្ថាពរ។

អ្វីដែលសេចក្តីថ្លែងការណ៍របស់វេទិកាភ.ជ.ព.ប.អ.ម.អ បានង្ហាញ គឺអំណាច និងសក្តានុពលនៃបណ្តាញភ.ជ.ព.បសម្របសម្រួលអាស៊ានមួយ ដែលធ្វើការជាដៃគូរ និងសហប្រតិបត្តិការជិតស្និត ក្នុងការបង្កើតជាសំឡេងឯងតែមួយក្នុងការបញ្ចុះបញ្ចូលដល់រដ្ឋាភិបាល និងតួអង្គសំខាន់ៗដទៃទៀតក្នុងតំបន់អាស៊ាន ពាក់ព័ន្ធនឹងសិទ្ធិភ.ជ.ព.ប។ ទោះជាយ៉ាងនេះក្តី បណ្តាញភ.ជ.ព.ប បច្ចុប្បន្នកំពុងធ្វើប្រតិបត្តិការដោយឈរលើមូលដ្ឋានមិនផ្លូវការមួយ និងអាចទទួលបានផលប្រយោជន៍នៃការទទួលស្គាល់ពីប្រភពនានា។ ជាថ្មីម្តងទៀត រដ្ឋាភិបាលកម្ពុជា គឺមានតួនាទីសំខាន់ក្នុងនាមជាប្រធានអាស៊ាន ក្នុងការជះឥទ្ធិពល និងអំណាចរបស់ខ្លួនដើម្បីគៀងគរឲ្យមានការទទួលស្គាល់បណ្តាញភ.ជ.ព.បជាផ្លូវការ និងលើកទឹកចិត្តរដ្ឋជាសមាជិកដទៃទៀតឲ្យគាំទ្រទាំងផ្នែកហិរញ្ញវត្ថុ និងបង្កើតជាលំហមួយសម្រាប់សេរីភាពក្នុងការបញ្ចេញមតិតាមបណ្តារដ្ឋជាសមាជិក។

---

[28] សេចក្តីថ្លែងការណ៍របស់វេទិកាភ.ជ.ព.ប.អ.ម.អ "សេចក្តីប្រកាសសិទ្ធិមនុស្សអាស៊ានបដិសេធក្នុងការការពារសិទ្ធិរបស់ភ.ជ.ព.ប.អ.ប" (ចេញផ្សាយនៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១២)
<www.sithi.org/temp.php?url=media_view2.php&mid=6095>។

[29] ដូចខាងលើ។

[30] ម.ស.ម.ក "ម.ស.ម.កគូសបញ្ជាក់ពីភាពគ្រោះថ្នាក់ក្នុងការអនុម័តសេចក្តីប្រកាសស្តីពីសិទ្ធិមនុស្សអាស៊ានដែលមានចន្លោះប្រហោង" (សេចក្តីថ្លែងការណ៍ ចេញផ្សាយថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១២)
<www.sithi.org/temp.php?url=media_view2.php&mid=6093>។

បន្ថែមលើសពីការធ្វើអធិប្បាយជុំវិញសេចក្ដីប្រកាសនោះ សិក្ខាសាលារបស់វេទិកាភ.ដ.ព.ប.អ.ម.អ ក៏ផ្ដល់ជាឱកាសក្នុងការចែករំលែកបទពិសោធន៍ជោគជ័យក្នុងការតស៊ូមតិ និងគំនិតផ្ដួចផ្ដើមយុទ្ធនាការនានារវាងប្រទេសទាំងឡាយក្នុងតំបន់ ហើយក៏អាចស្វែងយល់ពីរបៀបដែលយន្តការទាំងអស់នោះត្រូវបានអនុម័តយ៉ាងជោគជ័យតាមបណ្ដាប្រទេសដែលចែករំលែក។ តួយ៉ាង ដូចជាចលនាដែលកំពុងបន្តធ្វើឡើងក្នុងការទាមទារឲ្យអនុម័តច្បាប់អាពាហ៍ពិពាហ៍អ្នកស្រឡាញ់ភេទដូចគ្នានៅប្រទេសវៀតណាម និងកិច្ចប្រឹងប្រែងរបស់សកម្មជនម៉ាឡេស៊ីក្នុងការធានាដល់សិទ្ធិរបស់បណ្ដាជនប្ដូរភេទទាំងអស់តាមរយៈប្រព័ន្ធតុលាការ។

អាស្រ័យហេតុនេះហើយ ក្នុងកាលៈទេសៈដែលមានការគំរាមកំហែងដល់សន្តិសុខ និងសិទ្ធិសេរីភាពជាមូលដ្ឋានរបស់បណ្ដាជនភ.ដ.ព.ប នៅតាមបណ្ដាប្រទេសជាច្រើននៃតំបន់អាស៊ាន ដោយរួមមានកម្ពុជាផងដែរនោះ នេះពិតជាចាំបាច់ណាស់ដែលការវិវត្តន៍ និងការពង្រឹងបណ្ដាញភ.ដ.ព.ប និងសកម្មជនភ.ដ.ព.បនៅកម្រិតថ្នាក់ជាតិ គួរត្រូវបានគេដាក់ជាអាទិភាព។ ខណៈដែលកម្ពុជាបានវិវត្តជាបណ្ដើរៗជុំវិញគំនិតផ្ដួចផ្ដើមការតស៊ូមតិដ៏មានប្រសិទ្ធិភាព ក្នុងនាមពលរដ្ឋភ.ដ.ព.ប និងវឌ្ឍនភាពបណ្ដាញសហគមន៍នៃសកម្មជនភ.ដ.ព.បនៅកម្ពុជា ដែលរួមមានការបណ្ដុះបណ្ដាលដល់បណ្ដាញភ.ដ.ព.បដែលទើបបង្កើតថ្មី ចាប់តាំងពីរបាយការណ៍ឆ្នាំ២០១០របស់ម.ស.ម.កបានបោះពុម្ពផ្សាយនោះមក យន្តការទាំងអស់នេះនឹងផ្ដល់ជាប្រយោជន៍ក្នុងការចែករំលែក និងធនធាន។ ទំនាក់ទំនងប្រសើរជាងនេះ រវាងគម្រោងឬគំនិតផ្ដួចផ្ដើមជុំវិញភ.ដ.ព.ប និងជាពិសេសបណ្ដាញមូលដ្ឋាន និងអង្គការមិនមែនរដ្ឋាភិបាលថ្នាក់ជាតិ ក៏នឹងអាចជំរុញឲ្យស្ថានភាពបច្ចុប្បន្នមានភាពប្រសើរឡើងផងដែរ។ សហគមន៍ភ.ដ.ព.បនៅកម្ពុជា នឹងទទួលបានផលប្រយោជន៍ច្រើនពីការណ៍ដែលមានទស្សនៈវិស័យ សំឡេង និងការចែករំលែកធនធាន រួមគ្នាមួយ។

មិនតែប៉ុណ្ណោះ ក្រុមសង្គមស៊ីវិលនៅអាស៊ាន អាចផ្ដល់ផលប្រយោជន៍ដល់ចលនាភ.ដ.ព.ប ជាទូទៅមួយ តាមរយៈការសហការណ៍ជិតស្និតរវាងគ្នា ក្នុងន័យជានាំឲ្យបាននូវយន្តការល្អ និងបង្រួបបង្រួមមួយក្នុងការធ្វើការតស៊ូមតិសម្រាប់បណ្ដាជនភ.ដ.ព.ប។ ការប្រកួតប្រជែង និងធ្វើការជាន់គ្នាដដែលៗ ដែលត្រូវបានយល់ថាជាបញ្ហាទូទៅមួយ ក្នុងសហគមន៍អង្គការមិនមែនរដ្ឋាភិបាលនោះ គឺនឹងធ្វើឲ្យខូចខាតដល់វិស័យសិទ្ធិមនុស្សដែលទើបនឹងរីកដុះដាលឡើង តួយ៉ាងសម្រាប់ចលនាភ.ដ.ព.បនៅក្នុងតំបន់អាស៊ានជាដើម។ ជាការចាំបាច់ណាស់ដែលការតស៊ូមតិ និងការគាំទ្រដល់បណ្ដាជនភ.ដ.ព.ប ត្រូវបានធ្វើសមាហរណ៍កម្មទៅក្នុងសកម្មភាពសិទ្ធិមនុស្ស ដោយសារថាការតស៊ូមតិសម្រាប់សិទ្ធិរបស់បណ្ដាជនភ.ដ.ព.ប គឺជាការតស៊ូមតិមួយដើម្បីធ្វើឲ្យបណ្ដាជនភ.ដ.ព.បអាចទទួលបាន និងអាចប្រើប្រាស់សិទ្ធិមនុស្សដូចគ្នាមួយ ដូចមានចែងក្នុងសេចក្ដីប្រកាសជាសលស្ដីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាអន្តរជាតិ ដែលបុគ្គលគ្រប់រូបត្រូវទទួលបាន។ ឈរលើមូលហេតុនេះហើយ ម.ស.ម.កបានព្យាយាមជៀសមិនប្រើវាក្យស័ព្ទ "សិទ្ធិភ.ដ.ព.ប" ក្នុងរបាយការណ៍នេះ ដោយសារថាវាក្យស័ព្ទនេះ អាចធ្វើឲ្យយើងយល់ថាមានសិទ្ធិផ្សេងដទៃទៀត ជាពិសេសសម្រាប់តែបណ្ដាជនភ.ដ.ព.ប ជំនួសទៅវិញ ម.ស.ម.ក បានប្រើវាក្យស័ព្ទ "សិទ្ធិរបស់បណ្ដាជនភ.ដ.ព.ប"។ គោលបំណងសំខាន់នៃការតស៊ូមតិដើម្បីបណ្ដាជនភ.ដ.ព.ប គឺដើម្បីធានាថាបណ្ដាជនភ.ដ.ព.ប អាចទទួលបាននូវសិទ្ធិស្មើគ្នា។

**អនុសាសន៍ដល់រដ្ឋាភិបាល៖ ប្រើប្រាស់តួនាទីរបស់ខ្លួនជាប្រធានអាស៊ាន ដើម្បីធ្វើវិសោធនកម្មលើសេចក្ដីប្រកាសស្ដីពីសិទ្ធិមនុស្សអាស៊ាន ដោយដាក់បញ្ចូលនូវសេចក្ដីយោងជាក់លាក់ពីនិន្នាភេទ និងអត្តសញ្ញាណយេនឌ័រ ជាមូលដ្ឋានក្នុងការហាមប្រាមដល់ការរើសអើង។**

អនុសាសន៍ដល់រដ្ឋាភិបាល៖ ប្រើប្រាស់តួនាទីរបស់ខ្លួនជាប្រធានអាស៊ាន ដើម្បីទទួលស្គាល់ជាផ្លូវការនូវបណ្តាញភ.ជ.ព.ប និងជំរុញឲ្យរដ្ឋជាសមាជិកអាស៊ានដទៃទៀតគាំទ្រជំហរនេះ។

អនុសាសន៍ដល់សង្គមស៊ីវិល៖ ធ្វើការជាដៃគូ និងសហការជិតស្និតជាមួយដៃគូរនៅបណ្តាប្រទេសក្នុងថ្នាក់តំបន់អាស៊ាន ដើម្បីបង្កើតឲ្យបានជាសំឡេងមួយខ្លាំង ក្នុងការបញ្ចុះបញ្ចូលរដ្ឋាភិបាល និងតួអង្គដទៃទៀតក្នុងតំបន់អាស៊ានដើម្បីភ្ជាប់នឹងសិទ្ធិរបស់បណ្តាជនភ.ជ.ព.ប។

អនុសាសន៍ដល់សង្គមស៊ីវិល៖ ស្វែងរកឱកាសដែលអាចធ្វើឲ្យបណ្តាញភ.ជ.ព.បមានលក្ខណៈផ្លូវការ អាចទទួលបានជំនួយថវិកា និងពង្រឹងបន្ថែម តាមរយៈការពិនិត្យមើលឡើងវិញ និងបង្កើតបន្ថែមនូវវគ្គបណ្តុះបណ្តាលដល់បណ្តាញភ.ជ.ព.ប ដោយដាក់បញ្ចូលនូវការអប់រំជំនាញការងារ បច្ចេកវិទ្យា និងភាសាជាដើម។

អនុសាសន៍ដល់សង្គមស៊ីវិល៖ បង្កើត និងពង្រឹងបណ្តាញភ.ជ.ព.បនៅថ្នាក់ជាតិ និងភ្ជាប់ទំនាក់ទំនងរវាងពួកគាត់ ដើម្បីគាំទ្រ និងតស៊ូមតិទាមទារសិទ្ធិដល់បណ្តាជនភ.ជ.ព.ប។

អនុសាសន៍ដល់សង្គមស៊ីវិល៖ បន្តចូលរួមគាំទ្រដាក់បញ្ចូលបណ្តាជនភ.ជ.ព.ប ក្នុងគ្រប់សកម្មភាពសិទ្ធិមនុស្សទាំងឡាយ និងចែករំលែកគំរូល្អៗដល់អង្គការមិនមែនរដ្ឋាភិបាល និងដៃគូនានាក្នុងតំបន់អាស៊ាន។

## ៤.៣. ជីវិតគ្រួសារ

បណ្តាជនភ.ជ.ព.បនៅកម្ពុជាភាគច្រើន មិនអាចរស់នៅក្នុងជីវភាពមួយដែលពួកគាត់ប្រាថ្នា ដោយសារតែការសម្លឹងមើលក្នុងន័យអវិជ្ជមានពីសង្គម និងគំនាបគ្រួសារ។ ឪពុកម្តាយជាច្រើនមិនហ៊ានគាំទ្រកូនចៅរបស់ខ្លួនជាសាធារណៈ ដោយបារម្ភពីការម៉ាក់ងាយពីសង្គម។ ស្ថានភាពនេះ ជាញឹកញយគឺមានលក្ខណៈធ្ងន់ធ្ងរជាងសម្រាប់បណ្តាជនជាស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ និងអ្នកប្តូរភេទ ដោយសារតែបញ្ហាយេនឌ័រក្លាយជាមូលដ្ឋានក្នុងការរើសអើង។[31] ការៈចេញជាចំហ៉ ទៅកាន់គ្រួសាររបស់ពួកគាត់ គឺជារឿយៗទទួលបានមកវិញនូវផលអវិជ្ជមាន។ ពេលខ្លះ ឪពុកម្តាយបានកាត់កាលកូនរបស់ខ្លួនបន្ទាប់ពីត្រូវបានប្រាប់ការពិត ដោយកាត់ផ្តាច់ជនទាំងនោះចេញពីការផ្តត់ផ្គង់ជាស្មារតី ឬ ហិរញ្ញវត្ថុជាដើម ហើយកត្តាទាំងអស់នេះបានបណ្តាលឲ្យយុវវ័យជាច្រើនត្រូវរស់នៅតាមចិញ្ចើមផ្លូវ រស់នៅក្នុងសភាពអត់ឃ្លាន និងងាយនឹងរងគ្រោះដោយសារការបំពានពីអ្នកមិនស្គាល់ និងមន្ត្រីអនុវត្តច្បាប់។ ឪពុកម្តាយខ្លះជឿជាក់ថាការដែលបុគ្គលម្នាក់ជាអ្នកស្រឡាញ់ភេទដូចគ្នា គឺជាបញ្ហារោគចិត្ត និងអាចព្យាបាលបានតាមរយៈវិធីសាស្ត្រព្យាបាលដោយគ្រូខ្មែរ ដូចជាស្រោចទឹក និងព្យាបាលការស្រឡាញ់ភេទដូចគ្នាចេញ[32] ដែលកិច្ចការទាំងអស់នេះ អាចជាបទពិសោធន៍បាក់ស្បាតយ៉ាងខ្លាំង។

---

[31] លោកស្រី ណារី ភីឡៃ "របាយការណ៍របស់អង្គការសហប្រជាជាតិ" (ចេញផ្សាយនៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១១) ទំព័រទី២១។

[32] សិក្ខាសាលារួមគ្នាមួយរវាងបណ្តាញបុរសស្ត្រីដើម្បីការអភិវឌ្ឍន៍ និងម.ស.ម.ក (ទីក្រុងភ្នំពេញ ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ ២០១១)

បន្ថែមលើសនេះទៀតនោះ យុវវ័យនៅកម្ពុជាទទួលរងនូវគំនាបជាច្រើនឲ្យរៀបអាពាហ៍ពិពាហ៍ ទាំងពីសំណាក់គ្រួសារ និងសង្គម ដែលនេះជារើយៗបន្ថែមផលលំបាកដល់បណ្តាជនក.ជ.ព.ប ឲ្យលាក់លាមនិន្នាការភេទរបស់ពួកខ្លួន។ ករណីជាច្រើន សម្ពាធនេះបានបណ្តាលឲ្យបុរសដែលស្រឡាញ់បុរសដូចគ្នា រៀបការជាមួយស្ត្រី ប៉ុន្តែនៅរក្សាទំនាក់ទំនងផ្លូវភេទជាមួយបុរសដដែល។ តាមរយៈរបាយការណ៍សិក្សាមួយផ្សាយនៅឆ្នាំ ២០០០ ដោយអង្គការអន្តរជាតិសុខភាពគ្រួសារ បានឲ្យដឹងថា បុរសជាង៩% ដែលបង្ហាញអត្តសញ្ញាណរបស់ខ្លួនជាបុរស បានមានទំនាក់ទំនងផ្លូវភេទជាមួយបុរស" ("បុរសស្រឡាញ់បុរស") បើទោះបីជាខ្លួនបានរៀបការរួចហើយក៏ដោយ។[33] អំឡុងពេលដែលម.ស.ម.កបានរៀបចំសិក្ខាសាលានៅទីក្រុងភ្នំពេញ កាលពីថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១១[34] សិក្ខាកាមបានទាមទារថា រដ្ឋាភិបាលគួរជានាឲ្យបាននូវការទទួលបានសិទ្ធិមនុស្សស្មើគ្នាសម្រាប់បុគ្គលគ្រប់រូប ដែលក្នុងនោះបណ្តាជនក.ជ.ព.ប អាចស្រឡាញ់គ្នា និងរស់នៅជាមួយគ្នាដោយចំហ ជាជាងត្រូវបង្ខំចិត្តយកអាពាហ៍ពិពាហ៍ជា"ខែលបាំង" ដែលអាចប៉ះពាល់ដល់សេចក្តីសុខខ្លួនឯងផ្ទាល់ និងក្នុងគ្រួសារផងដែរ។ សមាជិកគ្រួសារ គឺជាភាគីសំខាន់ក្នុងដំណើរការកាត់បន្ថយការម៉ាក់ងាយ ការរើសអើង និងការរំលោភបំពានសិទ្ធិមនុស្ស ហើយការអត់អោន និងការទទួលស្គាល់ពីគ្រួសារ ជួយឲ្យជីវិតមួយអាចផ្លាស់ប្តូរទៅរកភាពប្រសើរឡើង។

នៅឆ្នាំ១៩៧២ គម្រោងឪពុកម្តាយ ក្រុមគ្រួសារ និងមិត្តភក្តិរបស់អ្នកស្រឡាញ់ភេទដូចគ្នា (ហៅកាត់ថា "គម្រោងសាច់ញាតិរបស់អ្នកស្រឡាញ់ភេទដូចគ្នា") ត្រូវបានចាប់ផ្តើមឡើងនៅសហរដ្ឋអាមេរិក ដើម្បីចងក្រង ឪពុកម្តាយ ក្រុមគ្រួសារ និងមិត្តភក្តិ របស់អ្នកស្រឡាញ់ភេទដូចគ្នា ក្នុងការរៀបចំកម្មវិធីអប់រំ និងការតស៊ូមតិគាំទ្រដល់សិទ្ធិរបស់បណ្តាជនក.ជ.ព.ប។ ចាប់តាំងពីពេលនោះមក គម្រោងស្រដៀងគ្នា ដែលខ្លះក៏បានប្រើឈ្មោះដូចគ្នា គឺ "គម្រោងសាច់ញាតិរបស់អ្នកស្រឡាញ់ភេទដូចគ្នា" ត្រូវបានចាប់ផ្តើមនៅប្រទេសដទៃផងដែរ តួយ៉ាងប្រទេសអាសង់ទីន អូស្ត្រាលី ប៊ែលស៊ិច ចិន អ៊ីស្រាអ៊ែល ចាមែកា ជប៉ុន និងប្រទេសឯទៀត។ នៅថ្ងៃទី ១១ ខែឧសភា ឆ្នាំ២០១១ គម្រោងសាច់ញាតិរបស់អ្នកស្រឡាញ់ភេទដូចគ្នា ប្រចាំនៅប្រទេសវៀតណាមត្រូវបានសម្ពោធឡើង ដែលគម្រោងនេះក្លាយជាធនធានមួយសម្រាប់ប្រទេសនេះ ក្នុងការផ្តល់កិច្ចគាំទ្រដល់គ្រួសារ និងសាច់ញាតិរបស់បណ្តាជនក.ជ.ព.ប។[35] អំឡុងព្រឹត្តការណ៍កាលពីខែវិច្ឆិកា ឆ្នាំ២០១២ នៅទីក្រុងហូជីមិញ (សៃហ្គន) សិក្ខាកាមនៃគម្រោងសាច់ញាតិរបស់អ្នកស្រឡាញ់ភេទដូចគ្នាបានថ្លែងថា *"ខ្ញុំយល់ច្បាស់ថា កូនប្រុសរបស់ខ្ញុំ និងអ្នកទាំងឡាយដែលស្រឡាញ់ភេទដូចគ្នាត្រូវរងទុក្ខដោយសារការម៉ាកងាយពីសង្គម។ ដូច្នេះខ្ញុំគ្រាន់តែសង្ឃឹមថា ឪពុកម្តាយដទៃទៀតដែលមានកូនរបស់ខ្លួនជាអ្នកស្រឡាញ់ភេទដូចគ្នានោះគួរតែមើល*

---

[33] អង្គការអន្តរជាតិសុខភាពគ្រួសារ "អាកប្បកិរិយាផ្លូវភេទ មេរោគឆ្លងតាមរយៈការរួមភេទ និងជំងឺអេដស៍ក្នុងចំណោមបុរសដែលមានទំនាក់ទំនងផ្លូវភេទជាមួយបុរសដូចគ្នា នៅទីក្រុងភ្នំពេញ" (កម្ពុជា ឆ្នាំ២០០០) ទំព័រ៦។ <www.fhi360.org/en/HIVAIDS/pub/survreports/MSMCambodia/index.htm>។

[34] សិក្ខាសាលារួមគ្នាមួយរវាងបណ្តាញបុរសស្ត្រីដើម្បីការអភិវឌ្ឍន៍ និងម.ស.ម.ក (ទីក្រុងភ្នំពេញ ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ ២០១១)

[35] "ការចាប់ផ្តើមគម្រោងសាច់ញាតិរបស់អ្នកស្រឡាញ់ភេទដូចគ្នានៅវៀតណាម" (គណៈកម្មការអន្តរជាតិស្តីពីសិទ្ធិបុរសស្រឡាញ់បុរស និងស្ត្រីស្រឡាញ់ស្ត្រី ចេញផ្សាយថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១១) <www.iglhrc.org/cgi-bin/iowa/article/takeaction/partners/1397.html>.

*ថែទាំកូនជាទីស្រឡាញ់របស់ខ្លួនដោយភាពអត់អោន*។[36] ផ្អែកលើឧទាហរណ៍របស់ប្រទេសវៀតណាមនេះ យើងឃើញមានសក្តានុពលខ្លាំង ក្នុងការបង្កើតឲ្យមានកម្មវិធីស្រដៀងគ្នានេះនៅកម្ពុជា ដែលអាចឆ្លើយតបនឹងទស្សនៈយល់ឃើញ និងអត្តចរិតរបស់ឪពុកម្តាយ និងគ្រួសារនៃបណ្ណាជនក.ជ.ព.ប។ សិក្ខាសាលាផ្តួចផ្តើមមួយ "ស្តីពីការទទួលស្គាល់ពីគ្រួសារ" ត្រូវបានរៀបចំធ្វើឡើង នៅទីក្រុងភ្នំពេញ កាលពីថ្ងៃទី១៧ ខែឧសភា ឆ្នាំ ២០១២ ដើម្បីចូលរួមទិវាអន្តរជាតិប្រឆាំងការស្អប់ខ្ពើមអ្នកស្រឡាញ់ភេទដូចគ្នា (ហៅកាត់ថា "អាយដាហូ") ដែលផ្តល់ជាចំណុចចាប់ផ្តើមមួយសម្រាប់កិច្ចសន្ទនា។

**អនុសាសន៍ដល់សង្គមស៊ីវិលៈ រៀបចំក្រុមពិភាក្សាដើម្បីពិភាក្សា គម្រោង "ការទទួលស្គាល់ពីគ្រួសារ" នៅកម្ពុជា ដែលអាចផ្តល់សេវាកម្មស្រដៀងគ្នានឹងគម្រោងសាច់ញាតិរបស់អ្នកស្រឡាញ់ភេទដូចគ្នា ហើយបន្ទាប់មកបង្កើតជាគម្រោងសាច់ញាតិរបស់អ្នកស្រឡាញ់ភេទដូចគ្នាសាកល្បងនៅកម្ពុជា។**

## ៤.៤. អាពាហ៍ពិពាហ៍រវាងអ្នកស្រឡាញ់ភេទដូចគ្នា

"សិទ្ធិក្នុងការរៀបអាពាហ៍ពិពាហ៍ និងបង្កើតគ្រួសារ" ត្រូវបានទទួលស្គាល់ក្នុងមាត្រា១៦ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងមាត្រា២៣ នៃក.អ.ស.ព.ន។ ជាងនេះទៅទៀត អង្គការលើកលែងទោសអន្តរជាតិបានអះអាងថា សមភាពក្នុងការរៀបអាពាហ៍ពិពាហ៍ គឺជាផ្នែកមួយនៃសិទ្ធិមនុស្ស ដោយលើកឡើងថាៈ *"ការបដិសេធចំពោះសិទ្ធិស្មើគ្នាក្នុងទំនាក់ទំនងផ្លូវភេទដូចគ្នា បានដកហូតសិទ្ធិដទៃទៀតពីបុគ្គលជាច្រើន ហើយបានបណ្តាលឲ្យកើត ជាការម៉ាកងាយដល់ទំនាក់ទំនងទាំងនោះ និងជុតពេលនូវការរើសអើងនិងការបំពានដទៃទៀតក្នុងសហគមន៍ សាលារៀន និងផ្ទះ ប្រឆាំងនឹងសិទ្ធិមនុស្សរបស់ជនភាគតិចខាងផ្លូវភេទ"។*[37] នៅកម្ពុជា អាពាហ៍ពិពាហ៍ត្រូវបានគេឲ្យនិយមន័យ តាមរយៈមាត្រា៤៥ នៃរដ្ឋធម្មនុញ្ញ និងមាត្រា៣ នៃច្បាប់អាពាហ៍ពិពាហ៍និងគ្រួសារ ថាជាកិច្ចព្រមព្រៀង ឬកិច្ចសន្យារវាងបុរសម្នាក់ និងស្ត្រីម្នាក់ ខណៈដែលអាពាហ៍ពិពាហ៍រវាងអ្នកស្រឡាញ់ភេទដូចគ្នា ត្រូវបានហាមឃាត់ជាពិសេសក្នុងមាត្រា៦ នៃច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ។[38]

មកទល់នឹងខែធ្នូ ឆ្នាំ២០១២ ប្រទេសសរុបចំនួន១១ បានដាក់អាពាហ៍ពិពាហ៍អ្នកស្រឡាញ់ភេទដូចគ្នាឲ្យស្របច្បាប់។[39] អាពាហ៍ពិពាហ៍អ្នកស្រឡាញ់ភេទដូចគ្នាលើកដំបូងគេបង្អស់គឺ ប្រព្រឹត្តឡើងនៅប្រទេសហូឡង់ដ៏ កាលពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០០១។ ប្រទេសបន្ទាប់មកទៀតនោះ គឺប៊ែលស៊ិដ អេស្ប៉ាញ កាណាដា

---

[36] អាណា លិច "មនុស្ស៨០០នាក់បានអបអរសាទរភាពចម្រុះបែបនៃនិន្នាការភេទ នៅប្រទេសវៀតណាម" (សារព័ត៌មានហ្គេស្តា ចេញផ្សាយថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១២) <www.gaystarnews.com/article/800-celebrate-sexualities-diversity-vietnam271112>

[37] អង្គការលើកលែងទោសអន្តរជាតិ "សេចក្តីស្រឡាញ់គឺជាសិទ្ធិមនុស្ស" <www.amnestyusa.org/our-work/issues/lgbt-rights/marriage-equality>។

[38] មានករណីលើកលែងមួយ កាលពីឆ្នាំ១៩៩៥ គូរស្រករស្ត្រីស្រឡាញ់ស្ត្រីមួយគូត្រូវបានគេអនុញ្ញាតិឲ្យរៀបអាពាហ៍ពិពាហ៍នៅខេត្តកណ្តាល។ សូមមើលអត្ថបទរបស់ទិវា គាំ និងម៉េងហួង "ដូចគ្នា តែរៀបគ្នា" (ភ្នំពេញប៉ុស្តិ៍ ផ្នែកលីហ្វ ចេញផ្សាយថ្ងៃទី២២ ខែកញ្ញា ឆ្នាំ ២០១០។ <www.phnompenhpost.com/index.php/2010092242205/LIFT/same-same-but-married.html>។

អាព្រិចខាងត្បូង ន័រវេ ស៊ុយអែត ប៉ទុយហ្គាល់ អាយលេន អាស៊ិង់ទីន និងដាណឺម៉ាក។[40] លើសពីនេះ ប្រទេសខ្លះទៀតបានអនុម័តច្បាប់ស្តីពី ″ភាពជាដៃគូរ″ ឬសម្ព័ន្ធមេត្រីភាព អ្នកស្រឡាញ់ភេទដូចគ្នា ដែលក្នុងនោះមានប្រទេសបារាំង និងចក្រភពអង់គ្លេស។[41] នៅប្រទេសខ្លះ អាពាហ៍ពិពាហ៍អ្នកស្រឡាញ់ភេទដូចគ្នា ឬសម្ព័ន្ធមេត្រីភាព ត្រូវបានអនុញ្ញាតិនៅក្នុងយុត្តាធិការជាកើលាក់មួយចំនួននៃប្រទេសនោះ តួយ៉ាងគឺតាមទីក្រុងឬរដ្ឋនិមួយៗ ប៉ុន្តែមិននៅក្នុងទីក្រុងឬរដ្ឋឯទៀតឡើយ ដូចជាប្រទេសម៉ិចស៊ីកូ[42] អាមេរិក និងអូស្ត្រាលីជាដើម។ ការសិក្សាអន្តរជាតិមួយ ដែលត្រូវបានរៀបចំឡើងដោយអង្គការ ថ្ងៃនៃសុខភាព នៅសហរដ្ឋអាមេរិក ប្រចាំនៅទី

---

[39] ទីស្តីការប្រទេសបារាំង (ដែល″ភាពជាដៃគូរអ្នកស្រឡាញ់ភេទដូចគ្នា" ជាបញ្ញត្តិស្របច្បាប់ហើយនោះ) បានអនុម័តលើសេចក្តីព្រាងនាពេលថ្មីៗនេះ ដើម្បីដាក់ឲ្យអាពាហ៍ពិពាហ៍អ្នកស្រឡាញ់ភេទដូចគ្នាស្របច្បាប់។ សេចក្តីព្រាងច្បាប់នោះត្រូវបានរំពឹងថា នឹងបានអនុម័តជាស្ថាពរនៅដើមឆ្នាំ២០១៣ បន្ទាប់ពីកិច្ចពិភាក្សាវែកញែកនៅព្រឹទ្ធិសភាបារាំង ដែលនេះនឹងធ្វើឲ្យបារាំងក្លាយជាប្រទេសទី១២ ដែលបានដាក់អាពាហ៍ពិពាហ៍អ្នកស្រឡាញ់ភេទដូចគ្នាឲ្យស្របច្បាប់។ សូមមើល ស្ទីវិនអ៊ែលលេនជឺ "ទីស្តីការបារាំងបានដាក់ចេញនូវច្បាប់អាពាហ៍ពិពាហ៍អ្នកស្រឡាញ់ភេទដូចគ្នា ថ្វីបើមានការជំទាស់ពីអ្នកអភិរក្សនិយម" ចេញផ្សាយដោយញូយ៉កថែមស៏ ថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១២។ <www.nytimes.com/2012/11/08/world/europe/gay-marriage-bill-advances-in-france.html>។

[40] ថូម៉ាស់ អាដាស៊ិន "ការងាកមើលលើអាពាហ៍ពិពាហ៍អ្នកស្រឡាញ់ភេទដូចគ្នា និងការអនុម័តច្បាប់ជាទូទៅនៅពិភពលោក″ អាស្ស៊ូស៊ីអេតធិដប្រេស (ចេញផ្សាយថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១២)។ <http://news.yahoo.com/look-gay-marriage-adoption-worldwide-154940786.html>។

[41] នៅប្រទេសជាច្រើន សម្ព័ន្ធមេត្រីភាពតាមការចុះអ៊ីតាស៊ីវិល (ហៅម្យ៉ាងទៀតថា "ភាពជាដៃគូប្តីប្រពន្ធ អាស្រ័យលើយុត្តាធិការ) ត្រូវបានដាក់ចេញ ដើម្បីអនុញ្ញាតិឲ្យគូរស្រករភេទដូចគ្នា អាចចុះកិច្ចព្រមព្រៀងស្របច្បាប់ ដែលនេះស្រដៀងនឹងអាពាហ៍ពិពាហ៍ខណៈដែលអាពាហ៍ពិពាហ៍អ្នកស្រឡាញ់ភេទដូចគ្នាមិនទាន់ត្រូវបានគេដាក់ឲ្យស្របច្បាប់នៅឡើយ។ ខណៈប្រទេសខ្លះ ដូចជាចក្រភពអង់គ្លេសជាដើម អាពាហ៍ពិពាហ៍ និងសម្ព័ន្ធប្តីប្រពន្ធតាមការចុះអ៊ីតាស៊ីវិល គឺមានសារៈសំខាន់ដូចគ្នា ដោយសារមានការផ្សារភ្ជាប់នឹងផលប្រយោជន៍ និងកាតព្វកិច្ចស្របច្បាប់ខណៈដែលប្រទេសដទៃដូចជាសហរដ្ឋអាមេរិក និងបារាំង លទ្ធផលនឹងមានលក្ខណៈផ្ទុយពីនេះដោយសារតែសិទ្ធិរបស់អ្នកស្រឡាញ់ភេទដូចគ្នាខ្លះ ឬភាគច្រើនត្រូវបានគេបដិសេធ។ សូម្បីតែនៅប្រទេសខ្លះដែលភាពខុសគ្នាមានលក្ខណៈតិចតួច ឬមិនមានទាល់តែសោះនោះ ការបង្កើតរចនាសម្ព័ន្ធច្បាប់ដោយឡែកមួយសម្រាប់គូរស្រករស្រឡាញ់ភេទដូចគ្នា គឺជាការរើសអើង។ កម្ពុជាគួរតែជៀសវាងនូវការព្យាយាមបង្កើតនូវរចនាសម្ព័ន្ធច្បាប់មួយដោយឡែក ឬមានលក្ខណៈរើសអើងស្រដៀងគ្នានេះសម្រាប់គូរស្រករអ្នកស្រឡាញ់ភេទដូចគ្នាជាដាច់ខាត ហើយជំនួសមកវិញគួរតែដាក់អាពាហ៍ពិពាហ៍អ្នកស្រឡាញ់ភេទដូចគ្នាឲ្យស្របច្បាប់។ ដើម្បីត្រួតពិនិត្យមើលទិដ្ឋភាពទូទៅនៃបញ្ហាសម្ព័ន្ធភាពតាមរយៈការចុះអ៊ីតាស៊ីវិលនេះ សូមមើល៖ សមភាពអាពាហ៍ពិពាហ៍របស់ប្រជាពលរដ្ឋអូស្ត្រាលី "ការសាកល្បងដែលបរាជ័យមួយ៖ ហេតុអ្វីបានជាសម្ព័ន្ធតាមរយៈការចុះអ៊ីតាស៊ីវិលមិនអាចជំនួសឲ្យសមភាពអាពាហ៍ពិពាហ៍បាន" (សលកប័ត្រ) ឆ្នាំ២០១០ ។ <www.australianmarriageequality.com/wp/wp-content/uploads/2010/12/A-failed-experiment.pdf>

[42] តុលាការកំពូលរបស់ម៉ិចស៊ីកូ បានចេញដីកាសម្រេចកាលពីឆ្នាំ២០១០ ដោយតម្រូវឲ្យរដ្ឋដទៃទៀតត្រូវទទួលស្គាល់អាពាហ៍ពិពាហ៍អ្នកស្រឡាញ់ភេទដូចគ្នា ដែលត្រូវបានអនុវត្តរួចហើយនៅទីក្រុងម៉ិចស៊ីកូ។ សូមមើល៖ "តុលាការកំពូលរបស់ម៉ិចស៊ីកូ បានចេញដីកាសម្រេចឲ្យមានការទទួលស្គាល់អាពាហ៍ពិពាហ៍អ្នកស្រឡាញ់ភេទដូចគ្នា ទូទៅមួយនៅទូទាំងប្រទេស″ (*LGBTQ Nation* ចេញផ្សាយថ្ងៃទី១០ ខែសីហា ឆ្នាំ២០១០)។ <www.lgbtqnation.com/2010/08/mexico-supreme-court-orders-gay-marriages-recognized-country-wide/>.។

ក្រុងម៉ាសាចូសេត កាលពីឆ្នាំ ២០១១ បានរាយការណ៍ថា បុរសជាអ្នកស្រឡាញ់បុរសដូចគ្នា ដែលរស់នៅក្នុងរដ្ឋដែលអាពាហ៍ពិពាហ៍អ្នកស្រឡាញ់ភេទដូចគ្នាបានដាក់ឲ្យស្របច្បាប់នោះ គឺមានសុខភាពល្អជាង មានភាពតានតឹងតិចជាង ទៅជួបគ្រូពេទ្យតិចជាង និងចំណាយថវិកាលើសេវាថែទាំសុខភាពទាបជាង។[43]

ថ្វីបើមិនទាន់មានការសិក្សាស្រាវជ្រាវជាផ្លូវការនៅកម្ពុជាក្តី មានភ័ស្តុតាងជាក់ស្តែងបង្ហាញឲ្យឃើញថា អាពាហ៍ពិពាហ៍អ្នកស្រឡាញ់ភេទដូចគ្នាអាចធ្វើឲ្យជីវិតគ្រួសារមានភាពជោគជ័យ។ មានករណីមួយ ដែលគូរស្រករស្ត្រីស្រឡាញ់ស្ត្រីដែលម.ស.ម.ក បានជួបក្នុងអំឡុងសិក្ខាសាលា បានលើកឡើងថា ខ្លួនបានយកក្មេងកំព្រាបួន ឬប្រាំនាក់មកចិញ្ចឹមមើលថែឲ្យក្មេងទាំងនោះធាំធាត់ក្លាយជាក្មេងល្អ និងមានអាជីពត្រឹមត្រូវ។ ក្មេងទាំងនោះ មកដល់បច្ចុប្បន្ននេះ ក៏មានកូនចៅរបស់ពួកគាត់ផងដែរ ហើយប្រកបដោយក្តីគោរពដល់ជីដូនជីតារបស់ខ្លួន។ នេះគ្រាន់តែជាឧទាហរណ៍មួយ ស្របពេលដែលលោកយាយម្នាក់បានថ្លែងថា "គូរស្រករស្ត្រីស្រឡាញ់ស្ត្រីដូចគ្នា អាចជួយសង្គមតាមរយៈការចិញ្ចឹម និងផ្គត់ផ្គង់ដល់ក្មេងកំព្រា ហើយជួយផ្តល់ឲ្យពួកគេមានអនាគតល្អ"។ ភ័ស្តុតាងជាក់ស្តែងប្រភេទនេះ មានលក្ខណៈស្រដៀងគ្នានឹងការសិក្សាដែលបានធ្វើឡើងនៅប្រទេសឯទៀត ក្នុងរយៈពេលបីទសវត្សមកនេះ ដែលការសិក្សាស្រាវជ្រាវនោះបានរកឃើញថា កូនស្រីប្រុសរបស់ឪពុកម្តាយដែលជាអ្នកស្រឡាញ់ភេទដូចគ្នា គឺជាទូទៅមានសុខភាពផ្លូវចិត្តល្អប្រសើរ។[44] សិក្ខាកាមក្នុងសិក្ខាសាលាមួយ ដែលបណ្តាញជាតិបុរសស្រឡាញ់បុរស/បណ្តាញចតុមុខ និងសុខភាពបុរសកម្ពុជា បានរៀបចំធ្វើឡើងនៅខេត្តសៀមរាប កាលពីថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១១ បានស្នើថា រដ្ឋាភិបាលគួរតាក់តែងច្បាប់ថ្មីមួយដែលទទួលស្គាល់សម្ព័ន្ធមេត្រីភាពរវាងអ្នកស្រឡាញ់ភេទដូចគ្នា ឬក៏អាចជាអាពាហ៍ពិពាហ៍។[45]

**អនុសាសន៍ដល់រដ្ឋាភិបាល/រដ្ឋសភា៖ ធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ និងច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ដើម្បីអនុញ្ញាតិឲ្យមានអាពាហ៍ពិពាហ៍សម្រាប់អ្នកស្រឡាញ់ភេទដូចគ្នា។**

**អនុសាសន៍ដល់សង្គមស៊ីវិល៖ ធ្វើការស្ទាបស្ទង់មតិគ្រួសារដែលមានឪពុកម្តាយជាអ្នកស្រឡាញ់ភេទដូចគ្នាដើម្បីលើកកម្ពស់ការយល់ដឹងពីបាតុភូត ពិភាក្សាពីបញ្ហាសំខាន់ៗ និងផ្តល់ជាព័ត៌មានពីការវិវត្តន៍ជុំវិញបញ្ហានោះ។**

---

[43] "ការដាក់អពាហ៍ពិពាហ៍អ្នកស្រឡាញ់ភេទដូចគ្នាឲ្យស្របច្បាប់អាចជំរុញឲ្យអ្នកស្រឡាញ់ភេទដូចគ្នាមានសុខភាពល្អ" ( ព័ត៌មានសុខភាពប្រចាំថ្ងៃ ចេញផ្សាយថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ ២០១១ ) <http://news.yahoo.com/legalized-same-sex-marriage-may-boost-gay-mens-210409455.html>។

[44] សូមមើល ទីម៉ូធី ប៊ិបឡា និងជូឌិត ស្តេស៊ី "តើយេនឌ័រ និងឪពុកម្តាយពាក់ព័ន្ធគ្នាយ៉ាងណា?" (២០១០) ៧២.១ ព្រឹត្តប័ត្រអាពាហ៍ពិពាហ៍ និងគ្រួសារ លេខ៣។ សហជីពពលរដ្ឋសេរីអាមេរិក "តម្លៃខ្ពស់ពេកហើយ៖ករណីប្រឆាំងនឹងឪពុកម្តាយដែលជាអ្នកស្រឡាញ់ភេទដូចគ្នាដែលមានភាពរឹតត្បិត (របាយការណ៍) ឆ្នាំ២០០៦។<www.aclu.org/lgbt-rights_hiv-aids/too-high-price-case-against-restricting-gay-parenting>។ ស្តនវល យូខេ "គ្រួសារខុសប្លែកគ្នា៖ បទពិសោធន៍កូននៅជាមួយឪពុកម្តាយដែលជាស្ត្រីស្រឡាញ់ស្ត្រី និងបុរសស្រឡាញ់បុរស" (របាយការណ៍) ឆ្នាំ ២០១០។ <www.stonewall.org.uk/what_we_do/research_and_policy/health_and_healthcare/3471.asp>.

[45] សិក្ខាសាលារបស់បណ្តាញជាតិបុរសស្រឡាញ់បុរស/បណ្តាញចតុមុខ និងសុខភាពបុរសកម្ពុជា (ខេត្តសៀមរាប ថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១១)

## ៤.៥. សហគមន៍

ក្រុម ភ.ជ.ព.ប គឺជាក្រុមងាយរងគ្រោះជាពិសេសដោយសារមានការរើសអើង និងការបំពានក្នុងសហគមន៍របស់ពួកគេ។ របាយការណ៍ ស.ហ បានកត់សម្គាល់ថា *"ក្រុម ភ.ជ.ព.ប ដែលវ័យក្មេង និងគ្រប់វ័យទាំងអស់ដែលត្រូវបានមើលឃើញថាផ្តើនចំពោះបទដ្ឋានសង្គម សុទ្ធតែប្រឈមនឹងអំពើហិង្សាពីសំណាក់ក្រុមគ្រួសារ និងសហគមន៍។ ស្ត្រីស្រលាញ់ស្ត្រី និងស្ត្រីប្តូរភេទ ប្រឈមមុខជាពិសេសដោយសារតែអសមភាពផ្នែកយេនឌ័រ និងទំនាក់ទំនងផ្នែកអំណាចក្នុងក្រុមគ្រួសារ និងសង្គមទាំងមូល"។*[46] ដូចបានពិភាក្សាក្នុងរបាយការណ៍ ឆ្នាំ២០១០ សម្ពាធផ្នែកវប្បធម៌ សង្គម និងសេដ្ឋកិច្ច នៅកម្ពុជា បានជួយកំណត់សណ្ឋានឲ្យសង្គមដែលកូនប្រុស និងកូនស្រីតែងត្រូវបានដាក់សម្ពាធឲ្យរៀបការ និងមានកូន ជាលទ្ធផលធ្វើឲ្យ ក្រុម ភ.ជ.ព.ប ត្រូវបណ្តេញចេញពីសហគមន៍ និងក្រុមគ្រួសារ ដោយសារ "ភាពអាម៉ាស់" ដែលពួកគេទាំងនោះអាចនឹងនាំមកកាន់គ្រួសារព្រោះតែអត្តសញ្ញាណរបស់ពួកគេ។

ទោះបីជារូបភាពនៃក្រុមអ្នកស្រលាញ់ភេទដូចគ្នាកើនឡើងនៅក្នុងតំបន់ទីប្រជុំជននៅកម្ពុជា ប៉ុន្តែការកើនឡើងនេះមិនមានឥទ្ធិពលចំពោះបណ្តាសមាជិកទាំងអស់នៃសហគមន៍ ភ.ជ.ព.ប នោះទេ ដោយសារតែការរើសអើងនៅក្នុងសហគមន៍ទាំងមូលនៅតែបន្ត។ ជាអកុសល បទឧក្រិដ្ឋបង្កដោយភាពស្អប់ខ្ពើម ដោយមូលហេតុនិន្នាការភេទនិងអត្តសញ្ញាណយេនឌ័រ នៅតែជាបញ្ហាចោទសម្រាប់កម្ពុជា។ ថ្វីបើមិនមានទិន្នន័យនៃចំនួនបទឧក្រិដ្ឋបង្កដោយភាពស្អប់ខ្ពើមនៅកម្ពុជាក្តី ប៉ុន្តែ មានរបាយការណ៍ជាច្រើនស្តីពីក្រុមជើងកាងវាយប្រហារលើក្រុម ភ.ជ.ព.ប ដែលប្រមូលផ្តុំនៅសួនច្បារ ក៏ដូចជារបាយការណ៍ស្តីពី "ការរួមភេទដោយបង្ខំ" ជាពិសេសចំពោះក្រុមអ្នកប្តូរភេទ ឬមានសក់វែង ទោះបីជាក្នុងអំឡុងបុណ្យប្រពៃណីក៏ដោយ។ អ្វីដែលគួរឲ្យចាប់អារម្មណ៍គឺថា ពាក្យ "រំលោភ" កម្រត្រូវបានជនរងគ្រោះយកមកប្រើពេលដែលពួកគេរៀបរាប់ពីការវាយប្រហារ[47] ដែលប្រហែលជាបង្ហាញពីទំនោរមួយដែលក្រុម ភ.ជ.ព.ប តែងតែបន្ទោសខ្លួនគេផ្ទាល់ថាជាមូលហេតុនៃបទឧក្រិដ្ឋបង្កដោយភាពស្អប់ខ្ពើមទាំងនោះ។

សំណាងល្អ នៅមិនទាន់ឃើញគំរូ "ការចាប់រំលោភដើម្បីកែប្រែ" ឬ "ការចាប់រំលោភដើម្បីព្យាបាល" នៅកម្ពុជា ជាករណីដែលមនុស្សប្រុសចាប់រំលោភស្ត្រីស្រលាញ់ស្ត្រីដើម្បី "ព្យាបាល" ពួកគេ ដែលជាករណីកើតមានក្នុងប្រទេសមួយចំនួន ដូចជាប្រទេសអាហ្វ្រិកខាងត្បូងនិងចាម៉េកា។[48] មិនតែប៉ុណ្ណោះ កម្ពុជាទទួលបាននូវអត្ថប្រយោជន៍ពីនិយមន័យរួមនៃពាក្យរំលោភសេពសន្ថវៈ នៅក្នុងក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩៖ *"'រំលោភសេពសន្ថវៈ' សំដៅដល់គ្រប់អំពើបញ្ចូលអង្គជាត តាមបែបណាក៏ដោយ ឬ អំពើបញ្ចូលឧបករណ៍ណាមួយទៅក្នុងអង្គជាត ដែលប្រព្រឹត្តទៅលើអ្នកដទៃ ទោះបីជាមានភេទដូចគ្នា ឬមិនដូចគ្នាក៏ដោយ ដោយការប្រើអំពើហិង្សា*

---

[46]ណារី ភីឡៃ "របាយការណ៍ ស.ហ" (ថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១១) ៨។

[47]សិក្ខាសាលារបស់ ម.ស.ម.ក (ភ្នំពេញ ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១១)

[48]អានឧទាហរណ៍ ៖ អង្គការឃ្លាំមើលសិទ្ធិមនុស្ស "'យើងនឹងបង្ហាញអ្នកថាអ្នកគឺជាស្ត្រី' ៖ ហិង្សា និងការរើសអើងមកលើស្ត្រីស្រលាញ់ស្ត្រីស្បែកខ្មៅ និងបុរសប្តូរភេទនៅអាហ្វ្រិកខាងត្បូង' (របាយការណ៍) (ថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០១១) <www.hrw.org/reports/2011/12/05/we-ll-show-you-you-re-woman>។

*ការបង្ខិតបង្ខំ ការគំរាមកំហែង ឬដោយការផ្ទេក់ឱកាស*។[49] និយមន័យរួមនេះ ផ្ទុយពីបណ្ដាប្រទេសមួយចំនួនដែលផ្ដល់និយមន័យឲ្យអំពើរំលោភសេពសន្ថវៈ ឬការយាយីផ្លូវភេទ ក្នុងក្រមព្រហ្មទណ្ឌ គឺត្រឹមតែទទួលស្គាល់អំពើរំលោភសេពសន្ថវៈរបស់បុរសមកលើស្ត្រីប៉ុណ្ណោះ ហើយនិយមន័យរួមនេះ អនុញ្ញាតឲ្យមានការផ្ដន្ទាទោសលើការរំលោភសេពសន្ថវៈ ឬការយាយីផ្លូវភេទមកលើបុរសស្រលាញ់បុរស ឬស្ត្រីប្ដូរភេទផងដែរ។ ទោះជាយ៉ាងណាក៏ដោយ ត្រូវតែមានការធានាថាមន្ត្រីនគរបាល និងប្រព័ន្ធតុលាការកម្ពុជានឹងធ្វើការស៊ើបអង្កេត និងផ្ដន្ទាទោសចំពោះការពោលអះអាងថាមានការយាយីផ្លូវភេទចំពោះក្រុម ភ.ដ.ព.ប។

មានរបាយការណ៍មួយចំនួនក្នុងសារព័ត៌មានថ្នាក់ជាតិនៅកម្ពុជា រាយការណ៍ពីការវាយប្រហារមកលើក្រុម ភ.ដ.ព.ប។ ឧទាហរណ៍ កាលពីខែធ្នូ ឆ្នាំ២០១១ សិស្សនារីមួយក្រុមក្នុងខេត្តបាត់ដំបងបានដាក់ពាក្យបណ្ដឹងប្រឆាំងនឹងមន្ត្រីយោធាជាន់ខ្ពស់មួយរូប ដែលត្រូវបានអះអាងថាបានប្រព្រឹត្តអំពើហិង្សា និងគំរាមចង់សម្លាប់ពួកគេ។ មន្ត្រីរូបនោះ ហើយដែលបានស្លៀកឯកសណ្ឋានយោធានាពេលនោះ ត្រូវបានចោទថាស្រវឹង និងបានបោកក្បាលក្មេងស្រីម្នាក់ទៅនឹងជញ្ជាំង។ មានការសន្និដ្ឋានថាគាត់គិតថាក្មេងស្រីម្នាក់នោះមានទំនាក់ទំនងស្នេហាជាមួយកូនស្រីរបស់លោក។[50]

បន្ថែមពីលើបទឧក្រិដ្ឋបង្កដោយភាពស្អប់ខ្ពើម ក៏មានរបាយការណ៍ជាច្រើនពីសហគមន៍ ភ.ដ.ព.ប កម្ពុជា ស្ដីពីការបំពានដោយអាជ្ញាធរ និងភស្តុតាងនៃការអនុវត្តច្បាប់ និងគោលនយោបាយដោយខុស ព្រោះមានការរើសអើង និងដៅមុខសញ្ញាមកលើក្រុម ភ.ដ.ព.ប។[51] ថ្វីបើមិនមានទិន្នន័យទាំងមូលក្ដី ចំនួនពិតប្រាកដនៃរបាយការណ៍ស្ដីពីការអនុវត្តន៍ច្បាប់ប្រឆាំងនឹងក្រុម ភ.ដ.ព.ប បានបង្ហាញថានេះគឺជាបញ្ហាដ៏សំខាន់ហើយដែលតម្រូវឲ្យមានការដោះស្រាយ។

គោលនយោបាយភូមិឃុំមានសុវត្ថិភាព (គ.ភ.ឃ.ស) ផ្ដោតសំខាន់លើសន្តិសុខ និងសណ្ដាប់ធ្នាប់សាធារណៈ ដែលតម្រូវឲ្យអាជ្ញាធរមូលដ្ឋានបំបាត់ចោលនូវរាល់ទម្រង់នៃបទល្មើសនៅក្នុងភូម និងឃុំ ហើយបញ្ហាជាក់លាក់គឺពាក់ព័ន្ធនឹង ថ្នាំញៀន ពេស្យាចារ ការជួញដូរផ្លូវភេទ អំពើហិង្សាក្នុងគ្រួសារ សកម្មភាពក្រុមជើងកាង ល្បែងស៊ីសងខុសច្បាប់ និងអាវុធខុសច្បាប់។ ប៉ុន្តែ បើពិចារណាតាមការវាយតម្លៃពីថ្នាក់មូលដ្ឋាន គោលនយោបាយនេះត្រូវបានប្រើប្រាស់ដើម្បីគាបសង្កត់ និងគ្រប់គ្រងប្រជាពលរដ្ឋកម្ពុជាក្នុងតំបន់ជនបទ និងទីរួមខេត្ត និងភូមិ ដោយផ្ដល់អំណាចដល់មន្ត្រីនគរបាល និងអាជ្ញាធរមូលដ្ឋានអាចធ្វើការតាមដានលើជីវភាពរស់នៅរបស់ប្រជាពលរដ្ឋកម្ពុជាគ្រប់ពេលវេលា និងដើម្បីចាប់ខ្លួនបុគ្គលដែលគួរឲ្យសង្ស័យដើម្បីជាវិធានការការពារ ដែលនេះគឺជាការរំលោភយ៉ាងធ្ងន់ធ្ងរមកលើសិទ្ធសេរីភាពជាមូលដ្ឋានរបស់ពួកគេ។ មិនតែប៉ុណ្ណោះ យោងតាមការវាយតម្លៃពីបណ្ដាញ ភ.ដ.ព.ប តាមបណ្ដាខេត្ត គ.ភ.ឃ.ស ត្រូវបានប្រើប្រាស់ជាពិសេសដើម្បីដៅមុខសញ្ញាមកលើ ក្រុម ភ.ដ.ព.ប ដែលជាក្រុមងាយរងគ្រោះជាងគេ ព្រោះថាជាញឹកញាប់ពួកគេមិនមានជម្រើស ផ្សេងក្រៅពីទៅប្រមូលផ្ដុំគ្នានៅទីកន្លែងងងឹត ឬមិនសូវមានការចាប់អារម្មណ៍ ដូចជា សួនច្បារដែល

[49]ក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ មាត្រា២៣៩ ៖ និយមន័យការរំលោភសេពសន្ថវៈ។

[50]'មន្ត្រីយោធាវាយប្រហារមកលើសិស្ស' សារព័ត៌មាន ឌឺ ភ្នំពេញប៉ុស្តិ៍ (ភ្នំពេញ ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០១១)

[51]សិក្ខាសាលារបស់ ម.ស.ម.ក (ខេត្តបាត់ដំបង ថ្ងៃទី១៧ ខែមករា ឆ្នាំ២០១២)។

គ្មានពន្លឺភ្លើង ក្នុងគោលបំណងគេចពីចំណាប់អារម្មណ៍របស់ក្រុមគ្រួសារ និងអាជ្ញាធរ។ ដោយសារតែការរើសអើងយ៉ាងរីករាលដាល និងការកំណត់ទុកមុនក្នុងន័យអវិជ្ជមាន អាជ្ញាធរចាត់ទុកថាក្រុម ភ.ដ.ព.ប គឺជាក្រុមអ្នករកស៊ីផ្លូវភេទ ពាក់ព័ន្ធនឹងការទាក់ទងបុរសៗមកប្រើសេវាផ្លូវភេទ និងពេស្យាចារ ដែលជាញឹកញាប់គឺពួកគេគ្រាន់តែជួបជុំគ្នា និងបង្ហាញថាពួកគេជានរណាយ៉ាងបើកចំហរ ក្នុងអាកប្បកិរិយាដែលមិនសំញែងតាមដែលពួកគេអាចធ្វើទៅបាន។

ការព្រួយបារម្ភដ៏សំខាន់ចុងក្រោយ ចំពោះ គ.ភ.ឃ.ស គឺថានេះមិនមែនជានីតិកម្មដែលត្រូវបានដដែកពិភាក្សា និងអនុម័តនៅក្នុងរដ្ឋសភានោះទេ ប៉ុន្តែគ្រាន់តែជាបញ្ញត្តនីតិប្រតិបត្តិចេញដោយក្រសួងមហាផ្ទៃ និងជាទូទៅចេញដោយរដ្ឋាភិបាល។ បន្ថែមពីលើនេះ គ.ភ.ឃ.ស ផ្ទុយនឹងច្បាប់កម្ពុជា ដូចជាច្បាប់គ្រប់គ្រងថ្នាំញៀន ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ និងក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ និងបានកាត់បន្ថយសិទ្ធិសេរីភាពដែលធានានៅក្នុងរដ្ឋធម្មនុញ្ញ និងអនុសញ្ញាអន្តរជាតិដែលរដ្ឋាភិបាលបានចុះសច្ចាប័ន។[52] ឧទាហរណ៍បន្ថែមស្ដីពីការប្រើប្រាស់ច្បាប់ដោយបំពាននៅកម្ពុជាដែលប្រឆាំង និងរំលោភលើសិទ្ធិរបស់ក្រុម ភ.ដ.ព.ប រួមមាន ច្បាប់គ្រប់គ្រងថ្នាំញៀន ដែលបានពិភាក្សាក្នុង ផ្នែក ៣.១ ខាងលើ និងច្បាប់ស្ដីពីការទប់ស្កាត់អំពើជួញដូរ និងកេងប្រវញ្ចផ្លូវភេទ ឆ្នាំ២០០៨ (ច្បាប់ទប់ស្កាត់ការជួញដូរផ្លូវភេទ) ដែលបានពិភាក្សាបន្ថែមនៅក្នុងផ្នែក ៣.៧។ ការរាយការណ៍ពីមូលដ្ឋានបង្ហាញថា ច្បាប់ទាំងពីរនេះត្រូវបានប្រើប្រាស់ដោយកំណត់មុខសញ្ញាមកលើក្រុម ភ.ដ.ព.ប ជាពិសេស និងដើម្បីបំបាត់ពួកគេចេញពីកន្លែងសាធារណៈ។

វិធីមួយដើម្បីបំបាត់នូវការប្រើប្រាស់ច្បាប់ដោយបំពាន គឺត្រូវរៀបចំនូវវគ្គបណ្ដុះបណ្ដាល និងកម្មវិធីដើម្បីឲ្យមានការយល់ចិត្ត សម្រាប់ក្រុមមន្ត្រីនគរបាល និងមន្ត្រីអនុវត្តច្បាប់ដទៃទៀតនៅកម្ពុជា។ ប្រសិនបើមិនដូច្នោះទេ ក្នុងករណីដែលក្រុម ភ.ដ.ព.ប ទទួលរងការរើសអើងនៅក្នុងផ្ទះ ហើយពួកគេថែមទាំងមិនអាចគេចផុតពីការរើសអើងនៅក្រៅផ្ទះទៀត ដែលជាទូទៅតែងតែរងនូវលទ្ធផលអាក្រក់ជាងនៅក្នុងផ្ទះ ពួកគេប្រាកដជាគ្មានកន្លែងណាដែលពួកគេអាចទៅ និងបង្ហាញថាពួកគេជានរណាយ៉ាងបើកចំហរបាននោះទេ។ វគ្គបណ្ដុះបណ្ដាលទាំងនោះត្រូវបានផ្ដល់ជាអនុសាសន៍នៅក្នុងឯកសារ។ ឧទាហរណ៍ របាយការណ៍ ស.ហ ដែលផ្ដល់ជាអនុសាសន៍ថា ប្រទេសទាំងអស់ "*គួរតែអនុវត្តនូវកម្មវិធីឲ្យមានការយល់ចិត្ត និងវគ្គបណ្ដុះបណ្ដាល សម្រាប់មន្ត្រីនគរបាល មន្ត្រីពន្ធនាគារ មន្ត្រីល្បាតព្រំដែន មន្ត្រីអន្តោប្រវេសន៍ និងភ្នាក់ងារអនុវត្តច្បាប់ដទៃទៀត និងដើម្បីគាំទ្រនូវយុទ្ធនាការផ្ដល់ព័ត៌មានជាសាធារណៈ ដើម្បីទប់ស្កាត់នឹងភាពរើសអើងចំពោះអ្នកស្រលាញ់ភេទដូចគ្នា និងការរើសអើងចំពោះអ្នកប្ដូរភេទ ក្នុងចំណោមសាធារណជនទូទៅ និង [គាំទ្រ] នូវយុទ្ធនាការប្រឆាំងនឹងការរើសអើងចំពោះអ្នកស្រលាញ់ភេទដូចគ្នានៅក្នុងសាលារៀនគោលដៅ*"។[53]

កម្មវិធីបែបនេះបង្ហាញថាអាចមានប្រសិទ្ធភាពខ្ពស់នៅកម្ពុជា និងអាចជួយលុបបំបាត់នូវការព្រួយបារម្ភរបស់ក្រុម ភ.ដ.ព.ប ដែលថាពួកគេអាចនឹងត្រូវបានដៅជាមុខសញ្ញាដោយភ្នាក់ងារអនុវត្តច្បាប់។ ស.ហ បាន

---

[52] "ការធ្វើចំណាត់ថ្នាក់ច្បាប់របស់ ម.ស.ម.កៈ គោលនយោបាយភូមិឃុំមានសុវត្ថិភាព" (សលាកប័ត្រព័ត៌មាន)(ខែមករា ឆ្នាំ២០១២)
<www.cchrcambodia.org/index_old.php?url=media/media.php&p=factsheet_detail.php&fsid=27&id=5>។

[53]ណាវី ភីឡៃ "របាយការណ៍ ស.ហ" (ថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១១) ២៥។

កត់សម្គាល់ថា រដ្ឋជាសមាជិកមួយចំនួនបានបង្កើតនូវកម្មវិធីបណ្តុះបណ្តាល សម្រាប់មន្ត្រីអនុវត្តច្បាប់ដើម្បីបង្ហាញឲ្យពួកគេឃើញ និងយល់ពីបញ្ហានៃអំពើហិង្សាមកលើក្រុម ភ.ជ.ព.ប និងជួយឲ្យពួកគេទទួលស្គាល់ទទួលដឹង និងឆ្លើយតបយ៉ាងសមស្របទៅនឹងការរាយការណ៍នៃបទល្មើសទាំងនេះ។ ឧទាហរណ៍ មូលនិធិអ្នករកស៊ីផ្លូវភេទ (ម.អ.ផ.ស) នៅក្នុងប្រទេសថៃបានចូលរួមក្នុង "កម្មវិធីសហគមន៍ភ្ជាប់ទំនាក់ទំនងជាមួយនិស្សិតនគរបាល"។ កម្មវិធីនេះផ្តល់ឱកាសឲ្យនិស្សិតនគរបាលឆ្នាំទីបី ដើម្បីចុះធ្វើជាកម្មសិក្សាការីជាមួយនឹង ម.អ.ផ.ស ដោយមានទស្សនគតិដើម្បីផ្លាស់ប្តូរវប្បធម៌ដែលពួកគេមានជាទូទៅ តាមរយៈការអប់រំមន្ត្រីនគរបាលជំនាន់ថ្មី អំពីបញ្ហាដែលក្រុមបុរសស្រលាញ់បុរសជាអ្នករកស៊ីផ្លូវភេទក្នុងប្រទេសថៃបានប្រឈម។ ក្នុងរយៈពេលចុងក្រោយនៃការចុះកម្មសិក្សា និស្សិតនគរបាលនោះត្រូវតែធ្វើបទបង្ហាញទៅដល់និស្សិតទាំងអស់នៅក្នុងសាលានគរបាលដើម្បីបន្តផ្សព្វផ្សាយសារដែលពួកគេបានទទួល។[54]

ទោះជាយ៉ាងណាក៏ដោយ វគ្គបណ្តុះបណ្តាល និងកម្មវិធីដើម្បីឲ្យមានការយល់ចិត្ត សម្រាប់មន្ត្រីអនុវត្តច្បាប់នេះ មិនគួរជាការរារាំងនូវតម្រូវការឲ្យមានកម្មវិធី និងសកម្មភាពដែលបន្តធ្វើការតាមដាន និងចុះស្រាវជ្រាវករណីនៃបទឧក្រិដ្ឋបង្កដោយភាពស្អប់ខ្ពើម និងទម្រង់ដទៃនៃអំពើហិង្សាដែលប៉ះពាល់លើសហគមន៍ ភ.ជ.ព.ប នោះទេ។ នៅក្នុងសហរដ្ឋអាមេរិក កម្មវិធីជាតិចម្រុះប្រឆាំងនឹងអំពើហិង្សា ធ្វើការដើម្បីការពារ ឆ្លើយតបទៅនឹង និងបញ្ឈប់រាល់ទម្រង់នៃអំពើហិង្សាលើ សហគមន៍ ភ.ជ.ព.ប និងអ្នកផ្ទុកមេរោគអេដស៍។ កម្មវិធីជាតិចម្រុះប្រឆាំងនឹងអំពើហិង្សានេះ គឺជាកម្មវិធីជាតិចម្រុះនៃ កម្មវិធីរបស់សមាជិកក្នុងស្រុក អង្គការ និងបុគ្គលដែលពាក់ព័ន្ធ ដែលមានបំណងឲ្យមានការផ្លាស់ប្តូរក្នុងសង្គម និងជាប្រព័ន្ធ។[55] ពួកគេបានខិតខំធ្វើការបង្កើនអំណាចសុវត្ថិភាព និងធនធានតាមរយៈការវិភាគទិន្នន័យ តស៊ូមតិលើគោលនយោបាយ ផ្តល់ជំនួយអប់រំ និងបច្ចេកទេស។ កម្មវិធីជាតិចម្រុះនេះបានបោះពុម្ពផ្សាយនូវរបាយការណ៍ ឆ្នាំ២០១១ ចំណងជើងថា *"អំពើហិង្សាដោយការស្អប់ខ្ពើម ប្រឆាំងនឹងសហគមន៍ស្ត្រីស្រលាញ់ស្ត្រី បុរសស្រលាញ់បុរស អ្នកស្រលាញ់ទាំងពីរភេទ អ្នកប្តូរភេទ អ្នករួមភេទដូចគ្នា និងអ្នកផ្ទុកមេរោគអេដស៍ នៅសហរដ្ឋអាមេរិក ឆ្នាំ២០១០"*[56] ដែលផ្តល់ព័ត៌មានលម្អិតពីបទល្មើសបែបហិង្សាមកលើ ក្រុម ភ.ជ.ព.ប និងដើម្បីផ្តល់អនុសាសន៍ដល់សង្គមស៊ីវិល និងរដ្ឋាភិបាលសហរដ្ឋអាមេរិកក្នុងការឆ្លើយតបចំពោះបទល្មើសទាំងនោះ។ កម្ពុជាផ្ទាល់ក៏អាចទទួលបាននូវអត្ថប្រយោជន៍ពីការសិក្សាបែបនេះដោយគ្មានការសង្ស័យ ក្នុងលក្ខខណ្ឌនៃការកាត់បន្ថយនូវបទឧក្រិដ្ឋបង្កដោយភាពស្អប់ខ្ពើមមកលើក្រុម ភ.ជ.ព.ប។

នៅប្រទេសហ្វីលីពីន អ្នកឃ្លាំមើលបទឧក្រិដ្ឋបង្កដោយភាពស្អប់ខ្ពើមមកលើក្រុម ភ.ជ.ព.ប បង្កើតដោយសហព័ន្ធនៃអង្គការ និងបុគ្គលដែលធ្វើការដើម្បីបញ្ឈប់បុរេវិនិច្ឆ័យប្រឆាំងនឹងក្រុម ភ.ជ.ព.ប អនុញ្ញាតឲ្យ

---

[54] 'ធ្វើឲ្យសត្រូវក្លាយទៅជាមិត្តៈ កម្មវិធីផ្តល់កម្មសិក្សារបស់ ម.អ.ផ.ស ដល់និស្សិតនគរបាលស្តីពីការការពារមេរោគអេដស៍ក្នុងចំណោមអ្នករកស៊ីផ្លូវភេទ (អង្គការផេក អត្ថបទបន្ទាន់សម័យ)<www.pactworld.org/cs/reach_news_and_media_swing_story>។

[55]កម្មវិធីជាតិចម្រុះប្រឆាំងនឹងអំពើហិង្សា 'អំពីយើង' <http://ncavp.org/about/default.aspx>។

[56]កម្មវិធីជាតិចម្រុះប្រឆាំងនឹងអំពើហិង្សា 'អំពើហិង្សាបង្កដោយភាពស្អប់ខ្ពើមមកលើ សហគមន៍ស្ត្រីស្រលាញ់ស្ត្រី បុរសស្រលាញ់បុរស អ្នកស្រលាញ់ទាំងពីរភេទ អ្នកប្តូរភេទ អ្នករួមភេទដូចគ្នានៅសហរដ្ឋអាមេរិក ឆ្នាំ២០១០' (ឆ្នាំ២០១១) <http://avp.org/documents/NCAVPHateViolenceReport2011Finaledjlfinaledits.pdf>។

ប្រជាពលរដ្ឋរាយការណ៍ពីករណីនៃបទឧក្រិដ្ឋ ឬករណីបង្កដោយភាពស្អប់ខ្ពើមតាមរយៈទម្រង់ដែលនៅលើវែបសាយរបស់ពួកគេ។[57] ស្របជាមួយនឹងការតស៊ូមតិជាបន្តបន្ទាប់ និងការងារផ្នែកនីតិកម្ម និងការផ្តួចផ្តើមដែលអាចអនុវត្តបាន ដូចជា កម្មវិធីបណ្តុះបណ្តាលមន្ត្រីនគរបាល និងកម្មវិធីធ្វើឲ្យមានការយល់ចិត្ត សកម្មភាពបែបនេះអាចដើរតួជា "អ្នកឃ្លាំមើល" ដើម្បីធានាថាករណីបទឧក្រិដ្ឋបង្កដោយភាពស្អប់ខ្ពើមនឹងមិនកើនឡើង។

វិធីមួយទៀតដើម្បីជួយលើកកម្ពស់ការយល់ដឹង ស្តីពីសិទ្ធិរបស់ក្រុម ភ.ដ.ព.ប គឺឲ្យបុគ្គល សហគមន៍ បណ្តាញ អង្គការ និងសង្គមស៊ីវិលដទៃទៀត ធ្វើការលើបញ្ហា ភ.ដ.ព.ប មានគំនិតច្នៃប្រឌិត និងបង្កើតឲ្យមានការផ្តួចផ្តើមក្នុងសហគមន៍ដ៏គួរឲ្យចាប់អារម្មណ៍ ដើម្បីគាំទ្រនូវសកម្មភាពទាំងនោះ។ ឧទាហរណ៍ ម.ស.ម.ក បានច្នៃម៉ូត និងផលិត "ក្រមា" ឥន្ទធនូក្រមាគឺត្រូវបានប្រើតាំងពីបុរមបុរាណ និងជាអត្តសញ្ញាណជាតិកម្ពុជា ហើយបច្ចុប្បន្នត្រូវបានដាក់លក់នៅគ្រប់កន្លែង ទាំងកន្លែងវប្បធម៌ និងសង្គមនៅទីក្រុងភ្នំពេញ និងក្នុងខេត្តសៀមរាប។ មិនតែប៉ុណ្ណោះ ម.ស.ម.ក ក៏មានគម្រោងពង្រីកការលក់ខ្នាតអន្តរជាតិនៅក្នុងអនាគតខាងមុខ ដើម្បីលើកកម្ពស់ការយល់ដឹងអំពីការរំលោភបំពានលើសិទ្ធិរបស់ក្រុម ភ.ដ.ព.ប ជួយគាំទ្រដល់ជនរងគ្រោះ និងបង្កើនការគោរពចំពោះក្រុម ភ.ដ.ព.ប ជាទូទៅ។

**អនុសាសន៍សម្រាប់រដ្ឋាភិបាល ៖ ធានាថាការពោលអះអាងថាមានអំពើហិង្សាមកលើក្រុម ភ.ដ.ព.ប រួមទាំងការយាយីផ្លូវភេទ ត្រូវបានស៊ើបអង្កេត និងផ្តន្ទាទោសយ៉ាងត្រឹមត្រូវ។**

**អនុសាសន៍សម្រាប់រដ្ឋាភិបាល/រដ្ឋសភា ៖ បង្កើតច្បាប់ប្រឆាំងនឹងបទឧក្រិដ្ឋបង្កដោយការស្អប់ខ្ពើម ដែលការពារជាពិសេសមកលើក្រុម ភ.ដ.ព.ប។**

**អនុសាសន៍សម្រាប់រដ្ឋាភិបាល/រដ្ឋសភា ៖ ធ្វើការពិភាក្សាលើ គ.ភ.យ.ស ឲ្យបានពេញលេញ និងមានតម្លាភាពនៅក្នុងរដ្ឋសភា និងអនុម័តគោលនយោបាយនេះទៅជាច្បាប់យ៉ាងល្អមួយ។**

**អនុសាសន៍សម្រាប់រដ្ឋាភិបាល ៖ បង្កើតនូវសេចក្តីណែនាំពីការអនុវត្តន៍ គ.ភ.យ.ស ដើម្បីឲ្យអាជ្ញាធរអាចអនុវត្តតាមយ៉ាងច្បាស់លាស់។ សេចក្តីណែនាំនេះគឺសម្រាប់មន្ត្រីអនុវត្តច្បាប់ ក៏ប៉ុន្តែក៏ដើរតួជាសេចក្តីណែនាំសម្រាប់ក្រុម ភ.ដ.ព.ប សហគមន៍របស់ពួកគេ និងសាធារណជនទូទៅផងដែរ ដើម្បីឲ្យប្រជាពលរដ្ឋទាំងអស់អាចដឹងពីសិទ្ធិរបស់ ក្រុម ភ.ដ.ព.ប។**

**អនុសាសន៍សម្រាប់សង្គមស៊ីវិល និង រដ្ឋាភិបាល ៖ បើកវគ្គបណ្តុះបណ្តាល និងអនុវត្តកម្មវិធីធ្វើឲ្យមានការយល់យោគគ្នា ទៅដល់ភ្នាក់ងារអនុវត្តច្បាប់ និងធានាឲ្យមានមូលនិធិ ជាតិសម្រាប់កម្មវិធីប្រឆាំងអំពើហិង្សាថ្នាក់មូលដ្ឋាន ដើម្បីធានាឲ្យមានការយល់ដឹងដែលប្រសើរឡើង រវាងភ្នាក់ងារអនុវត្តច្បាប់ និងក្រុម ភ.ដ.ព.ប។**

**អនុសាសន៍សម្រាប់សង្គមស៊ីវិល និងរដ្ឋាភិបាល ៖ បង្កើតនូវប្រព័ន្ធតាមដានបទឧក្រិដ្ឋបង្កដោយភាពស្អប់ខ្ពើមនៅកម្ពុជា។**

---

[57] 'តើអ្វីជាអ្នកឃ្លាំមើលបទឧក្រិដ្ឋបង្កដោយភាពស្អប់ខ្ពើមរបស់ហ្វីលីពីន?' (អ្នកឃ្លាំមើលបទឧក្រិដ្ឋបង្កដោយភាពស្អប់ខ្ពើមហ្វីលីពីន ថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០១១) <http://thephilippinelgbthatecrimewatch.blogspot.com/2011/09/philippine-lgbt-hate-crime-watch.html>។

**អនុសាសន៍សម្រាប់សង្គមស៊ីវិល និងរដ្ឋាភិបាល ៖ បង្កើតនូវកម្មវិធីលើកកម្ពស់ការយល់ដឹង រួមបញ្ចូលទាំងការយល់ដឹងស្តីពី ក្រុម ភ.ដ.ព.ប និងសិទ្ធិរបស់ពួកគេ និងគាំទ្រការលើកកម្ពស់ និងការចែកចាយក្រមាឥន្ទធនូ ដើម្បីរៃអង្គាសមូលនិធិសម្រាប់គាំទ្រជនរងគ្រោះនៃការរំលោភបំពានសិទ្ធិមនុស្ស។**

## ៤.៦. ការអប់រំ

មាត្រា៤៨ នៃរដ្ឋធម្មនុញ្ញធានានូវសិទ្ធិទទួលបានការអប់រំសម្រាប់កុមារទាំងអស់ ៖ *"រដ្ឋធានាការពារសិទ្ធិរបស់កុមារ ដែលមានចែងក្នុងអនុសញ្ញាស្តីពីកុមារ ជាពិសេស សិទ្ធិ [...] ទទួលការអប់រំរៀនសូត្រ [...]។ រដ្ឋគាំពារប្រឆាំងនឹងការងារទាំងឡាយ ដែលអាចធ្វើឲ្យខូចដល់ការអប់រំ និងការរៀនសូត្ររបស់កុមារ ឬដែលនាំឲ្យអន្តរាយដល់សុខភាព ឬសុខុមាលភាពរបស់កុមារ"។*

ដើម្បីអនុវត្តតាមបញ្ញត្តិរដ្ឋធម្មនុញ្ញមួយនេះ រដ្ឋាភិបាលបានបង្កើតនូវគោលនយោបាយ និងយុទ្ធសាស្ត្រជាច្រើន ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ក្នុងគោលបំណងផ្តល់ឲ្យបានស្មើភាពគ្នានូវលទ្ធភាពទទួលបានការអប់រំ ។ ឧទាហរណ៍ ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឆ្នាំ២០០៩ - ២០១៣ ដែលអនុម័តក្នុងឆ្នាំ២០១០ បានសង្កត់ធ្ងន់លើ *"ការធានាថាកុមារ និងយុវជនកម្ពុជាទាំងអស់មានឱកាសស្មើគ្នាដើម្បីទទួលបានការអប់រំជាមូលដ្ឋាន ទាំងផ្លូវការ និងក្រៅផ្លូវការ ដោយគ្មានការរើសអើងដោយផ្អែកលើមូលដ្ឋាន ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា និន្នាការនយោបាយរបស់ឪពុកម្តាយ ទីកន្លែងកំណើត និងឋានៈក្នុងសង្គម"។*[58] ជាអកុសល ផែនការយុទ្ធសាស្ត្រទាំងនេះ និងឯកសារគោលនយោបាយដទៃទៀតបានខកខានមិនបានបញ្ជាក់ច្បាស់ពីនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រជាពិសេស ថ្វីបើមានការចង្អុលបង្ហាញយ៉ាងច្បាស់ថាក្រុមយុវជន ភ.ដ.ព.ប តែងទទួលរងការរើសអើងក្នុងសាលា ទាំងនៅកម្ពុជា និងនៅជុំវិញពិភពលោក។ រដ្ឋធម្មនុញ្ញក៏ដូចជា ស.ប.ស.អ និន្នាការភេទ និងអត្តសញ្ញាណយេនឌ័រគួរតែត្រូវបានបញ្ចូលទៅក្នុងគ្រប់បញ្ជីនៃមូលដ្ឋានដែលហាមឃាត់មិនឲ្យមានការរើសអើង។

យោងតាម ក្រសួងអប់រំ យុវជន និងកីឡា ចំនួន ១៩.៦ភាគរយនៃសិស្សទាំងអស់ក្នុងថ្នាក់អនុវិទ្យាល័យ (ថ្នាក់ទី៧ ដល់ទី៩) បោះបង់ការរៀនសូត្រក្នុងអំឡុងឆ្នាំសិក្សា ២០១០ - ២០១១។[59] ទោះបីជាមិនមានការសិក្សាណាមួយអះអាងពីមូលហេតុដែលនាំឲ្យសិស្សបោះបង់ការសិក្សាដ៏ច្រើនបែបនេះ ឬក៏ពីមូលហេតុថាតើអត្រានេះមានពាក់ព័ន្ធនឹងការនិយាយបង្អាប់ដោយការរើសអើង ប៉ុន្តែភស្តុតាងខ្លីៗដែលប្រមូលបានតាមរយៈការចុះស្រាវជ្រាវរបស់ ម.ស.ម.ក នៅក្នុងខេត្តសៀមរាបកាលពីខែមករា ឆ្នាំ២០១២ បានបង្ហាញថាអត្រាបោះបង់ការសិក្សាមានកម្រិតខ្ពស់ជាពិសេស ក្នុងចំណោមយុវជន ភ.ដ.ព.ប។ ក្នុងអំឡុងនៃការសម្ភាសន៍ក្នុងខេត្តសៀមរាប សិស្សបានផ្តល់នូវមូលហេតុផ្សេងៗពាក់ព័ន្ធនឹងការបោះបង់ការសិក្សា រួមទាំងថាពួកគេមិនត្រឹមតែលំបាកផ្នែកជីវភាពដែលកើតចេញ ពីការមិនទទួលស្គាល់ពីក្រុមគ្រួសារ ថែមទាំងមានការហៅឈ្មោះ ឬការនិយាយបង្អាប់លេងសើចពីមិត្តរួមថ្នាក់ចំពោះភេទរបស់ពួកគេផងដែរ។

---

[58]ក្រសួងអប់រំ យុវជន និងកីឡា របស់រដ្ឋាភិបាល 'ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឆ្នាំ២០០៩ -២០១៣' (ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១០)។

[59]ក្រសួងអប់រំ យុវជន និងកីឡា 'ស្ថិតិ និងសូចនាករអប់រំ ២០១០ -២០១១'(ខែមិនា ឆ្នាំ២០១១)
<http://moeys.gov.kh/km/component/joomdoc/doc_download/32-education-statistics-and-indicators2010-2011-kh.html>

ស.ហ បានទទួលស្គាល់ថា ការនិយាយបង្អាប់លេងសើច មកលើសិស្ស ភ.ដ.ព.ប គឺជាបញ្ហាធ្ងន់ធ្ងរកម្រិតពិភពលោក និងបានបង្កជាការគំរាមកំហែងមកលើសិទ្ធិទទួលបានការអប់រំដែលជាសិទ្ធិសាកលជាមូលដ្ឋាន ហើយដូច្នេះក្នុងខែធ្នូ ឆ្នាំ២០១១ ស.ហ បានរៀបចំនូវកិច្ចពិគ្រោះយោបល់លើកដំបូងដើម្បីកាត់បន្ថយនូវការនិយាយបង្អាប់លេងសើចមកលើសិស្ស ភ.ដ.ព.ប។ ការនិយាយបង្អាប់លេងសើច មិនត្រឹមតែនាំឲ្យមានការបោះបង់ការសិក្សាឆាប់ ប៉ុន្តែក៏នាំឲ្យមានការបាក់ទឹកចិត្ត អាកប្បកិរិយាចង់សម្លាប់ខ្លួន និងបង្កគ្រោះថ្នាក់ ដូចជាប្រើប្រាស់ថ្នាំញៀន និងការរួមភេទដោយមិនបានការពារផងដែរ។[60]

ក្នុងទិវាអន្តរជាតិប្រឆាំងនឹងការរើសអើង ភ.ដ.ព.ប ឆ្នាំនេះ គឺថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១២ អង្គការសហប្រជាជាតិស្តីពីការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ (យូណេស្កូ) បានផ្តួចផ្តើមនូវយុទ្ធនាការអន្តរជាតិដើម្បីកាត់បន្ថយនូវការនិយាយបង្អាប់លេងសើចមកលើសិស្ស ភ.ដ.ព.ប ដោយប្រមូលផ្តុំនូវភ្នាក់ងារជំនាញ ស.ហ បុគ្គលិកអង្គការ មន្ត្រីរដ្ឋាភិបាល និងក្រុមបញ្ញវន្ត ពីជុំវិញពិភពលោកដើម្បីចែករំលែកបទពិសោធន៍ និងកំណត់នូវបទពិសោធន៍អនុវត្តដែលទទួលបានលទ្ធផលល្អបំផុតសម្រាប់លុបបំបាត់ការនិយាយបង្អាប់លេងសើច។ ជាលទ្ធផល គឺការបោះពុម្ពផ្សាយ "ការឆ្លើយតបរបស់វិស័យអប់រំមកលើការនិយាយបង្អាប់លេងសើចដោយការរើសអើងចំពោះអ្នកស្រលាញ់ភេទដូចគ្នា"[61] បានផ្តល់កម្លាំងជំរុញចិត្តដល់ដៃគូសង្គមស៊ីវិល ក៏ដូចជា យូណេស្កូ និងរដ្ឋាភិបាល ដើម្បីខិតខំប្រឹងប្រែងឲ្យមានការអនុម័តការផ្តួចផ្តើមនេះនៅកម្ពុជា។ មានសកម្មភាពល្អៗជាច្រើនទៀតនៅជុំវិញពិភពលោក ត្រូវបានចងក្រងជាឯកសារដោយ យូណេស្កូ ដែលស្ថាប័ននៅកម្ពុជាអាចយកធ្វើជាឯកសារយោងបាន។ គំរូដ៏ជោគជ័យមួយគឺ "ការផ្តួចផ្តើមប្រទេសប្រេស៊ីលគ្មានការរើសអើងលើអ្នកស្រលាញ់ភេទដូចគ្នា" សម្ពោធឆ្នាំ២០០៤ ដែលបានចាប់ផ្តើមពីការធ្វើសន្និសិទ្ធជាបន្តបន្ទាប់ដើម្បីផ្តួចផ្តើមនូវកិច្ចសន្ទនាជាទូទៅអំពីការរើសអើងមកលើអ្នកស្រលាញ់ភេទដូចគ្នា និងដើម្បីសម្របសម្រួលនូវការធ្វើការជាមួយគ្នារវាងរដ្ឋ និងសង្គមស៊ីវិល។[62]ការផ្តួចផ្តើមនេះ គឺភាពជាដៃគូរវាងអង្គការសង្គមស៊ីវិល និងរដ្ឋាភិបាលប្រេស៊ីលដែលមានក្រុមយុវជនចូលរួមក្នុងការផ្តួចផ្តើមនេះផងដែរ។ អង្គការសង្គមស៊ីវិល គឺជាអ្នកអនុវត្តចម្បងដែលមានរៀបចំនូវវគ្គបណ្តុះបណ្តាលសម្រាប់គ្រូបង្រៀនស្តីពី យេនឌ័រ និងការរើសអើង ផ្តល់ជំនួយដល់យុវជនដែលចេញជាចំហរ បង្កើតនូវយុទ្ធវិធីរួមដើម្បីកាត់បន្ថយអាកប្បកិរិយាអវិជ្ជមានចំពោះក្រុម ភ.ដ.ព.ប និងបង្កើតគោលនយោបាយដ៏ទូលំទូលាយសម្រាប់សាលា ដោយពាក់ព័ន្ធនឹងសន្តិសុខ និងពលរដ្ឋ។ ការផ្តួចផ្តើមនេះបានរីឡូទៅជាដេប៉ាតឺម៉ង់ដែលអាចផ្គត់ផ្គង់ថវិកាដោយខ្លួនឯង ដូចជា កម្មវិធីមួយមានចំណងជើងថា "សាលារៀនដែលគ្មានភាពរើសអើងប្រឆាំងនឹងអ្នកស្រលាញ់ភេទដូចគ្នា"។

---

[60]ភីតធី ហ្គ័រដេន 'ការពិនិត្យឡើងវិញនូវការនិយាយបង្អាប់លេងសើចក្នុងវិទ្យាស្ថានអប់រំ' (របាយការណ៍ឧបត្ថម្ភដោយ យូណេស្កូ និងរៀបចំសម្រាប់កិច្ចពិភាក្សាថ្នាក់អន្តរជាតិនៅទីក្រុងរីអូ ដឺ ចេនីរ៉ូ ប្រទេស ប្រេស៊ីល ថ្ងៃទី ៦ -៩ ខែធ្នូ ឆ្នាំ២០១១ បោះពុម្ពឆ្នាំ២០១២) <http://unesdoc.unesco.org/images/0021/002157/215708e.pdf>។

[61]អាចអានបាន ៖ www.unesco.org/new/en/education/themes/leading-the-international-agenda/our-priorities-in-health-education/homophobic-bullying/។

[62]ភីតធី ហ្គ័រដេន 'ការពិនិត្យឡើងវិញនូវការនិយាយបង្អាប់លេងសើចក្នុងវិទ្យាស្ថានអប់រំ' (ឆ្នាំ២០១២) ២៨។

បទពិសោធន៍អនុវត្តល្អៗក៏ត្រូវបានបង្ហាញដោយ ស្តូនវ៉ល (Stonewall) អង្គការមានទីតាំងនៅចក្រភពអង់គ្លេស ចាប់ផ្តើមក្នុងឆ្នាំ១៩៨៩ ដើម្បីធ្វើការតវ៉ាប្រឆាំងនឹង ផ្នែកទី២៨ នៃច្បាប់រដ្ឋាភិបាលក្នុងស្រុក ជាផ្នែកមួយនៃច្បាប់ដែលមានបំណងរារាំងនូវអ្វីដែលអ្នកបង្កើតច្បាប់ហៅថា "ការលើកកម្ពស់" ការស្រលាញ់ភេទដូចគ្នានៅតាមសាលារៀន។[63]សកម្មភាពមួយក្នុងចំណោមសកម្មភាពដែលបង្កើតឡើងដើម្បីកាត់បន្ថយការប្រើពាក្យបង្អាប់ដោយការរើសអើងក្នុងសាលា ស្តូនវ៉ល ក៏បានបង្កើតនូវប្រភពធនធានយ៉ាងសម្បូរបែប ដែលគ្រូបង្រៀនអាចស្នើសុំដើម្បីប្រើប្រាស់ក្នុងសាលារៀន និងថ្នាក់រៀន ដែលរួមមាន ផ្ទាំងរូបភាពផ្សព្វផ្សាយ ប្រៃសណីយ៍ប័ត្រ និងស្ទីកគ័រ ក៏ដូចជា គោលការណ៍ណែនាំសម្រាប់គ្រូអំពីរបៀបរួមបញ្ចូលក្រុម ភ.ជ.ព.ប ទៅក្នុងកាលវិភាគសិក្សា និងជីវិតនៅក្នុងសាលាជាទូទៅផងដែរ។[64] ប្រភពធនធានត្រូវបានបង្កើតជាពិសេសសម្រាប់ការអប់រំក្នុងកម្រិតផ្សេងៗ និងអាចបង្កើតសម្រាប់ប្រើប្រាស់ក្នុងបរិបទប្រទេសកម្ពុជាដើម្បីអនុវត្តនូវការផ្តួចផ្តើមអស់ទាំងនោះនៅកម្ពុជា។

ប្រហាក់ប្រហែលគ្នានេះដែរ ក្នុងសហរដ្ឋអាមេរិក យុទ្ធនាការសាលារៀនដែលស្វាគមន៍ ជាគម្រោងនៃយុទ្ធនាការសិទ្ធិមនុស្ស ដែលជាអង្គការមានទីតាំងនៅសហរដ្ឋអាមេរិក ដែលធ្វើការតស៊ូមតិដើម្បីសិទ្ធិរបស់ក្រុម ភ.ជ.ព.ប បង្ហាញពីវិធីសាស្ត្រដែលរាប់បញ្ចូល រួមមានឧបករណ៍ មេរៀន និងធនធាន ក្នុងគោលបំណងបញ្ចូលនូវភាពចម្រុះក្នុងក្រុមគ្រួសារ ចៀសវាងការកំណត់ទុកមុនចំពោះយេនឌ័រ និងបញ្ចប់នូវការបង្អាប់លេងសើច និងការហៅឈ្មោះ ក្នុងសាលាបឋមសិក្សា។ គម្រោងបានសាកល្បងដំបូងនៅក្នុងសាលារៀនមួយចំនួនដែលត្រូវបានជ្រើសរើស ហើយក្រោយមកក៏បានធ្វើការវាយតម្លៃដើម្បីកំណត់ពីប្រសិទ្ធភាពនៃកម្មវិធីក្នុងការសម្រេចបាននូវគោលបំណងរបស់កម្មវិធី។ អ្វីដែលសំខាន់ជាងនេះទៅទៀត ការវាយតម្លៃបានសន្និដ្ឋានថាកម្មវិធីទទួលបានប្រសិទ្ធភាពជាពិសេស ក្នុងការកំណត់ថាកុមារទាំងអស់នឹងទទួលបានផលប្រយោជន៍ពីការជជែកពិភាក្សាពីតួនាទីយេនឌ័រ និងការបង្ហាញខ្លួនរបស់ពួកគេ និងបង្កើនសមត្ថភាពរបស់គ្រូក្នុងការពិភាក្សាប្រធានបទទាំងនេះ។[65]

ការផ្តួចផ្តើមដែលទទួលបានជោគជ័យមួយទៀត ដែលបានសាកល្បងក្នុងប្រទេសកម្ពុជាហើយនោះ គឺការបង្កើតក្រុមពិភាក្សា លើប្រធានបទ ភ.ជ.ព.ប នៅតាមសាកលវិទ្យាល័យ។ ម.ស.ម.ក បានសម្របសម្រួលសិក្ខាសាលាបែបនោះ ដើម្បីលើកយកបញ្ហា ភ.ជ.ព.ប ទៅក្នុងផ្នែកសំខាន់នៃជីវិតរបស់សិស្ស ៖ សិស្ស ដែលជា ភ.ជ.ព.ប ក៏មានលាយឡំក្នុងក្រុមសិស្សទាំងអស់នោះដែរ ចំណែកវាគ្មិនមានទាំងសកម្មជន ភ.ជ.ព.ប និង ភ.ជ.ព.ប សាមញ្ញដែលត្រូវបានអញ្ជើញដើម្បីបង្ហាញអំពីបទពិសោធន៍របស់ពួកគេ។[66] សិក្ខាសាលាបែបនេះ គឺជាឱកាសដ៏ល្អក្នុងការបង្កើតបរិស្ថានដែលមានលក្ខណៈមិត្តភាពចំពោះ ក្រុម ភ.ជ.ព.ប ក្នុងសាលារៀន និង

---

[63]ស្តូនវ៉ល 'អំពីយើង' <www.stonewall.org.uk/about_us/2532.asp>។

[64]ប្រភពធនធានផ្នែកអប់រំរបស់ស្តូនវ៉ល អាចអានបាន ៖ http://www.stonewall.org.uk/at_school/education_resources/default.asp។

[65]យុទ្ធនាការសិទ្ធិមនុស្ស 'គម្រោងសាកល្បង*សាលារៀនដែលស្វាគមន៍* និងលទ្ធផលនៃការវាយតម្លៃ' (ខែកក្កដា ឆ្នាំ២០១០) <www.welcomingschools.org/2012/03/evaluation-of-welcoming-schools/>។

[66]សិក្ខាសាលារបស់ ម.ស.ម.ក (សកលវិទ្យាល័យបៀលប្រាយ ភ្នំពេញ ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១១)។

ដើម្បីបង្កើតនូវការយោគយល់ និងការយល់ដឹងស្តីពីក្រុម ភ.ដ.ព.ប ជីវិតរបស់ពួកគេ សិទ្ធិរបស់ពួកគេ និងបញ្ហាប្រឈមដែលពួកគេជួបប្រទះក្នុងជីវភាពប្រចាំថ្ងៃ។

ការផ្តួចផ្តើម និងគំនិតទាំងអស់នេះអាចបង្ហាញជាទិសដៅសម្រាប់កម្ពុជា ដើម្បីកាត់បន្ថយនូវការនិយាយបង្អាប់ដោយរើសអើង។ ឧទាហរណ៍ ភាគីអ្នកពាក់ព័ន្ធមួយក្រុមអាចនឹងចាប់ផ្តើមធ្វើការស្រាវជ្រាវ នាំយកគំនិតពីការប្រតិបត្តិល្អៗមកពីអន្តរជាតិ និងដើម្បីបង្កើតនូវសកម្មភាពដើម្បីកាត់បន្ថយនូវការនិយាយបង្អាប់ដោយការរើសអើងនៅកម្ពុជា។

**អនុសាសន៍សម្រាប់រដ្ឋាភិបាល/ក្រសួងអប់រំ យុវជន និងកីឡា ៖ បញ្ចូលនូវការលើកឡើងស្តីពី និន្នាការភេទ និងអត្តសញ្ញាណយេនឌ័រទៅក្នុងផែនការយុទ្ធសាស្ត្រ និងគោលនយោបាយក្នុងពេលអនាគត។**

**អនុសាសន៍សម្រាប់រដ្ឋាភិបាល និងសង្គមស៊ីវិល ៖ ចាប់ផ្តើមធ្វើការស្ទង់មតិដើម្បីកំណត់ពីកម្រិតដែលក្រុមយុវជន ភ.ដ.ព.ប បោះបង់ការសិក្សា និងមូលហេតុនៃការបោះបង់ការសិក្សា ដើម្បីបង្កើតនូវគោលនយោបាយដែលអាចកាត់បន្ថយនូវមូលហេតុទាំងនោះ។**

**អនុសាសន៍សម្រាប់សង្គមស៊ីវិល ៖ រៀបចំប្រជុំក្រុមការងាររបស់អង្គការសង្គមស៊ីវិល យូណេស្កូ និងក្រសួងអប់រំ យុវជន និងកីឡា ដើម្បីបង្កើត យុទ្ធនាការ "ប្រឆាំងនឹងការនិយាយបង្អាប់ដោយការរើសអើងក្នុងសាលារៀន" នៅកម្ពុជា និងដើម្បីបង្កើតនូវប្រភពធនធានសម្រាប់គ្រូ ដើម្បីប្រើប្រាស់ក្នុងថ្នាក់រៀន។**

**អនុសាសន៍សម្រាប់រដ្ឋាភិបាល/ក្រសួងអប់រំ យុវជន និងកីឡា និង សង្គមស៊ីវិល ៖ ដើម្បីបង្កើតនូវការអប់រំទាក់ទងនឹងនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ ទៅក្នុងកម្មវិធីសិក្សា ជាតិ និងធានាថាកម្មវិធីសិក្សានេះយកចិត្តទុកដាក់ចំពោះជីវភាពការរស់នៅរបស់ក្រុម ភ.ដ.ព.ប នៅកម្ពុជា។**

## ៤.៧. ការងារ

ការរើសអើងប្រឆាំងនឹង ក្រុម ភ.ដ.ព.ប នៅកន្លែងការងារនៅតែបន្តជារឿងធម្មតានៅជុំវិញពិភពលោក ទោះបីជាមានកាតព្វកិច្ចក្នុងច្បាប់សិទ្ធិមនុស្សអន្តរជាតិ ដែលទទួលស្គាល់ដោយរដ្ឋាភិបាល ដើម្បីការពារក្រុម ភ.ដ.ព.ប ពីការរើសអើងដែលពាក់ព័ន្ធនឹងលទ្ធភាពទទួលបាន និងការថែរក្សាការងារ រួមទាំង ការទទួលស្គាល់ និងការផ្តល់សិទ្ធិការងារដល់បុគ្គលទាំងឡាយនៅពេលដែលពួកគាត់ទទួលបានការងារធ្វើ។ គ.ស.ស.ស.វ បានបញ្ជាក់ថា គណៈកម្មាធិការបាន "*បានហាមឃាត់ការរើសអើងចំពោះលទ្ធភាពទទួលបាន និងការថែរក្សាការងារដែលផ្អែកលើមូលដ្ឋាននៃ…និន្នាការភេទ*"។[67]ការរើសអើងក្នុងលក្ខខណ្ឌការងារត្រូវបានហាមឃាត់បន្ថែមទៀត

[67]គណៈកម្មការអង្គការសហប្រជាជាតិស្តីពីស.ស.ស.វ "មតិយោបល់លេខ១២ ក្នុង 'សេចក្តីអធិប្បាយលេខ១៨៖ សិទ្ធិក្នុងការទទួលបានការងារ (មាត្រា៦ នៃ ក.អ.ស.ស.ស.វ)'(ថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០០៦) ឯកសាររបស់អង្គការសហប្រជាជាតិE/C.12/GC/18 <http://www2.ohchr.org/english/bodies/cescr/comments.htm>។

ដោយអនុសញ្ញានៃអង្គការពលកម្មអន្តរជាតិ ស្តីពីការលុបបំបាត់ការរើសអើងពាក់ព័ន្ធនឹងការងារ និងអាជីព ដែលចុះសច្ចាប័នដោយកម្ពុជា ឆ្នាំ១៩៩៩។[68]

ច្បាប់ជាតិ ក៏មានសារៈសំខាន់ក្នុងការការពារ សិទ្ធិក្រុម ភ.ដ.ព.ប ក្នុងកន្លែងធ្វើការផងដែរ បច្ចុប្បន្ន ប្រទេសចំនួន ៥២ បានអនុម័តច្បាប់ដើម្បីហាមឃាត់ការរើសអើងដោយផ្អែកលើនិន្នាការភេទ និងអត្តសញ្ញាណ យេនឌ័រក្នុងបរិបទការងារ។[69] ប៉ុន្តែ ច្បាប់ការងារកម្ពុជា អនុម័តឆ្នាំ ១៩៩៧ ខកខានមិនបានលើកឡើងយ៉ាង ច្បាស់ស្តីពីនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ ថាជាមូលដ្ឋានដែលការរើសអើងត្រូវបានហាមឃាត់។ មាត្រា ១២ ចែងពីសមភាពនៅកន្លែងធ្វើការ ប៉ុន្តែមិនបានការពារយ៉ាងបើកចំហរ និងយ៉ាងមានប្រសិទ្ធភាពចំពោះក្រុម ភ.ដ.ព.ប នោះទេ។ បន្ថែមពីលើនោះ ការអនុវត្តន៍ច្បាប់ដែលពាក់ព័ន្ធនឹងការងារ ដូចជាច្បាប់ទប់ស្កាត់ការជួញ ដូរផ្លូវភេទ ដែលមើលបានធ្វើឲ្យកន្លែងរកស៊ីផ្លូវភេទ ដែល ភ.ដ.ព.ប កំពុងធ្វើការត្រូវបានបិទក្នុងឆ្នាំ២០០៨ នេះផ្តល់ឥទ្ធិពលអវិជ្ជមានដែលមិនសមាមាត្រមកលើក្រុម ភ.ដ.ព.ប។ ស្របពេលមានការអះអាងថាការបង្កើត ច្បាប់បែបនេះផ្តល់ផលល្អ ប៉ុន្តែ អ្នករកស៊ីផ្លូវភេទដែលជា ភ.ដ.ព.ប ត្រូវបង្ខំចិត្តធ្វើការនៅតាមផ្លូវ និងពាក់ព័ន្ធ នឹងសកម្មភាពបទឧក្រិដ្ឋដើម្បីឧបត្ថម្ភខ្លួនឯង ដោយសារតែពួកគេត្រូវបានដកហូតនូវប្រាក់ចំណូល ដែលជា លទ្ធផលនៃការអនុវត្តន៍ច្បាប់នេះ។

ទោះបីជាមិនមានការសិក្សាជាផ្លូវការ ទៅលើលទ្ធភាពទទួលបាន និងការថែរក្សាការងារ របស់ ក្រុម ភ. ដ.ព.ប នៅកម្ពុជាក៏ដោយ ប៉ុន្តែការសិក្សារបស់អង្គការសុខភាពគ្រួសារអន្តរជាតិ ឆ្នាំ២០០០ ស្តីពីការរាលដាល នៃមេរោគអេដស៍ និងមេរោគឆ្លងតាមរយៈការរួមភេទដទៃទៀត ក្នុងចំណោម បុរសរួមភេទជាមួយបុរស នៅទី ក្រុងភ្នំពេញ បានរាយការណ៍ថាភាពគ្មានការងារធ្វើក្នុងចំណោម ក្រុមបុរសដែលរួមភេទជាមួយបុរស គឺមាន កម្រិតខ្ពស់ខ្លាំងណាស់ ប្រហែលពាក់កណ្តាលនៃអ្នកចូលរួមស្ទង់មតិនិយាយថាពួកគេគ្មានការងារធ្វើ។[70]ទោះបី ជារបាយការណ៍នោះមានចំណាស់ប្រហែលជាមួយទស្សវត្សរ៍ហើយក៏ដោយ មានការចង្អុលបង្ហាញតិចតួច ណាស់ដែលបង្ហាញថាស្ថានភាពមានការផ្លាស់ប្តូរបន្ទាប់ពីការសិក្សានោះ ហើយនៅតែអាចប្រើប្រាស់ជាឯកសារ យោងដ៏សំខាន់ពាក់ព័ន្ធនឹងភាពគ្មានការងារធ្វើរបស់ក្រុម ភ.ដ.ព.ប នៅកម្ពុជា។ ឆ្លងតាមសិក្ខាសាលា និងបទ សម្ភាសន៍ជាច្រើនដែលរៀបចំឡើងដោយ ម.ស.ម.ក ជាមួយនឹង ភ.ដ.ព.ប នៅទូទាំងប្រទេសកម្ពុជា មានភស្តុ តាងបង្ហាញថា ភាគច្រើននៃ ភ.ដ.ព.ប មានការលំបាកក្នុងការស្វែងរក និងរក្សាការងាររបស់ពួកគេ។

ក្រុម ភ.ដ.ព.ប ជាញឹកញាប់តែងតែរងការបណ្តេញចេញ ការយាយី ការហៅឈ្មោះ (ឧទាហរណ៍ "ខ្ទើយ" ដែលជាពាក្យខ្មែរប្រើសម្រាប់ប្រមាថម៉ាក់ងាយសំដៅដល់ក្រុមអ្នកប្តូរភេទ) និងការនិយាយបង្អាប់លេង សើចនៅកន្លែងធ្វើការ ដែលជាទូទៅនាំឲ្យឈានទៅរកការតប់ប្រមល់ និងការលំបាកផ្នែកសេដ្ឋកិច្ច។ បុរស

---

[68]កតិកាសញ្ញាស្តីពីការរើសអើងក្នុងវិស័យការងារ និងអាជីព (អនុម័តថ្ងៃទី២៥ ខែមិថុនា ឆ្នាំ១៩៥៨ ចូលជាធរមាននៅថ្ងៃទី១៥ ខែមិថុ នា ឆ្នាំ១៩៦០) អង្គការពលកម្មអន្តរជាតិC111 www.ilo.org/ilolex/cgi-lex/convde.pl?C111។

[69]សមាគមអ្នកស្រលាញ់ភេទដូចគ្នា អ្នកស្រលាញ់ភេទទាំងពីរ អ្នកប្តូរភេទ និងអន្តរភេទ 'ការរើសអើងប្រឆាំងនឹងការស្រលាញ់ភេទដូច គ្នាឧបត្ថម្ភដោយរដ្ឋ' (ឆ្នាំ២០១២) ១៥។

[70]អង្គការសុខភាពគ្រួសារអន្តរជាតិ 'អាកប្បកិរិយាភេទ មេរោគឆ្លង និងមេរោគអេដស៍ក្នុងចំណោមបុរសដែលរួមភេទជាមួយបុរសក្នុង ភ្នំពេញ កម្ពុជា ឆ្នាំ២០០០' (ឆ្នាំ២០០០) ៦។

ស្រលាញ់បុរសសញ្ជាតិកម្ពុជាម្នាក់ បានរាយការណ៍មក ម.ស.ម.ក ថានៅពេលដែលគាត់បើកចំហរពីភេទរបស់គាត់នៅកន្លែងការងារ ការនិយាយបង្អាប់ដោយការរើសអើងគឺមានសភាពធ្ងន់ធ្ងររហូតដល់គាត់ត្រូវបង្ខំចិត្តត្រូវចាកចេញពីការងារ។ ក្រុម ភ.ដ.ព.ប ជាញឹកញាប់ត្រូវលាក់អត្តសញ្ញាណរបស់ខ្លួននៅពេលដែលពួកគេធ្វើការ។ ស្ត្រីស្រលាញ់ស្ត្រីសញ្ជាតិកម្ពុជាម្នាក់និយាយប្រាប់ ម.ស.ម.ក ថា *"ទោះបីជាមិត្តភក្តិដទៃទៀតស្លៀកពាក់ដូចជាមនុស្សប្រុសក៏ដោយ ប៉ុន្តែនាងស្លៀកពាក់ជាស្រី ដោយសារតែនាងត្រូវការស្វែងរកការងារ និងរកលុយ"*។ បុរស និងស្ត្រីដែលជាអ្នកប្តូរភេទបានរាយការណ៍ថាពួកគេតែងតែត្រូវបានបដិសេធនៅពេលដាក់ពាក្យសុំធ្វើការ រួមទាំងហាងអាហារ និងរោងចក្រ ព្រោះតែរូបរាងរបស់ពួកគេ ទោះបីជាពួកគេបញ្ចប់បរិញ្ញាប័ត្រក៏ដោយ។ ពេលខ្លះពួកគេត្រូវបានបង្ខំចិត្តឲ្យទៅធ្វើការនៅក្នុងឧស្សាហកម្មផ្តល់សេវាផ្លូវភេទដោយសារតែចង់បានការងារពេក។

ជាអកុសលមានការព្យាយាមបន្តិចបន្តួចប៉ុណ្ណោះត្រូវបានធ្វើឡើងនៅប្រទេសកម្ពុជា ដើម្បីពិភាក្សាពីបញ្ហានិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ ជាមួយនិយោជក រួមមានទាំង ស្ថាប័នរដ្ឋដូចជាស្ថាប័នយោធា នគរបាល នីតិបញ្ញត្ត និងប្រព័ន្ធតុលាការ ឬជាមួយនឹងសមាគមនិយោជក និងសហជីព។ ភាពអសកម្មបែបនេះកើតឡើងជាច្រើនដោយសារបញ្ហាដទៃផ្សេងទៀតក្នុងវិស័យការងារ ដូចជា សិទ្ធិទទួលបានប្រាក់បៀវត្សរ៍ដោយស្មើភាព ដែលសំខាន់ជាងបញ្ហា ភ.ដ.ព.ប។ ប៉ុន្តែ ភាពធ្ងន់ធ្ងរនៃការរើសអើងផ្អែកលើនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ នៅកន្លែងធ្វើការ និងភាពខ្វះខាតផ្នែកជីវភាពដែលភាពរើសអើងនឹងបង្កឲ្យមានចំពោះក្រុម ភ.ដ.ព.បមានន័យថានេះគឺជាពេលដ៏ស័ក្តិសមបំផុតដែលការប្រឹងប្រែង និងការផ្តួចផ្តើមដ៏សមស្របត្រូវបានបង្កើតឡើងពាក់ព័ន្ធនឹងបញ្ហានេះ។ វិធីមួយដែលអាចធ្វើទៅបានសម្រាប់ ក្រុម ភ.ដ.ព.ប នៅក្នុងកម្ពុជា គឺការពិតដែលថាការរីកចម្រើនផ្នែកសេដ្ឋកិច្ចនៅកម្ពុជា នឹងនាំឲ្យមានការបង្កើនឱកាសដើម្បីធ្វើការជាមួយក្រុមហ៊ុនអន្តរជាតិ ដែលភាគច្រើនផ្តោតការយកចិត្តទុកដាក់ទៅលើទំនួលខុសត្រូវផ្នែកសង្គម សិទ្ធិពលករ និងសិទ្ធិមនុស្សជាទូទៅ រួមមានទាំងយកចិត្តទុកដាក់ចំពោះការរើសអើងដោយផ្តោតមកលើនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រក្នុងកន្លែងធ្វើការ។

នៅថ្នាក់អន្តរជាតិ មានបទពិសោធន៍អនុវត្តល្អៗ ក្នុងការការពារសិទ្ធិរបស់ ក្រុម ភ.ដ.ព.ប និងលើកសរសើរនូវភាពចម្រុះក្នុងកន្លែងការងារ។ ឧទាហរណ៍ នៅសហរដ្ឋអាមេរិក យុទ្ធនាការសិទ្ធិមនុស្ស បានធ្វើការជាមួយក្រុមហ៊ុនទំហំធំៗនៅក្នុងសហរដ្ឋអាមេរិក ដើម្បីឲ្យមានការគោរពចំពោះក្រុម ភ.ដ.ព.ប ដោយផ្តល់ការកោតសរសើរដល់ប្រទេស ចំនួន៣៣៧ ក្នុងបញ្ជីឆ្នាំ២០១២ ថាជា "ទីកន្លែងល្អបំផុតដែលមានសមភាពក្នុងកន្លែងធ្វើការសម្រាប់ ភ.ដ.ព.ប" ("បញ្ជី ភ.ដ.ព.ប")។[71] មិនត្រឹមតែប៉ុណ្ណោះ យុទ្ធនាការសិទ្ធិមនុស្សបានបោះពុម្ពផ្សាយនូវ "របាយការណ៍សមភាពក្នុងសាជីវកម្ម" ដែលចាត់ចំណាត់ថ្នាក់ក្រុមហ៊ុនរបស់សហរដ្ឋអាមេរិកធំៗដោយផ្អែកលើថាតើគោលនយោបាយ និងអត្ថប្រយោជន៍មានលក្ខណៈមិត្តភាពដល់ ក្រុម ភ.ដ.ព.ប ឬក៏អត់។ ក្រុមហ៊ុនដែលត្រូវបានផ្តល់ចំណាត់ថ្នាក់ ១០០% គឺត្រូវបានទទួលស្គាល់ក្នុង បញ្ជី ភ.ដ.ព.ប និងជាលទ្ធផលត្រូវបានអញ្ជើញឲ្យដាក់ពាក្យស្នើសុំ "រង្វាន់ការបង្កើតថ្មីចំពោះកន្លែងធ្វើការដែលមានសមភាព" ដែលទទួល

[71]សីលា ហ្សាយ៉ន 'ការចាត់ចំណាត់ថ្នាក់កន្លែងការងាររបស់ ក្រុម ភ.ដ.ព.ប បង្ហាញថាមានការប្រសើរឡើងក្នុងសាជីវកម្មអាមេរិក' (ប្រែនឆាណែល ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១១)<www.brandchannel.com/home/post/2011/12/19/HRC-2012-Corporate-Equality-Index-121911.aspx>។

ស្គាល់នូវក្រុមហ៊ុនណាដែលបានអនុវត្តលើសពីបទពិសោធន៍អនុវត្តល្អបំផុតក្នុងពេលបច្ចុប្បន្នពាក់ព័ន្ធនឹងគោលនយោបាយ ភ.ដ.ព.ប។[72]

នៅប្រទេសហ្វីលីពីនគណបក្សឡាឡាត (ឡាឡាត: Ladladដែលមានន័យថា "ចេញជាចំហរ" ជាភាសាតាកាឡុក)ទើបតែត្រូវបានទទួលស្គាល់ជាផ្លូវការដោយតុលាការកំពូលថាជា គណបក្សនយោបាយរបស់ក្រុម ភ.ដ.ព.ប ហើយដែលកំពុងរៀបចំនូវការផ្តួចផ្តើមក្នុងកម្រិតជាតិ និងសហគមន៍ ក្នុងគោលបំណងធ្វើឲ្យជីវិតរបស់ក្រុម ភ.ដ.ព.ប កាន់តែប្រសើរឡើង រាប់បញ្ចូលទាំង ផ្នែកការងារផងដែរ។ បន្ថែមពីលើការជំរុញសម្រាប់ការណែនាំជាថ្មីម្តងទៀតអំពី ច្បាប់ប្រឆាំងនឹងការរើសអើង ឡាឡាត ក៏បានបង្កើតគម្រោងមីក្រូហិរញ្ញវត្ថុ និងជីវភាពចិញ្ចឹមជីវិត សម្រាប់ក្រុម ភ.ដ.ព.ប ដែលក្រីក្រ និង/ឬ ពិការ។[73]

មានការផ្តួចផ្តើមជាច្រើនដែលអាចធ្វើទៅបាននៅកម្ពុជាក្នុងរយៈពេលនេះ។ គម្រោង ធុរកិច្ច និងសិទ្ធិមនុស្សរបស់ ម.ស.ម.ក[74]("គម្រោងធុរកិច្ច និងសិទ្ធិមនុស្ស") បានតាមដានរោងចក្រកាត់ដេរនៅកម្ពុជា លើកឡើងពីការរំលោភបំពានលើសិទ្ធិមនុស្សនៅកម្ពុជាដែលពាក់ព័ន្ធនឹង ក្រុម ភ.ដ.ព.ប ឬនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រ (ក្នុងចំណោមបញ្ហាដទៃទៀត) និងការប្រឹងប្រែងដើម្បីបញ្ចូលបញ្ហារបស់ ភ.ដ.ព.ប ទៅក្នុងកិច្ចសន្ទនាជាមួយក្រុមអ្នកជំនួញ លើកកម្ពស់នូវឧទាហរណ៍នៃកម្មវិធីដែលត្រូវបានសាកល្បងក្នុងប្រទេសដទៃតាមរយៈជាឧទាហរណ៍។ គម្រោងធុរកិច្ច និងសិទ្ធិមនុស្ស ក៏ផ្តល់នូវសេចក្តីណែនាំពីវិធីសាស្ត្រដែលសមរម្យ រួមទាំងវិធីសាស្ត្រដែលទាន់ពេលវេលា អំពីរបៀបដើម្បីពិចារណានូវសិទ្ធិរបស់ក្រុមដែលមិនត្រូវបានគេរាប់បញ្ចូល រួមទាំងក្រុម ភ.ដ.ព.ប។

**អនុសាសន៍សម្រាប់រដ្ឋាភិបាល/រដ្ឋសភា៖ កែទម្រង់ច្បាប់ការងារ រួមទាំងបទប្បញ្ញត្តដើម្បីការពារប្រជាពលរដ្ឋពីការរើសអើងដោយផ្អែកលើនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័ររបស់ពួកគេ។**

**អនុសាសន៍សម្រាប់សង្គមស៊ីវិល៖ អំពាវនាវឲ្យនិយោជកឲ្យគោរពសិទ្ធិដល់ក្រុមភាគតិចផ្នែកភេទ ដោយគោរពតាមច្បាប់ការងារ និងច្បាប់ដទៃទៀតដែលពាក់ព័ន្ធដែលការពារ និងលើកកម្ពស់សិទ្ធិរបស់ក្រុម ភ.ដ.ព.ប ក្នុងសកម្មភាពប្រចាំថ្ងៃ និងដោយបញ្ចូលនូវគោលការណ៍និន្នាការភេទ និងអត្តសញ្ញាណយេនឌ័រទៅក្នុងគោលការណ៍ផ្ទៃក្នុង។**

**អនុសាសន៍សម្រាប់សង្គមស៊ីវិល៖ បង្កើតនូវគោលការណ៍និន្នាការភេទ និងអត្តសញ្ញាណយេនឌ័រទៅក្នុងសកម្មភាពកាន់តែទូលាយជាងនេះជាមួយនឹងនិយោជក និងសមាគមនិយោជក រួមទាំងសកម្មភាពធុរកិច្ច និងសិទ្ធិមនុស្ស។**

---

[72]យុទ្ធនាការសិទ្ធិមនុស្ស សន្ទស្សន៍សមភាពក្នុងសាជីវកម្ម<www.hrc.org/corporate-equality-index/#.ULXYBIZe-Ys>។

[73]ផាទ្រីក យីង ប៉ាស្កាល់ 'ឡាឡាត អនុម័ត 'បើកចិត្ត បើកបេះដូង' ជាពាក្យស្លោកយុទ្ធនាការថ្មី' (វើរ៉ា ហ្វាល់ ថ្ងៃទី២១ ខែមេសា ឆ្នាំ ២០១២)<http://ph.news.yahoo.com/blogs/the-inbox/ladlad-adopts-open-mind-open-heart-campaign-slogan-091949933.html>។

[74]មើល ម.ស.ម.ក 'គម្រោងធុរកិច្ច និងសិទ្ធិមនុស្ស' <www.cchrcambodia.org/index_old.php?url=project_page/project_page.php&p=project_profile.php&id=3&pro=BHRP&show=show>។

**អនុសាសន៍សម្រាប់សង្គមស៊ីវិល ៖ ផ្ដល់អំណាចសម្រាប់ ក្រុម ភ.ជ.ព.ប តាមរយៈការលើកកម្ពស់ការយល់ដឹងនៃ សិទ្ធិរបស់ពួកគេនៅកន្លែងធ្វើការ និងធានាថាការផ្ដួចផ្ដើមទាំងនេះត្រូវបានបង្កើតឡើងក្នុងគំរូដែលមាននិរន្តភាព។**

## ៤.៨. សេវាសុខភាព

សិទ្ធទទួលបានសេវាសុខភាព និងសិទ្ធិមិនត្រូវរងការរើសអើងក្នុងវិស័យសុខាភិបាលត្រូវបានចងក្រងជាឯកសារទុកក្នុងច្បាប់អន្តរជាតិ។ អ្វីដែលសំខាន់ជាងនេះទៅទៀត គ.ស.ស.ស.វ បានសម្រេចសេចក្ដីថា មាត្រា១២ (១) នៃ ក.អ.ស.ស.ស.វ ចែងថាភាគីរដ្ឋគួរតែ "*ទទួលស្គាល់សិទ្ធិបុគ្គលគ្រប់រូបដើម្បីឲ្យពួកគេអាចទទួលបាននូវបទដ្ឋានដែលអាចទទួលបានខ្ពស់បំផុតនៃសេវាសុខភាពទាំងផ្នែករូបរាងកាយ និងផ្នែកផ្លូវចិត្ត*" បន្ថែមពីនោះទៀត "*ប្រកាសហាមឃាត់រាល់ការរើសអើងពាក់ព័ន្ធនឹងលទ្ធភាពទទួលបានសេវាសុខភាព និងការកំណត់ពីសុខភាពដែលមានពីកំណើត ក៏ដូចជាមធ្យោបាយ និងការផ្ដល់សិទ្ធិសម្រាប់ការទទួលបានរបស់ពួកគេដោយផ្អែកលើមូលដ្ឋាន ... និន្នាការភេទ*"។[75] ចំពោះកម្ពុជា មាត្រា៧២ នៃរដ្ឋធម្មនុញ្ញចែងថា "*សុខភាពរបស់ប្រជារាស្ត្រត្រូវបានធានា។ រដ្ឋយកចិត្តទុកដាក់ដល់ការការពារជំងឺ និងការព្យាបាលជំងឺ។ ប្រជារាស្ត្រក្រីក្រគួរតែទទួលបានការពិនិត្យរោគដោយឥតបង់ថ្លៃនៅតាមមន្ទីរពេទ្យ គិលានដ្ឋាន និងមន្ទីរសម្ភពសាធារណៈ*"។ ថ្វីបើមានចំណុចនេះ និងតម្រូវការផ្នែកច្បាប់អន្តរជាតិដទៃក្នុងការផ្ដល់នូវសេវាសុខភាពដែលស្មើភាពដោយមិនគិតពីនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រក៏ដោយ ក៏ការរើសអើងក្នុងសេវាសុខភាពមកលើក្រុម ភ.ជ.ព.ប នៅតែមានច្រើននៅកម្ពុជា។

ខណៈពេលដែលការកាត់បន្ថយនូវលទ្ធភាពទទួលបានសេវាសុខភាព នៅតែជាបញ្ហាស្រួចស្រាវនៅក្នុងប្រទេសដែលចាត់ទុកថាការស្រលាញ់ភេទដូចគ្នាជាបទល្មើសព្រហ្មទណ្ឌ[76]ដូច្នេះលទ្ធផលនៃការបិទបាំងនូវនិន្នាការភេទរបស់បុគ្គលម្នាក់គឺមានគ្រោះថ្នាក់យ៉ាងខ្លាំង[77] ហើយដែលមានការខ្វះខាតនូវការបណ្ដុះបណ្ដាល

---

[75]គណៈកម្មការអង្គការសហប្រជាជាតិស្ដីពីស.ស.ស.វ "មតិយោបល់លេខ១៨ ក្នុង 'សេចក្ដីអធិប្បាយលេខ១៤៖ បញ្ហាអចិន្ត្រៃយ៍កើតឡើងក្នុងពេលអនុវត្តនូវ ក.អ.ស.ស.ស.វ'(ថ្ងៃទី១១ ខែសីហា ឆ្នាំ២០០០) ឯកសាររបស់អង្គការសហប្រជាជាតិ E/C.12/2000/4 <www2.ohchr.org/english/bodies/cescr/comments.htm>។

[76]សមាគមអ្នកស្រលាញ់ភេទដូចគ្នា អ្នកស្រលាញ់ភេទទាំងពីរ អ្នកប្ដូរភេទ និងអន្តរភេទ 'ការរើសអើងប្រឆាំងនឹងការស្រលាញ់ភេទដូចគ្នាឧបត្ថម្ភដោយរដ្ឋ'២៣។

[77]ឧទាហរណ៍ សភាអ៊ូហ្គង់ដាបានកំពុងតែពិចារណានូវ ច្បាប់ប្រឆាំងនឹងការស្រលាញ់ភេទដូចគ្នា ឈ្មោះហៅក្រៅ "ច្បាប់សម្លាប់អ្នកស្រលាញ់ភេទដូចគ្នា" ដែលអាចធ្វើឲ្យទណ្ឌកម្មសម្រាប់សកម្មភាពស្រលាញ់ភេទដូចគ្នាកាន់តែធ្ងន់ធ្ងរឡើង អនុវត្តនូវទោសជាប់ពន្ធនាគារមួយជីវិតសម្រាប់អ្នករៀបការជាមួយភេទដូចគ្នា និងបង្ខំឲ្យប្រជាពលរដ្ឋ "ប្រកាសថ្កោលទោស" នូវជនដែលសង្ស័យថាប្រព្រឹត្តសកម្មភាពស្រលាញ់ភេទដូចគ្នា តាមរយៈការពិន័យ និងដាក់ពន្ធនាគារចំពោះអ្នកដែលមិនព្រមប្រកាសថ្កោលទោសលើជនសង្ស័យ។ ច្បាប់នេះក៏អាចនឹងអនុវត្តនូវទោសប្រហារជីវិតសម្រាប់ សកម្មភាព "ដែលមានស្ថានទម្ងន់ទោស" ផងដែរ។ មើល សែនថូរ៉ុន រ៉ាជ 'សេចក្ដីស្រលាញ់មិនស័ក្តិសមទទួលនូវការស្លាប់នោះទេ' (អង្គការលើកលែងទោសអន្តរជាតិអូស្ត្រាលី ថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០១២) <www.amnesty.org.au/features/comments/30655/>។ ច្បាប់នេះនឹងកាន់តែធ្វើឲ្យស្ថានភាពដែលកំពុងតែមានគ្រោះថ្នាក់កាន់តែធ្ងន់ធ្ងរទៅ ៖ ក្នុងខែមករា ឆ្នាំ២០១១ ដាវីត កាតូ សកម្មជនដ៏ឆ្នើមទាមទារសិទ្ធិ ភ.ជ.ព.ប ដែលទទួលស្គាល់ដោយមនុស្សជាច្រើនថាជាស្ថាបនិកនៃ ចលនាសិទ្ធិ ភ.ជ.ព.បដែលកំពុងចាប់កំណើតក្នុងប្រទេស ត្រូវបានសម្លាប់យ៉ាងឃោរឃៅ បន្ទាប់ពីទទួលបានការគំរាមកំហែងសម្លាប់ជាច្រើនលើកច្រើនសារ និងក្លាយជាមុខសញ្ញានៃសារព័ត៌មានអ៊ូហ្គង់ដា។ មើល ៖ ជេហ្វរី ហ្គេថលមែន 'ជនជាតិអ៊ូហ្គង់ដា

សមស្របសម្រាប់អ្នកអាជីពផ្នែកវេជ្ជសាស្ត្រចំពោះបញ្ហាដែល ក្រុម ភ.ដ.ព.បជួបប្រទះដោយ ជាលទ្ធផលនាំឲ្យមានការរើសអើងកើនឡើង និងកង្វះខាតលទ្ធភាពទទួលបានសេវាសុខភាព។[78] ការរើសអើង ទោះបីជាជាក់ស្តែង ឬគ្រាន់តែជាការគិតក៏ដោយ តែងតែមានន័យថា ក្រុម ភ.ដ.ព.ប នឹងមិនមានអារម្មណ៍ងាយស្រួល ឬអាចនឹងបង្ហាញពីនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័ររបស់ពួកគេទៅកាន់អ្នកផ្តល់សេវាសុខភាពដែរ។[79] ប៉ុន្តែដើម្បីឲ្យប្រជាពលរដ្ឋទទួលបានការពិនិត្យរោគនិងការព្យាបាលយ៉ាងសមស្រប ជាពិសេស មេរោគអេដស៍ និងមេរោគដែលឆ្លងតាមការរួមភេទ (មេរោគឆ្លង) ក្រុម ភ.ដ.ព.ប តម្រូវឲ្យអាចបើកចំហរ និងស្មោះត្រង់ពីនិន្នាការភេទ និងអាកប្បកិរិយា ជាមួយនឹងអ្នកអាជីពផ្នែកសេវាសុខភាព ដោយមិនខ្លាចថាមានការរើសអើង។ បន្ថែមពីលើនោះ យោងតាមរបាយការណ៍ របស់ ការិយាល័យឧត្តមស្នងការសហប្រជាជាតិ បានកត់សម្គាល់ថា ជាពិសេស អ្នកប្តូរភេទមានការលំបាកជាខ្លាំងក្នុងការទទួលនូវសេវាសុខភាពយ៉ាងសមស្រប ដោយសារតែ "*ការព្យាបាលប្តូរភេទ នៅកន្លែងដែលមានមានសេវានេះ តែងតែជាឧបសគ្គសម្រាប់ពួកគាត់ដោយសារតែតម្លៃថ្លៃ ហើយការគាំទ្រថវិកាដោយរដ្ឋ ឬការគ្របដណ្តប់ដោយក្រុមហ៊ុនធានារ៉ាប់រងមិនសូវមាននោះទេ។ សេវាសុខភាពជាលក្ខណៈអាជីពតែងតែមានតិចតួចណាស់សម្រាប់តម្រូវការរបស់អ្នកប្តូរភេទ និងការខ្វះខាតការបណ្តុះបណ្តាលជាលក្ខណៈអាជីពដែលចាំបាច់*"។[80] ស្ត្រីស្រលាញ់ស្ត្រីក៏មានគ្រោះថ្នាក់ដែលមិនសមមាត្រផងដែរ ៖ ការយល់ខុសដែលរីករាលដាលមួយថាមេរោគអេដស៍នឹងមិនឆ្លងរវាងស្ត្រីនិងស្ត្រី ហើយដែលអ្នកជំនាញផ្នែកសុខភាពបន្តពូជស្ត្រីគឺផ្តោតលើតែការការពារកំណើត និងស្ត្រីមានផ្ទៃពោះតែម្យ៉ាង នាំឲ្យស្ត្រីស្រលាញ់ស្ត្រីចំនួនតិចណាស់ដែលទៅទទួលការត្រួតពិនិត្យសេវាសុខភាពប្រចាំឆ្នាំ ដែលអាចរកឃើញនូវមេរោគឆ្លង និងជំងឺមហារីកមួយចំនួនដូចជា ជំងឺមហារីកសុដន់ និងមហារីកមាត់ស្បូន ផងដែរ។[81]

ថ្វីបើមានការខ្វះខាតនូវទិន្នន័យជាក់លាក់ជាប្រព័ន្ធស្តីពីក្រុម ភ.ដ.ព.ប នៅកម្ពុជាក៏ដោយ ការសិក្សានៅជុំវិញពិភពលោកបានបង្ហាញថាមានភស្តុតាងដែល ក្រុម ភ.ដ.ព.ប មានលក្ខណៈឆាប់រហ័សក្នុងការមានជំងឺ

---

ដែលនិយាយតំណាងឲ្យអ្នកស្រលាញ់ភេទដូចគ្នាត្រូវបានគេវាយដំ'សារព័ត៌មាន ឌឹ ញូវយ៉ក ថាមស៍ ថ្ងៃទី២៧ ខែមករា ឆ្នាំ២០១១ <www.nytimes.com/2011/01/28/world/africa/28uganda.html?_r=0>។

[78]ឧទាហរណ៍ ក្នុងសហរដ្ឋអាមេរិក ការស្រាវជ្រាវបានបង្ហាញពីភាពខុសគ្នាយ៉ាងសំខាន់រវាងនីតិជនដែលប្រតិព័ទ្ធភេទផ្ទុយ និងនីតិជន ភ.ដ.ព.ប ដែល ភ.ដ.ព.បនឹងមិនសូវទទួលបាននូវការធានារ៉ាប់រងផ្នែកសុខភាព ហាក់ដូចជាមានការយឺតយ៉ាវ ឬមិនស្វែងរកនូវការព្យាបាល និងហាក់ដូចជាមានការពន្យារ និងមិនបានទទួលនូវថ្នាំពេទ្យដែលចាំបាច់តាមវេជ្ជបញ្ជា។ មូលហេតុត្រូវបានកំណត់សម្រាប់ភាពខុសគ្នានេះ ដែលរួមមាន ការកាត់បន្ថយលទ្ធភាពទទួលបាននូវការធានារ៉ាប់រងសុខភាពតាមរយៈការផ្តល់ដោយនិយោជក ការរើសអើងក្នុងសង្គមប្រឆាំងនឹង ភ.ដ.ព.ប និងខ្វះខាតសមត្ថកិច្ចផ្នែកវប្បធម៌ក្នុងប្រព័ន្ធផ្តល់សេវាសុខភាព។ មើលមជ្ឈមណ្ឌលសម្រាប់ការរីកចម្រើនរបស់ជនជាតិអាមេរិក'របៀបបិទចន្លោះភាពខុសគ្នាផ្នែកសេវាសុខភាពសម្រាប់ ភ.ដ.ព.ប' (កំណត់ហេតុសង្ខេប) (ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៩)<www.americanprogress.org/wp-content/uploads/issues/2009/12/pdf/lgbt_health_disparities.pdf>។

[79]ដូចខាងលើ ៤។

[80]ការិយាល័យឧត្តមស្នងការសហប្រជាជាតិស្តីពីសិទ្ធិមនុស្ស 'កើតមកដោយសេរី និងស្មើភាព ៖ និន្នាការភេទ និងអត្តសញ្ញាណយេនឌ័រក្នុងច្បាប់សិទ្ធិមនុស្សអន្តរជាតិ' (ខែកញ្ញា ឆ្នាំ២០១២) ៥១ <www.ohchr.org/Documents/Publications/BornFreeAndEqualLowRes.pdf>។

[81]សមាគមអ្នកស្រលាញ់ភេទដូចគ្នា អ្នកស្រលាញ់ភេទទាំងពីរ អ្នកប្តូរភេទ និងអន្តរភេទ'សុខភាពរបស់ស្ត្រីស្រលាញ់ស្ត្រី ៖ អាថ៌កំបាំង និងការពិត' (ខែកញ្ញា ឆ្នាំ២០១១) <www.iglhrc.org/binary-data/ATTACHMENT/file/000/000/539-1.pdf>។

ផ្លូវចិត្ត និងការសម្លាប់ខ្លួន។ ឧទាហរណ៍ ក្នុងប្រទេសតៃវ៉ាន់ យោងតាមការស្ទង់មតិធ្វើឡើងដោយ សម្ព័ន្ធមិត្តភាពតៃវ៉ាន់ សហព័ន្ធនៃក្រុមជាច្រើនធ្វើការលើសិទ្ធិរបស់ក្រុម ភ.ដ.ព.ប បានបង្ហាញថាប្រហែលមួយភាគបីនៃអ្នកចូលរួមស្ទង់មតិមានគំនិតចង់ធ្វើឃាតខ្លួនឯងម្តងក្នុងជីវិតរបស់ពួកគេ។[82] របាយការណ៍មួយក្នុង ឆ្នាំ២០០៨ របស់មជ្ឈមណ្ឌលការពារការធ្វើអត្តឃាត មានទីតាំងនៅប្រទេសអាមេរិកបានពន្យល់ថា "*ការសិក្សាផ្សេងៗបានបង្ហាញថា យុវជន ភ.ដ.ព* [sic] *ត្រូវបានរាយការណ៍ថាមានគំនិតចង់សម្លាប់ខ្លួន រវាង១.៥ដង ទៅ៣ដង ច្រើនជាងក្រុមយុវជនដែលមិនមែន ភ.ដ.ព ហើយដែលការស្រាវជ្រាវពីប្រកពជាច្រើនក៏បានបង្ហាញថា យុវជន ភ.ដ.ព ត្រូវបានរាយការណ៍ថាប៉ុនប៉ងសម្លាប់ខ្លួន រវាង ១.៥ដង ទៅ ៧ដង ច្រើនជាង យុវជនដែលមិនមែន ភ.ដ.ព ។ ការសិក្សាទាំងនេះមិនរួមបញ្ចូលយុវជនដែលប្តូរភេទនោះទេ"។*[83] ករណីជាច្រើនក្នុងចំណោមករណីទាំងនេះ ការតប់ប្រមល់ និងគំនិតចង់សម្លាប់ខ្លួនកើតមកពីការនិយាយបង្អាប់លេងសើចរាប់សិបឆ្នាំ ការបំពានដោយប្រើពាក្យសម្តី ការផ្តាច់ខ្លួនចេញពីសង្គម និងការរំពឹងថាខ្លួននឹងអាចចូលចំណោមក្នុងក្រុមគ្រួសារ និងវប្បធម៌ប្រពៃណី។

នៅកម្ពុជា បញ្ហាទាំងនេះលាយឡំជាមួយនឹងវិស័យសុខាភិបាលដែលជាញឹកញាប់មិនអាចផ្តល់នូវការថែរក្សាសុខភាពឲ្យបានសមស្របទៅប្រជាពលរដ្ឋខ្មែរជាច្រើនទៀតផងដែរ។ ទម្រង់នៃការផ្តល់សេវាសុខភាព ឆ្នាំ២០១២ ដែលចងក្រងដោយអង្គការសុខភាពពិភលោក និងក្រសួងសុខាភិបាលរបស់កម្ពុជា បានកត់សម្គាល់ថាក្នុងឆ្នាំ២០១០ "*មានត្រឹមតែ ៤០% នៃមណ្ឌលសុខភាពដែលបានផ្តល់នូវកញ្ចប់សេវាសុខភាពកម្រិតអប្បបរមាបានពេញលេញ ហើយដែលឧបសគ្គទាំងនោះ មានដូចជា អវត្តមាននៃបុគ្គលិកគោល កង្វះខាតការផ្គត់ផ្គង់ថ្នាំសង្កូវ និងកង្វះខាតនូវតម្រូវការសេចក្តីណែនាំពីការប្រតិបត្តិដទៃ"*។[84] យោងតាមរបាយការណ៍របស់ សហព័ន្ធអន្តរជាតិរៀបចំផែនការគ្រួសារ ស្តីពីការបង្ការមេរោគអេដស៍ បុរសរួមភេទជាមួយបុរស និងអ្នកប្តូរភេទដែលផ្ទុកមេរោគអេដស៍ នៅកម្ពុជាជួបប្រទះនូវការប្រឈមទ្វេរដងដោយសារតែការរើសអើងពីក្រុមគ្រួសារ សហគមន៍ និងមណ្ឌលផ្តល់សេវាសុខភាព។[85]

ប្រទេសថៃបានបង្ហាញពីបទពិសោធន៍អនុវត្ត ដ៏ល្អពាក់ព័ន្ធនឹងការផ្តួចផ្តើមដែលគាំទ្រឲ្យមានលទ្ធភាពទទួលបានស្មើភាពគ្នាសម្រាប់ក្រុម ភ.ដ.ព.ប។ ក្រុមអាន់ចារី[86] ក្រុមដំបូងបង្អស់ ដែលជាក្រុមសកម្មជនបង្កើត

---

[82]អេដម៉ុន ប្រុចន៍ 'តៃវ៉ាន់ ៖ ប្រហែលជាមួយភាគប្រាំនៃចំនួនបុរសស្រលាញ់បុរសមានទំនោរសម្លាប់ខ្លួន' (ព័ត៌មានពណ៌ផ្កាឈូក ថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១២) www.pinknews.co.uk/2012/04/17/taiwan-almost-one-in-five-gay-people-have-attempted-suicide/។

[83]មណ្ឌលការពារការធ្វើអត្តឃាត 'ការប្រឈមនៃការធ្វើអត្តឃាត និងការការពារសម្រាប់ យុវជនដែលជា ស្ត្រីស្រលាញ់ស្ត្រី បុរសស្រលាញ់បុរស អ្នកស្រលាញ់ទាំងពីរភេទ និងអ្នកប្តូរភេទ' (ឆ្នាំ២០០៨ )<www.sprc.org/sites/sprc.org/files/library/SPRC_LGBT_Youth.pdf>។

[84]អង្គការសុខភាពពិភពលោក 'ទម្រង់នៃការផ្តល់សេវាសុខភាព ៖ កម្ពុជា ២០១២' (ឆ្នាំ២០១២) <www.wpro.who.int/health_services/service_delivery_profile_cambodia.pdf>។

[85]សហព័ន្ធអន្តរជាតិរៀបចំផែនការគ្រួសារ'ប័ណ្ណរាយការណ៍ស្តីពីការពារមេរោគអេដស៍សម្រាប់ បុរសរួមភេទជាមួយបុរស និងអ្នកប្តូរភេទ ៖ កម្ពុជា'(ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១១ )www.msmgf.org/index.cfm/id/11/aid/4648។

[86]www.astraeafoundation.org/grants/meet-a-grantee/anjaree។

ឡើងនៅប្រទេសថៃក្នុង ឆ្នាំ១៩៨៦ ដើម្បីទាមទារសិទ្ធិឲ្យស្ត្រីស្រលាញ់ស្ត្រី និងដែលបានធ្វើការងារមួយដែលគួរឲ្យចងចាំរួមជាមួយក្រសួងសុខាភិបាលប្រទេសថៃ ក្នុងឆ្នាំ២០០២ គឺការចេញនូវសេចក្តីថ្លែងការណ៍សាធារណៈថាការស្រលាញ់ភេទដូចគ្នាមិនមែនជាជំងឺផ្លូវចិត្តនោះទេ។ ក្រុមអាន់ចារី បន្តធ្វើការងារលើបញ្ហានេះ ដោយធ្វើការជាមួយក្រសួងសុខាភិបាលដើម្បីបង្កើត និងរៀបចំវគ្គបណ្តុះបណ្តាលសម្រាប់គ្រូពេទ្យផ្នែកចិត្តវិទ្យា និងអ្នកអាជីពដទៃទៀតដែលធ្វើការពាក់ព័ន្ធនឹងសុខភាពផ្នែកផ្លូវចិត្តដើម្បីធានាថាអ្នកអាជីពផ្នែកវេជ្ជសាស្ត្រមិនឆ្លើយតបដោយបុរេវិច្ឆ័យនៅពេលដែលធ្វើការជាមួយក្រុម ភ.ដ.ព.ប នោះទេ។

នៅសហរដ្ឋអាមេរិក យុទ្ធនាការសិទ្ធិមនុស្ស បានរៀបចំនូវសកម្មភាពមួយចំនួនដោយផ្តោតលើសេវាសុខភាពសម្រាប់ ក្រុម ភ.ដ.ព.ប ជនជាតិអាមេរិក រួមមាន ការស្ទង់មតិអ្នកផ្តល់សេវាសុខភាពស្តីពីគោលនយោបាយ និងការអនុវត្តន៍របស់ពួកគេ ពេលធ្វើការជាមួយអ្នកជំងឺជា ភ.ដ.ព.ប និងក្រុមគ្រួសារពួកគេ។[87] បន្ថែមពីលើការជួយកំនត់បទពិសោធន៍អនុវត្តដ៏ល្អបំផុតសម្រាប់សេវាសុខភាពរបស់ក្រុម ភ.ដ.ព.ប ដែលងាយបាក់ទឹកចិត្ត សកម្មភាពរបស់ យុទ្ធនាការសិទ្ធិមនុស្សក៏បានពាក់ព័ន្ធនឹងការធ្វើការងារជាមួយក្រុមអ្នកផ្តល់សេវាសុខភាពដើម្បីធានាថាសេវារបស់ពួកគេ បានបញ្ចូលនូវបទពិសោធន៍ងអនុវត្តដ៏ល្អបំផុតទាំងនេះដែរ។ រួមជាមួយគ្នានេះ នៅសហរដ្ឋអាមេរិក សមាគមផ្នែកវេជ្ជសាស្ត្រ នៃអ្នកស្រលាញ់ភេទដូចគ្នា បានបង្កើតសេចក្តីណែនាំសម្រាប់ការព្យាបាលដល់ក្រុម ភ.ដ.ព.ប ដើម្បីឲ្យអ្នកអាជីពផ្នែកវេជ្ជសាស្ត្រអាចបង្កើតបរិស្ថានមន្ទីរពេទ្យដែលមានលក្ខណៈស្វាគមន៍ដល់ក្រុម ភ.ដ.ព.ប។[88] សេចក្តីណែនាំទាំងនេះ គួរតែត្រូវបានយកមកអនុវត្តក្នុងបរិបទប្រទេសកម្ពុជា។

ពាក់ព័ន្ធនឹងការគាំទ្រឲ្យមានលទ្ធភាពទទួលបានសេវាសុខភាពរបស់ក្រុម ភ.ដ.ព.ប និងជាពិសេសសម្រាប់អ្នកផ្ទុកមេរោគអេដស៍ សមាគមមេឃពណ៌ឥន្ទធនូរបស់ប្រទេសថៃ ដែលធ្វើការលើការការពារ អប់រំ និងគាំទ្រដល់ ក្រុម ភ.ដ.ព.ប ដែលផ្ទុកមេរោគអេដស៍បាននាំមុខគេនូវគម្រោងដូចជា ៖ ក្រុមប្រឹក្សាផ្តល់ការណែនាំសម្រាប់សហគមន៍ សិក្ខាសាលាសម្រាប់អ្នកផ្ទុកមេរោគអេដស៍ វគ្គបណ្តុះបណ្តាលសម្រាប់អង្គការបង្កើតថ្មី ឬបុគ្គលក្នុងសហគមន៍ ដែលមានបំណងចង់ជួយសហគមន៍ ភ.ដ.ព.ប ការប្រឹក្សាតាមទូរស័ព្ទដោយឥតគិតថ្លៃសម្រាប់អ្នកផ្ទុកមេរោគអេដស៍ មណ្ឌលសហគមន៍ដើម្បីផ្តល់កន្លែងសម្រាប់ ភ.ដ.ព.ប ដើម្បីអាចជួបជុំគ្នាទៅវិញទៅមក "ការផ្តួចផ្តើមជំរុំបំនិនជីវិត" (ការបោះជំរំរយៈពេលមួយសប្តាហ៍សម្រាប់ ក្រុមបុរសរួមភេទជាមួយបុរស) និង "បវរកញ្ញាផ្ទៃមេឃឥន្ទធនូ២០១២" ការប្រកួតសម្រាប់អ្នកប្តូរភេទ។[89]

នៅកម្ពុជា បណ្តាញបុរសរួមភេទជាមួយបុរសដែលផ្ទុកមេរោគអេដស៍ មានគម្រោងសាកល្បងមួយធ្វើការជាមួយបណ្តាញដែលមានក្រុមអ្នកស្រលាញ់ភេទដូចគ្នា និងអ្នកប្តូរភេទប្រហែលជា ៣០០នាក់ ផ្ទុកមេរោគអេដស៍ ភាគច្រើនគឺគ្មានផ្ទះសម្បែង និងជីវភាពក្រីក្រ និងដែលត្រូវការការគាំទ្រដើម្បីស្វែងរកលំនៅដ្ឋាន និងធ្វើ

---

[87]យុទ្ធនាការសិទ្ធិមនុស្ស សន្ទសន៍សមភាពក្នុងវិស័យសុខាភិបាល<www.hrc.org/hei#.ULXIPIZe-Yt>។

[88]សមាគមផ្នែកវេជ្ជសាស្ត្រ នៃអ្នកស្រលាញ់ភេទដូចគ្នា'សេចក្តីណែនាំសម្រាប់ការថៃរក្សា អ្នកជំងឺជា ស្ត្រីស្រលាញ់ស្ត្រី និងបុរសស្រលាញ់បុរស អ្នកស្រលាញ់អ្នកទាំងពីរភេទ និងអ្នកប្តូរភេទ' (ឆ្នាំ២០០៦)
<www.glma.org/_data/n_0001/resources/live/GLMA%20guidelines%202006%20FINAL.pdf>។

[89]http://old.msmgf.org/MSMGFdirectory/MSMGFbytype/RainbowSkyAssociationofThailand.htm។

ការតស៊ូមតិសម្រាប់សមាជិកដែលប្រឈមនឹងលទ្ធភាពទទួលបានសេវាសុខភាពមិនស្មើភាព ដោយសារតែអ្នកផ្ដល់សេវាសុខភាពមានកង្វះខាតការយល់ដឹងពីតម្រូវការជាក់លាក់របស់ពួកគាត់។ គម្រោងក៏បានរាយការណ៍ថាមានចន្លោះប្រហោងដ៏ធំក្នុងសេវាកម្មនេះដោយសារតែសមាជិករបស់ពួកគេ និងកំពុងតែខិតខំកាត់បន្ថយនូវចន្លោះប្រហោងនេះតាមរយៈការចូលទៅកាន់មន្ទីរពេទ្យ និងគ្លីនិកដើម្បីពិភាក្សា និងអប់រំអ្នកផ្ដល់សេវាសុខភាពអំពីតម្រូវការជាក់លាក់របស់អ្នកជំងឺដែលជា ភ.ដ.ព.ប។ គម្រោងនេះបានធ្វើការដើម្បីពង្រីកបណ្ដាញតាមរយៈការចុះទៅជួបអ្នករស់នៅក្នុងសហគមន៍ និងទីក្រុងថ្មីៗ។ ចំណុចសំខាន់ដែលត្រូវការឲ្យមានការកែលម្អសម្រាប់បុរសរួមភេទ ជាមួយបុរសនិងអ្នកប្ដូរភេទផ្ទុកមេរោគអេដស៍ គឺការបង្កើតនូវផ្ទះសម្រាប់ស្នាក់ ឬសណ្ឋាគារ ដែលពួកគេអាចទទួលការព្យាបាល និងត្រូវបានផ្ដល់នូវបណ្ដុះបណ្ដាលវិជ្ជាជីវៈដើម្បីអាចឲ្យពួកគេស្វែងរកការងារបានធ្វើ។

**អនុសាសន៍សម្រាប់រដ្ឋាភិបាល/ក្រសួងសុខាភិបាល ៖ ដាក់ចេញនូវសេចក្ដីណែនាំ និងវគ្គបណ្ដុះបណ្ដាលសម្រាប់អ្នកធ្វើការក្នុងសេវាសុខភាពក្នុងគោលបំណងការពារសុខភាពរបស់ក្រុម ភ.ដ.ព.ប ឲ្យបានកាន់តែប្រសើរជាងនេះ។**

**អនុសាសន៍សម្រាប់រដ្ឋាភិបាល/ក្រសួងសុខាភិបាល ៖ រៀបចំយុទ្ធនាការដើម្បីលើកកម្ពស់ការយល់ដឹងក្នុងគោលបំណងធានាថាក្រុម ភ.ដ.ព.ប ទទួលបាននូវការថែទាំសុខភាព ទាំងធ្វើឲ្យក្រុមអ្នកផ្ដល់សេវាសុខភាពមានការយល់ចិត្ត យល់ពីតម្រូវការរបស់អ្នកជំងឺដែលជា ភ.ដ.ព.ប និងដើម្បីធានាថាអ្នកជំងឺដែលជា ភ.ដ.ព.ប យល់ពីភាពចាំបាច់នៃការត្រួតពិនិត្យសុខភាពជាញឹកញាប់។**

**អនុសាសន៍សម្រាប់រដ្ឋាភិបាល/ក្រសួងសុខភិបាល និងសង្គមស៊ីវិល ៖ ធ្វើការជាដៃគូដើម្បីធ្វើការស្ទង់មតិស្ដីពីសុខភាពផ្លូវចិត្តរបស់ក្រុម ភ.ដ.ព.ប កំណត់នូវបទពិសោធន៍អនុវត្តល្អបំផុតដើម្បីគាំទ្រអ្នកដែលមានបញ្ហា និងលើកកម្ពស់ការយល់ដឹងអំពីតម្រូវការជាក់លាក់របស់ពួកគេជាមួយក្រុមអ្នកផ្ដល់សេវាសុខភាព។**

## ៤.៩. បណ្ដាញសារព័ត៌មាន

ទោះបីជាបណ្ដាញសារព័ត៌មានអាចដើរតួយ៉ាងសំខាន់ក្នុងការលើកកម្ពស់ការយល់ដឹងស្ដីពីសិទ្ធិមនុស្សដែលរួមទាំងបញ្ហារបស់ ភ.ដ.ព.ប យ៉ាងណា តែបណ្ដាញសារព័ត៌មានក៏អាចជះឥទ្ធិពលអវិជ្ជមាន ប្រសិនបើបណ្ដាញសារព័ត៌មាននោះបញ្ជូននូវរូបភាពអវិជ្ជមានរបស់សហគមន៍ ភ.ដ.ព.ប។ ជាញឹកញាប់ ការពណ៌នាទៅលើក្រុម
ភ.ដ.ព.ប ក្នុងបណ្ដាញសារព័ត៌មាន ជាពិសេសនៅលើទូរទស្សន៍ដែលមានការកំណត់ទុកមុននៃចរិតលក្ខណៈបង្ហាញនូវការនាំឲ្យមានការតក់ស្លុតជាទូទៅ ដែលហាក់ដូចជាផ្ដល់ការប៉ះទង្គិចអវិជ្ជមានមកលើក្រុម ភ.ដ.ព.ប និងអាចនាំទៅដល់ការរើសអើងបន្ថែមទៀត។

នៅកម្ពុជា ទោះបីជាបញ្ហា ភ.ដ.ព.ប បានទទួលនូវការចាប់អារម្មណ៍ពីសារព័ត៌មានថ្នាក់ជាតិច្រើនជាងមុនក៏ដោយ ប៉ុន្តែចំណាប់អារម្មណ៍ទាំងនោះមិនមែនសុទ្ធតែវិជ្ជមាននោះទេ។ ឧទាហរណ៍ ភាពយន្តបែបរន្ធត់មួយក្នុងឆ្នាំ២០០៦ ចំណងជើងថា "ខ្មោចប្រពន្ធអាទុយ" មានបញ្ចូលនូវឆាកដែលស្ត្រីដែលបានរៀបការរួចម្នាក់មានទំនាក់ទំនងស្នេហាជាមួយនឹងស្ត្រីម្នាក់ទៀត ជាលទ្ធផលនាងត្រូវបាន "ព្យាបាល" ភាពជាស្ត្រីស្រលាញ់ស្ត្រី

ដោយការរំលោភសេពសន្ថវៈ។[90] ផ្ទុយមកវិញ ភាពយន្តមួយក្នុងឆ្នាំ២០០៩ ចំណងជើងថា "ខ្ញុំជានរណា?" ដែលនិពន្ធ និងដឹកនាំដោយ លោកស្រី ពាន់ ភួងបុប្ផា គឺជាភាពយន្តដំបូងដែលបរិយាយបែបវិជ្ជមាន អំពីទំនាក់ទំនងនៃអ្នកស្រលាញ់ភេទដូចគ្នានៅកម្ពុជា និងត្រូវបានបញ្ចាំងជាច្រើនលើកច្រើនសារនៅលើស្ថានីយទូរទស្សន៍ស៊ីធីអិន។[91] ប្រហាក់ប្រហែលគ្នាដែរ ក្នុងឆ្នាំដដែលប្រលោមលោកដែលពាក់ព័ន្ធនឹងការស្រលាញ់ភេទដូចគ្នាចំណងជើងថា "*ស្នេហាសុភាពបុរស*" និពន្ធដោយ សុខ ចាន់ផល ត្រូវបានបោះពុម្ពផ្សាយ ដែលបង្ហាញពីភាពសំខាន់ចាំបាច់ដែលកើនឡើងនៃរូបភាពវិជ្ជមានរបស់ ភ.ដ.ព.ប ក្នុងបណ្តាញសារព័ត៌មាន។

អង្គការសង្គមស៊ីវិលក៏ដើរតួយ៉ាងសំខាន់ ដើម្បីធានាថាបណ្តាញសារព័ត៌មានបង្ហាញនូវរូបភាពរបស់ក្រុម ភ.ដ.ព.ប ក្នុងលក្ខណៈជាវិជ្ជមាន។ នៅប្រទេសថៃ អង្គការឥន្ទធនូបាងកក មិនត្រឹមតែបានផ្តល់ការណែនាំទៅកាន់សារព័ត៌មានជាតិ និងអន្តរជាតិស្តីពីរបៀបលើកយកបញ្ហា ភ.ដ.ព.ប មកបង្ហាញក្នុងបែបវិជ្ជមាននោះទេ ប៉ុន្តែថែមទាំងតស៊ូមតិប្រឆាំងនឹងកម្មវិធីទូរទស្សន៍ និងការផ្សព្វផ្សាយពាណិជ្ជកម្មដែលបានបង្ហាញពីសហគមន៍ ភ.ដ.ព.ប ក្នុងបែបអវិជ្ជមានផងដែរ។ អង្គការឥន្ទធនូបាងកក ក៏បានរៀបចំនូវ "បទបង្ហាញពីពានរង្វាន់សារព័ត៌មានឥន្ទធនូ" ដែលទទួលស្គាល់ក្រុមសារព័ត៌មានដែលគាំទ្រយ៉ាងសកម្មមកលើសហគមន៍ ភ.ដ.ព.ប។[92] ស្រដៀងគ្នានេះដែរ ក្នុងសហរដ្ឋអាមេរិក សម្ព័ន្ធអ្នកស្រលាញ់ភេទដូចគ្នាប្រឆាំងនឹងការបរិហារកេរ្តិ៍ បានចេញនូវ "សន្ទស្សន៍ទំនួលខុសត្រូវរបស់បណ្តាញសារព័ត៌មាន" ប្រចាំឆ្នាំ ដែលផ្តល់ការ "*វាយតម្លៃលើបរិមាណ គុណភាព និងភាពចម្រុះនៃរូបភាពរបស់អ្នកស្រលាញ់ភេទដូចគ្នា អ្នកស្រលាញ់ទាំងពីរភេទ និងអ្នកប្តូរភេទ ក្នុងកញ្ចក់ទូរទស្សន៍ ក្នុងសហរដ្ឋអាមេរិក*"។[93]

បន្ថែមពីលើនោះ តារាល្បីៗដែលជាក្រុម ភ.ដ.ព.ប និងអ្នកល្បីឈ្មោះដទៃទៀតដែលគាំទ្រនូវសិទ្ធិរបស់ក្រុម ភ.ដ.ព.ប ក៏អាចធ្វើឲ្យមានការផ្លាស់ប្តូរមកលើទស្សនៈសាធារណជន ដើរតួជាបុគ្គលគំរូ និងដឹកនាំឲ្យមានការផ្លាស់ប្តូរឥរិយាបថរបស់ប្រជាពលរដ្ឋផងដែរ។ នៅកម្ពុជា ថ្មីៗនេះ បានណែនាំនូវពានរង្វាន់អាណាចក្រតារាសម្រាប់ផ្នែកអ្នកសម្តែងជាអ្នកស្រលាញ់ភេទដូចគ្នាល្អបំផុត។ ក្នុងខែកុម្ភៈ ឆ្នាំ២០១២ "កញ្ញា ប៉ុបពី" ទទួលបានរង្វាន់នេះ នាងគឺជាតារាស្រីអ្នកប្តូរភេទ ហើយត្រូវបានចុះផ្សាយក្នុងសារព័ត៌មាន ដូច្នេះបានផ្តល់នូវវេទិកាសម្រាប់ កញ្ញា ប៉ុបពី ក្នុងការតស៊ូមតិដើម្បីសិទ្ធិរបស់ ភ.ដ.ព.ប ដោយប្រើប្រាស់បទពិសោធន៍ផ្ទាល់ខ្លួនរបស់នាង ៖ "*ខ្ញុំមានការឈឺចាប់ជាខ្លាំងដោយសារតែការរើសអើង និងការជេរស្តីមកលើរូបខ្ញុំ។ ចំណុចនេះបាននាំឲ្យ*

---

[90]លី គឹមស្រ៊ុន (អ្នកនិពន្ធ និងអ្នកដឹកនាំរឿង) 'ខ្មោចប្រពន្ធអាទុយ' (ឆ្នាំ២០០៦)

[91]គាំ ទិវា និងមេងហួង 'ដូច ដូច ... ប៉ុន្តែរៀបការជាមួយគ្នា' (*សារព័ត៌មាន ឌឹ ភ្នំពេញ ប៉ុស្តិ៍ ៖ លីហ្វ* ថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១០)។

[92]អង្គការឥន្ទធនូបាងកក 'អំពីយើង' <www.bangkokrainbow.org/About_Us.html>។

[93]សម្ព័ន្ធអ្នកស្រលាញ់ភេទដូចគ្នាប្រឆាំងនឹងការបរិហារកេរ្តិ៍ 'សន្ទស្សន៍ការទទួលខុសត្រូវរបស់បណ្តាញសារព័ត៌មាន ឆ្នាំ២០១១-២០១២' (ខែសីហា ឆ្នាំ២០១២) <www.glaad.org/publications/nri>។

*ខ្ញុំខំរើបម្រះ និងគេចវេះពីភាពជាអ្នកស្រលាញ់ភេទដូចគ្នា ដែលត្រូវបានពិចារណាដោយមនុស្សជាច្រើនថាគ្មានប្រយោជន៍”។*[94]

តារាកម្ពុជាដ៏ល្បីឈ្មោះមួយរូបទៀតដែលបានប្តូរភេទដែរនោះគឺ កញ្ញា ស៊ិនឌី បានគាំទ្រនូវយុទ្ធនាការលើកកម្ពស់ការយល់ដឹងស្តីពី ភ.ដ.ព.ប ក្នុងកម្រិតដែលអាចធ្វើទៅបាន ៖ កញ្ញា ស៊ិនឌី បានចូលរួមក្នុងសិក្ខាសាលា ភ.ដ.ព.ប របស់ ម.ស.ម.ក ដើម្បីបង្ហាញជាគំរូ និងលើកទឹកចិត្តអ្នកចូលរួមសិក្ខាសាលាឲ្យប្រឆាំងនឹងការរើសអើងតាមរយៈចែករំលែកនូវបទពិសោធន៍របស់ខ្លួន។ នាងក៏បានប្រើប្រាស់ភាពល្បីរបស់នាង ដើម្បីជំរុញឲ្យរដ្ឋាភិបាលធ្វើវិសោធនកម្មនូវច្បាប់ដែលពាក់ព័ន្ធ ដើម្បីឲ្យច្បាប់ទាំងនោះអាចការពារសិទ្ធិរបស់ ភ.ដ.ព.ប។[95] ការគាំទ្រពីក្រុមអ្នកតស៊ូមតិបែបនេះ គឺមានអនុភាពខ្លាំងណាស់ និងគួរឲ្យលើកទឹកចិត្ត និងគាំទ្រនូវរាល់ឱកាសទាំងអស់។

ការគាំទ្ររបស់តារាល្បីក្នុងថ្នាក់អន្តរជាតិ ក៏ទទួលបានការជោគជ័យក្នុងការលើកកម្ពស់ការយល់ដឹង និងបង្កើននូវការគាំទ្រជាសាធារណៈសម្រាប់ក្រុម ភ.ដ.ព.ប ផងដែរ។ ឧទាហរណ៍ ក្នុងឆ្នាំ២០១១ អ្នកចម្រៀងលេឌី កាកា ដែលគាំទ្រយ៉ាងខ្លាំងមកលើក្រុម ភ.ដ.ព.ប អស់រយៈពេលជាច្រើនឆ្នាំ បានសម្ពោធនូវ “មូលនិធិកើតមកក្នុងរបៀបនេះ” ដែលមានបំណងកាត់បន្ថយនូវបញ្ហាដែលជួបប្រទះដោយក្រុមយុវជន ភ.ដ.ព.ប ដូចជាការនិយាយបង្អាប់ដោយការរើសអើង តាមរយៈការបង្កើត “*សហគមន៍មានសុវត្ថិភាពដែលជួយភ្ជាប់ក្រុមក្មេងៗទៅនឹងជំនាញ និងឱកាសដែលពួកគេត្រូវការដើម្បីកសាងនូវពិភពដែលល្អប្រសើរ និងក្លាហានជាងនេះ”។*[96] ស្រដៀងគ្នានេះដែរ អ្នកចម្រៀងម៉ាដូណា ត្រូវបានប្តឹងដោយសកម្មជនអភិរក្សនិយមជនជាតិរូស្ស៊ី ដោយសារតែនាងបានជំរុញឲ្យអ្នកស្តាប់របស់នាង “*បង្ហាញសេចក្តីស្រលាញ់ និងការលើកសរសើរចំពោះសហគមន៍អ្នកស្រលាញ់ភេទដូចគ្នា”* ក្នុងអំឡុងការប្រគុំតន្ត្រីក្នុងខែសីហា ឆ្នាំ២០១២ នៅទីក្រុង សែន ភីតធឺស្បឺក ដែលមានច្បាប់ត្រូវបានអនុម័តក្នុងដើមឆ្នាំ ដោយចាត់ទុកជាសកម្មភាពខុសច្បាប់ក្នុងការ “លើកកម្ពស់” ការស្រលាញ់ភេទដូចគ្នាទៅដល់ក្រុមអនីតិជន។[97]

សង្គមនៃស្ត្រីប្តូរភេទក្នុងប្រទេសហ្វីលីពីន[98] បានបង្កើននូវការផ្សព្វផ្សាយនៃយុទ្ធនាការ ភ.ដ.ព.ប របស់ខ្លួនទៅក្នុងកម្រិតអតិបរមា តាមរយៈការគាំទ្រអ្នកប្តូរភេទដែលល្បីឈ្មោះ។ ក្នុងឆ្នាំ២០១០ សង្គមនៃស្ត្រីប្តូរភេទក្នុងប្រទេសហ្វីលីពីននេះ បានរៀបចំនូវការផ្តល់ពានរង្វាន់ ស៊ីប៊ីល ដើម្បីជាការលើកសរសើរចំពោះបុគ្គល និង

---

[94]‘តារាសម្តែងជាស្ត្រីប្តូរភេទអំពាវនាវឲ្យឈប់មានការរើសអើងបន្ទាប់ពីទទួលបានរង្វាន់ជាតារាសម្តែងល្អបំផុតផ្នែកអ្នកស្រលាញ់ភេទដូចគ្នាល្អ’ (*ឌឹ ខេមបូឌា ដេលី* ថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០១២) www.thecambodiaherald.com/cambodia/detail/1?page=14&token=ZDYxM2MxYjI0NWEwYWEwZmIwYjA1ZjE3MGZiMTA5

[95]សិក្ខាសាលា របស់ ម.ស.ម.ក (ភ្នំពេញ ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១១)

[96]មូលនិធិកើតមកក្នុងរបៀបនេះ ‘បេសកកម្មរបស់យើង’ <http://bornthiswayfoundation.org/pages/our-mission/>។

[97]ជូលី បិលស៊ីរ ‘ករណីសុន្ទរកថារបស់អ្នកការពារសិទ្ធិអ្នកស្រលាញ់ភេទដូចគ្នា ចំពោះការទម្លាក់ការចោទប្រកាន់លើម៉ាដូណា’ (*ឌឹ អែតវ៉ូខេត* ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១២) <www.advocate.com/news/world-news/2012/11/23/russian-gay-rights-speech-case-against-madonna-dismissed>។

[98]<www.tsphilippines.com/aboutstrap.htm>។

ស្ថាប័នដែលបានធ្វើការលុបបំបាត់នូវការមិនអត់ឱន និងការរើសអើងដោយផ្អែកលើនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ។ ពានរង្វាន់នេះត្រូវបានដាក់ឈ្មោះបន្ទាប់ពីការចូលរូបរបស់ទេពធិតា ឬ "អ្នកម្តាយដ៏អស្ចារ្យ" ស៊ីប៊ីល ដែលគោរពដោយបព្វជិតភេទស្រីកាលពីអំឡុងសម័យក្រិចបុរាណ ឬមុននោះទៅទៀត។[99]

ក្រុមពណ៌ឥន្ទធនូ ជាក្រុមមានទីតាំងក្នុងប្រទេសថៃ ដែលបានប្រមូលផ្តុំនូវអង្គការសហគមន៍ ភ.ដ.ព.ប នៅទូទាំងប្រទេសភូមា បានបង្ហាញថាឧទាហរណ៍ដ៏ល្អអំពីបណ្តាញចងភ្ជាប់ដែលមានភាពរស់រវើក។ ក្រុមពណ៌ឥន្ទធនូ ប្រើប្រាស់នូវបណ្តាញសារព័ត៌មានជាច្រើន ដើម្បីផ្សព្វផ្សាយនូវព័ត៌មានក្នុងចំណោមក្រុមចម្រុះផ្សេងៗ ដែលមានដូចជា ទស្សនាវដ្តីឥន្ទធនូ វែបសាយឥន្ទធនូ និងទូរទស្សន៍ឥន្ទធនូលើបណ្តាញអ៊ីនធើណែត។[100]

មានតម្រូវការជាចាំបាច់ខ្លាំងណាស់ក្នុងការចែករំលែកព័ត៌មានពាក់ព័ន្ធនឹងក្រុម ភ.ដ.ព.ប នៅទូទាំងប្រទេសកម្ពុជា ដើម្បីដោមុខសញ្ញាលើក្រុម និងបណ្តាញ ភ.ដ.ព.ប នៅជុំវិញប្រទេស ក៏ដូចជាសាធារណជនជាក្នុងទំហំធំផងដែរ។ ក្នុងប្រទេសកម្ពុជា តម្រូវការដែលគួរផ្តោតសំខាន់ទៅលើគឺការបង្កើតនូវកម្មវិធីវិទ្យុ ដោយសារតែអត្រាអ្នកចេះអក្សរមានកម្រិតទាប ស្ថានីយទូរទស្សន៍រដ្ឋដែលរងការគាបសង្កត់ដ៏ធ្ងន់ធ្ងរនៅកម្ពុជា និងអត្រានៃអ្នកប្រើប្រាស់អ៊ិនធើណែតដែលមានកម្រិតទាប ជាពិសេស នៅទីជនបទ។[101]បច្ចុប្បន្ន ម.ស.ម.ក បានរៀបចំនូវកម្មវិធីវិទ្យុស្តីពីបញ្ហា ភ.ដ.ព.ប ក្នុងរយៈពេលពីរខែម្តង រួមមានការទូរស័ព្ទចូលក្នុងកម្មវិធីវិទ្យុបានទទួលនូវជោគជ័យ ដែលនាំឲ្យមានការជជែកពិភាក្សាយ៉ាងបើកចំហរអំពីបញ្ហាផ្សេងៗរបស់ ភ.ដ.ព.ប។ ម.ស.ម.ក ក៏តែងតែចេញនូវសេចក្តីថ្លែងការណ៍ជាទៀងទាត់ដែលត្រូវបានសារព័ត៌មានយកទៅផ្សព្វផ្សាយ ឧទាហរណ៍ដូចជា សេចក្តីថ្លែងការណ៍អំពាវនាវឲ្យមានសមភាព និងសិទ្ធិមិនទទួលរងនូវការរើសអើងសម្រាប់ក្រុម ភ.ដ.ព.ប នៅកន្លែងធ្វើការដើម្បីស្វាគមន៍នូវទិវាពលកម្មអន្តរជាតិ ឆ្នាំ២០១២។[102] សេចក្តីថ្លែងការណ៍នេះត្រូវបានចេញបន្ទាប់ពីការបោះពុម្ពផ្សាយមួយចំនួន រួមទាំង បទសម្ភាសន៍របស់ លោក ហែម សុខលី អតីតមន្ត្រីសម្របសម្រួលគម្រោង និន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ ក្នុង *សារព័ត៌មាន ឌឺ ខេមបូឌា ដេលី* ដែលបង្ហាញពីឥទ្ធិពលវិជ្ជមានអំពីការតស៊ូមតិលើបណ្តាញផ្សព្វផ្សាយបែបនេះ។ ចាប់តាំងពីឆ្នាំ២០០៩ អង្គការនៅកម្ពុជា រួមទាំង ម.ស.ម.ក ផងដែរ បានរៀបចំនូវព្រឹត្តិការណ៍មួយចំនួនក្នុងខែឧសភា ដើម្បីអបអរសាទរទិវាសប្តាហ៍នៃមោទនភាព និងលើកកម្ពស់ការយល់ដឹងនៅកម្ពុជា។ ទិវាសប្តាហ៍នៃមោទនភាព ឆ្នាំ២០១២ បានរៀបចំនូវការ

---

[99]ណាអូមី ហ្វូនថាណូ 'សង្គមនៃស្ត្រីប្តូរភេទក្នុងប្រទេសហ្វីលីពីន រយៈពេល១០ឆ្នាំ ៖ មួយទស្សវត្សរ៍នៃការគាំទ្រ សមាគមស្ត្រី និងភាពជាបងប្អូនស្រី' (*ប្លុករបស់សង្គមនៃស្ត្រីប្តូរភេទក្នុងប្រទេសហ្វីលីពីន*ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១២) <http://strapmanila.blogspot.com/2012/02/strap-turns-10-decade-of-support.html>។

[100]ក្រុមពណ៌ឥន្ទធនូ<www.colorsrainbow.com/>។

[101]មកទល់ខែកញ្ញា ឆ្នាំ២០១២ អត្រាអ្នកប្រើប្រាស់អ៊ិនធើណែតនៅកម្ពុជា គឺប្រហែលជា ៣.១%។ ប៉ុន្តែ អត្រាប្រើប្រាស់អ៊ិនធើណែតគឺកើនឡើងជាបន្តបន្ទាប់ ៖ ធនាគារពិភពលោករាយការណ៍ថាអ្នកប្រើប្រាស់អ៊ិនធើណែតនៅកម្ពុជាកើនឡើងពី ១៧៨.១៤២នាក់ ក្នុងឆ្នាំ២០១០ ទៅ ៤៤៣.៤៦១នាក់ ក្នុងឆ្នាំ២០១១។ ចូស៊ូរ វីលវ៉ល 'ចំនួនអ្នកប្រើប្រាស់អ៊ិនធើណែតកើនឡើងលើសពីពីរដងធៀបនឹងឆ្នាំមុន' *សារព័ត៌មាន ឌឺ ខេមបូឌា ដេលី* ថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១២។

[102]ម.ស.ម.ក 'ម.ស.ម.ក អំពាវនាវឲ្យមានសមភាព និងគ្មានការរើសអើងសម្រាប់ ភ.ដ.ព.ប ក្នុងវិស័យការងារ' (សេចក្តីថ្លែងការណ៍) (ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១២) <www.cchrcambodia.org/media/files/press_release/245_202ccfeandflgbatp%28l%29iee_en.pdf>។

បញ្ចាំងភាពយន្ត ការតាំងពិពណ៌សិល្បៈ ពិធីជប់លៀង ពិធីបុណ្យសាសនា សិក្ខាសាលា និងកិច្ចពិភាក្សាតុមូល ទាំងនៅទីក្រុងភ្នំពេញ និងខេត្តសៀមរាប។[103]

ដើម្បីបង្កើននូវការតស៊ូមតិ និងផ្តល់នូវធនធានសម្រាប់បណ្តាល ភ.ដ.ព.ប នៅកម្ពុជា ម.ស.ម.ក នឹងសម្ពោធនូវ "វេបសាយឥន្ទធនូខ្មែរ" ("វេបសាយ") សម្រាប់កម្ពុជានៅដើមឆ្នាំ២០១៣។វេបសាយនឹងដើរតួជាឧបករណ៍ជាក់លាក់សម្រាប់ការចែករំលែកព័ត៌មាន រួមជាមួយនឹងគោលបំណងឲ្យសហគមន៍ ភ.ដ.ព.ប ចាត់ទុកខ្លួនឯងជាម្ចាស់លើវេបសាយ និងរួមចំណែកក្នុងការអភិវឌ្ឍន៍វេបសាយនេះទាំងអស់គ្នា។ បន្ថែមពីនោះទៀត កម្មវិធីទូរទស្សន៍លើអ៊ិនធើណែត មានសក្តានុពលយ៉ាងធំសម្បើមក្នុងការអភិវឌ្ឍន៍វេបសាយ ៖ វីដេអូអប់រំខ្លីៗ ការផ្សាយបន្តផ្ទាល់នៃកម្មវិធីវិទ្យុ និងកិច្ចពិភាក្សាតុមូល កម្មវិធីព័ត៌មាន ភាពយន្តឯកសារ និងប្រភេទវិដេអូដែលពាក់ព័ន្ធនឹងសិទ្ធិរបស់ក្រុម ភ.ដ.ព.ប នឹងអាចត្រូវបានផ្សព្វផ្សាយតាមវេបសាយនេះ ដើម្បីបង្កើននូវលទ្ធភាពទទួលព័ត៌មានអំពីបញ្ហា ភ.ដ.ព.ប សំខាន់ៗ។ មួយវិញទៀត ការបោះពុម្ពផ្សាយអាចបំពេញបន្ថែមមកលើវេបសាយក្នុងការចូលទៅដល់ក្រុមសកម្មជន បុគ្គល និងសហគមន៍ ភ.ដ.ព.ប ដែលគ្មានលទ្ធភាពប្រើប្រាស់អ៊ិនធើណែត។

**អនុសាសន៍សម្រាប់សង្គមស៊ីវិល៖ ធ្វើការយ៉ាងជិតស្និទ្ធជាមួយនឹងភ្នាក់ងារសារព័ត៌មាន រួមទាំង ស្ថានីយទូរទស្សន៍ កាសែត ទស្សនាវដ្តី និងស្ថានីយវិទ្យុ ដើម្បីលើកកម្ពស់នូវរូបភាពបែបវិជ្ជមាន និងរូបភាពបែបផ្តល់អំណាចសម្រាប់ក្រុម ភ.ដ.ព.ប ផ្ទាល់ និងបញ្ហារបស់ពួកគេ ទាំងនៅក្នុងព័ត៌មាន រឿងប្រលោមលោក ឬភាពយន្តឯកសារ។**

**អនុសាសន៍សម្រាប់សង្គមស៊ីវិល៖ រើសបុគ្គលិកជាសមាជិកនៃក្រុម ភ.ដ.ព.ប ដែលល្បីឈ្មោះ ឬអ្នកគាំទ្រពីបញ្ហា ភ.ដ.ព.ប ដើម្បីដើរតួជាអ្នកតស៊ូមតិ និងធ្វើការជាមួយបណ្តាញសារព័ត៌មានដើម្បីលើកបង្ហាញពីការគាំទ្ររបស់ពួកគេ។**

**អនុសាសន៍សម្រាប់សង្គមស៊ីវិល៖ បង្កើតនូវកម្មវិធីផ្តល់ពានរង្វាន់ដើម្បីលើកសរសើរ បុគ្គល ឬស្ថាប័នដែលធ្វើការលុបបំបាត់ការរើសអើងប្រឆាំងនឹងក្រុម ភ.ដ.ព.ប។**

**អនុសាសន៍សម្រាប់សង្គមស៊ីវិល៖ ពង្រឹង និងធ្វើសមាហរណកម្មបណ្តាញ ភ.ដ.ព.ប ទៅក្នុងសកម្មភាពសារព័ត៌មាននៅកម្ពុជា តាមរយៈការបង្កើតនូវទស្សនាវដ្តីជាទៀងទាត់ បង្កើនចំនួនដងនៃការចេញសេចក្តីថ្លែងការណ៍ ទាក់ទងនឹងសកម្មភាពរបស់បណ្តាញ ភ.ដ.ព.ប និងព្រឹត្តិការណ៍ថ្មីៗ អភិវឌ្ឍន៍បន្ថែមនូវវេបសាយឥន្ទធនូខ្មែរ និងផលិតនូវទូរទស្សន៍តាមប្រព័ន្ធអ៊ិនធើណែត ឬភាពយន្ត។**

[103]អានរបៀបវារៈ ៖www.camboguide.com/lifestyle/gay-cambodia/gay-pride-cambodia-2012-agenda។

# ៥. សេចក្តីសន្និដ្ឋាន

ការកែប្រែឬការអនុម័តច្បាប់ដែលពាក់ព័ន្ធអាចជាជំនួយដ៏សំខាន់ក្នុងការផ្លាស់ប្តូរគំនិតនិងទស្សនៈរើសអើងរបស់សាធារណជនលើក្រុមភ.ដ.ព.ប ហើយធ្វើដូច្នេះអាចផ្តួចផ្តើមឲ្យមានការផ្លាស់ប្តូរជាវិជ្ជមានក្នុងជីវភាពរបស់ភ.ដ.ព.ប ដែលកំពុងតែបន្តប្រឈមនិងការរើសអើងក្នុងជីវិតប្រចាំថ្ងៃរបស់ពួកគេ។ ។ កម្ពុជាបានឈានមកដល់ចុងបញ្ចប់នៃតួនាទីជាប្រធានអាស៊ានរបស់ខ្លួនក្នុងឆ្នាំនេះ ប៉ុន្តែនេះគឺជាឱកាសដ៏ល្អបំផុតដើម្បីឆ្លៀតឱកាសសម្រាប់ រដ្ឋាភិបាលដើម្បីដឹកនាំ និងជះឥទ្ធិពលដល់រដ្ឋាភិបាលដទៃទៀត និងគំនិតរបស់សាធារណជនក្នុងតំបន់ទាំងមូល។

ដើម្បីបង្កើតនូវសង្គមដែលមានសមភាពពិតប្រាកដ ដែលប្រជាពលរដ្ឋនិមួយៗអាចក្លាយទៅជាអ្វីដែលពួកគេចង់ក្លាយជា ហើយនឹងមិនទទួលរងនូវផលប៉ះពាល់នានា គឺមានតម្រូវការចាំបាច់ដើម្បីបង្កើតនូវយន្តការផ្នែកច្បាប់ដែលការពារ និងលើកដម្កើងយ៉ាងពេញទំហឹងលើសិទ្ធិរបស់ ភ.ដ.ព.ប នៅកម្ពុជា។ រដ្ឋាភិបាលអាចធ្វើវិសោធនកម្មលើរដ្ឋធម្មនុញ្ញ ក៏ដូចជា អនុម័តនូវច្បាប់ថ្មីដែលដោះស្រាយជាពិសេសលើសិទ្ធិក្រុម ភ.ដ.ព.ប និងចាត់ទុកការរើសអើងដែលផ្អែកលើនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ និងបទឧក្រិដ្ឋបង្កដោយភាពស្អប់ខ្ពើមជាបទល្មើសព្រហ្មទណ្ឌ។ បន្ថែមពីលើនោះទៀត រដ្ឋាភិបាលត្រូវតែចាត់វិធានការឲ្យបានសមស្របដើម្បីធានាថាច្បាប់ ឬគោលនយោបាយបច្ចុប្បន្ន នឹងមិនត្រូវបានប្រើប្រាស់ដើម្បីរើសអើងមកលើក្រុម ភ.ដ.ព.ប។ បន្ថែមពីលើការអនុម័តច្បាប់ដែលពាក់ព័ន្ធនឹងការប្រឆាំងការរើសអើង ដែលរួមបញ្ចូលនូវយន្តការដ៏មានប្រសិទ្ធភាពក្នុងការអនុវត្តន៍ច្បាប់ទាំងនោះ រដ្ឋាភិបាលអាចចូលរួមលើកកម្ពស់ការយល់ដឹងអំពីក្រុម ភ.ដ.ព.ប និងបញ្ហារបស់ពួកគេ និងផ្តួចផ្តើមនូវការអប់រំសម្រាប់មន្ត្រីរដ្ឋាភិបាល និងអាជ្ញាធរដែលប្រើប្រាស់ច្បាប់បច្ចុប្បន្នដោយបំពាន។

មានការកើតឡើងនូវបណ្តាញ ភ.ដ.ព.ប នៅកម្ពុជា ដែលបានបង្កើតនូវសកម្មភាពបែបវិជ្ជមានដើម្បីតស៊ូរកសិទ្ធិសម្រាប់ក្រុម ភ.ដ.ព.ប។ បណ្តាញនេះអាចទទួលបានផលប្រយោជន៍ពីការលូតលាស់ និងការពង្រឹងបន្ថែម តាមរយៈការបង្កើនធនធាន សមាជិក និងការបង្កើនសមត្ថភាព។ បណ្តាញ ភ.ដ.ព.ប ដែលចងភ្ជាប់យ៉ាងខ្លាំង ដែលប្រកាន់យកនូវទស្សនវិស័យដូចគ្នា អាចជួយឲ្យមានការផ្លាស់ប្តូរក្នុងសង្គម តស៊ូមតិដើម្បីកាត់បន្ថយការរើសអើង និងលើកកម្ពស់ការគោរពដល់ក្រុម ភ.ដ.ព.ប និងសិទ្ធិរបស់ពួកគេ។ បណ្តាញនេះអាចនឹងត្រូវបានគាំទ្រតាមរយៈការធ្វើសមាហរណកម្មទៅក្នុងកិច្ចខិតខំប្រឹងប្រែងថ្នាក់តំបន់ និងថ្នាក់អន្តរជាតិ ដើម្បីលើកកម្ពស់ និងការពារសិទ្ធិរបស់ក្រុម ភ.ដ.ព.ប ដោយមានការបណ្តុះបណ្តាលបន្ថែម រួមទាំងបណ្តុះបណ្តាលវិជ្ជាជីវៈ និង ចែករំលែកធនធាន។

អង្គការសង្គមស៊ីវិល រួមទាំង អង្គការ ភ.ដ.ព.ប ឬ អង្គការមកពីវិស័យដទៃ រួមមាន សុខភាព ការអប់រំ និងបណ្តាញសារព័ត៌មាន គឺជាកន្លែងដ៏ស័ក្តិសមក្នុងការបង្កើត និងអនុវត្តនូវការផ្តួចផ្តើមដែលអាចធ្វើទៅបានដើម្បីឲ្យមានការផ្លាស់ប្តូរ។ វិស័យចម្បងៗដែលត្រូវយកចិត្តទុកដាក់ គួរតែរាប់បញ្ចូលនូវការធ្វើការជាមួយ (១) ក្រុមគ្រួសារដើម្បីជួយកាត់បន្ថយការរើសអើង និងបង្កើនការទទួលស្គាល់ (២) និយោជក និងធុរកិច្ចដើម្បី

បញ្ចូលនូវគោលនយោបាយជានានូវសមភាពនៅកន្លែងការងារ (៣) បណ្ដាញសារព័ត៌មានដើម្បីបង្កើនរូបភាព និងរឿងរ៉ាវជាវិជ្ជមានសម្រាប់ក្រុម ភ.ដ.ព.ប និង (៤) វិស័យសុខភិបាលដើម្បីឲ្យមានការយល់ចិត្ត និងបណ្ដុះបណ្ដាលអ្នកផ្ដល់សេវាសុខភាពដើម្បីអាចផ្ដល់នូវសេវាសុខភាពដែលប្រសើរ និងមានលក្ខណៈជំនាញសម្រាប់ឲ្យដល់អ្នកជំងឺដែលជាក្រុម ភ.ដ.ព.ប។

ចុងបញ្ចប់ ការផ្លាស់ប្ដូរឥរិយាបថគឺជាចំណុចសំខាន់ គឺជាអ្វីដែលអាចសម្រេចបានយ៉ាងជោគជ័យបំផុតតាមរយៈយុទ្ធនាការអប់រំ រួមទាំងប៉ុន្តែមិនកម្រិតត្រឹមតែ យុទ្ធនាការតស៊ូមតិ និងបណ្ដាញសារព័ត៌មានដែលដៅមុខសញ្ញាទៅលើសាធារណជនទូទៅ ប៉ុន្តែក៏ត្រូវបង្កើនការយល់ដឹងពីក្រុម ភ.ដ.ព.ប និងសិទ្ធិរបស់ពួកគេនៅក្នុងសាលា និងសាកលវិទ្យាល័យផងដែរ។ ជាចុងក្រោយ គឺតម្រូវឲ្យមានសកម្មភាពទាំងពីសំណាក់ រដ្ឋាភិបាល និងសង្គមស៊ីវិលដើម្បីកាត់បន្ថយនូវការរើសអើងមកលើក្រុម ភ.ដ.ព.ប ដើម្បីឲ្យពួកគេអាចមានកន្លែងរបស់ពួកគេរួមជាមួយនឹងប្រជាពលរដ្ឋទូទៅនៅកម្ពុជា និងមានអារម្មណ៍ថាមានអំណាចគ្រប់គ្រាន់ និងទទួលបានការការពារ ដើម្បីឲ្យពួកគេអាចរួមចំណែកយ៉ាងពេញលេញទៅក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គម និងវប្បធម៌ក្នុងប្រទេស។ តាមរយៈការប្រកាន់យកនូវតម្លៃនៃការអត់ឱន និងភាពចម្រុះ កម្ពុជានឹងក្លាយទៅជាប្រទេសដែលមានបាន និងរស់រវើក ហើយនឹងអាចបង្កើតខ្លួនឯងឲ្យទៅជាពន្លឺភ្លើងនាំមុខក្នុងតំបន់បាន។

# ៦. គន្ថនិទ្ទេស

## ច្បាប់ជាតិ

ច្បាប់

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា (ឆ្នាំ១៩៩៣ និងធ្វើវិសោធនកម្មឡើងវិញ)

ក្រមនីតិវិធីព្រហ្មទណ្ឌ (ឆ្នាំ២០០៧)

ច្បាប់ការងារនៃព្រះរាជាណាចក្រកម្ពុជា (ឆ្នាំ១៩៩៧)

ច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ (ឆ្នាំ១៩៨៩)

ច្បាប់ស្តីពីការគ្រប់គ្រងថ្នាំញៀន (ឆ្នាំ២០០៥)

ច្បាប់ស្តីពីការទប់ស្កាត់អំពើជួញដូរ និងការកេងប្រវ័ញ្ចផ្លូវភេទ (ឆ្នាំ២០០៨)

ក្រមព្រហ្មទណ្ឌ (ឆ្នាំ២០០៩)

## សេចក្តីសម្រេច

សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា លេខ០៩២/០០៣/២០០៧ (ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧)

## គោលនយោបាយ

ក្រសួងអប់រំ យុវជន និងកីឡា របស់រដ្ឋាភិបាល 'ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឆ្នាំ២០០៩ -២០១៣' (ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១០)

ក្រសួងកិច្ចការនារី 'នារីរតនៈ III' (ឆ្នាំ ២០០៩)

## ច្បាប់ និងករណីយុត្តាធិការពីប្រទេសដទៃ

ច្បាប់ប្រព្រឹត្តកម្មស្មើភាព ឆ្នាំ១៩៩៤ (ហូឡង់)

ច្បាប់សមភាព ឆ្នាំ ២០១០ (ចក្រភពអង់គ្លេស)

ច្បាប់និន្នាភេទ និងមិនរើសអើងរដ្ឋញូយ៉ក ឆ្នាំ២០០៣ (សហរដ្ឋអាមេរិក)

ច្បាប់សិទ្ធិមនុស្សរដ្ឋញូយ៉ក (ច្បាប់និតិប្រតិបត្តិរដ្ឋញូយ៉ក មាត្រា១៥ ផ្នែក២៩០-៣០១ (សហរដ្ឋអាមេរិក)

"មូលដ្ឋានណាស់ និងរដ្ឋាភិបាល" ឆ្នាំ២០១០ CriLJ ៩៤. ១៦០ (២០០៩) DLT ២៧៧ (ប្រទេសឥណ្ឌា)

## ច្បាប់ និងលិខិតូបករណ៍អន្តរជាតិ

*សន្ធិសញ្ញា និងកិច្ចព្រមព្រៀងអន្តរជាតិ*

កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦ ចូលជាធរមាននៅថ្ងៃទី២៣ ខែមិនា ឆ្នាំ១៩៧៦)

កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (អនុម័តនៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦)

សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស (អនុម័តនៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤៨)

អនុសញ្ញានៃអង្គការពលកម្មអន្តរជាតិ ស្តីពីការលុបបំបាត់ការរើសអើងពាក់ព័ន្ធនឹងការងារ និងអាជីព ( អនុម័តថ្ងៃទី២៥ ខែមិថុនា ឆ្នាំ១៩៥៨ ចូលជាធរមាននៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៦០)

***ករណីច្បាប់ និងសេចក្តីសម្រេច***

គណៈកម្មការអង្គការសហប្រជាជាតិស្តីពីស.ស.ស.វ "សេចក្តីអធិប្បាយលេខ២៧ ចែងក្នុងសេចក្តីអធិប្បាយទូទៅលេខ២០ ស្តីពី ″ការមិនរើសអើងចំពោះសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌″ (មាត្រា២ ឃ្លាទី២ នៃក.អ.ស.ស.ស.វ″ (ចេញផ្សាយថ្ងៃទី ០២ ខែកក្កដា ឆ្នាំ២០០៩) ឯកសាររបស់អង្គការសហប្រជាជាតិ /C.12/GC/20

គណៈកម្មការអង្គការសហប្រជាជាតិស្តីពីស.ស.ស.វ "មតិយោបល់លេខ១២ ក្នុង 'សេចក្តីអធិប្បាយលេខ១៨៖ សិទ្ធិក្នុងការទទួលបានការងារ (មាត្រា៦ នៃ ក.អ.ស.ស.ស.វ)′(ថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០០៦) ឯកសាររបស់អង្គការសហប្រជាជាតិE/C.12/GC/18

សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស (ឆ្នាំ២០១១) ឯកសាររបស់អង្គការសហប្រជាជាតិ A/HRC/17/L.9/Rev.1

## *លិខិតុបករណ៍អន្តរជាតិដទៃទៀត*

គោលការណ៍យ៉ូកយ៉ាការ៉ាតា នៃការអនុវត្តច្បាប់សិទ្ធិមនុស្សអន្តរជាតិ ស្តីពីនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ (ថ្ងៃទី២៦ ខែមិនា ឆ្នាំ២០០៧)។

## របាយការណ៍ និងឯកសារបោះពុម្ពផ្សាយ

សហជីពពលរដ្ឋសេរីអាមេរិក "តម្លៃខ្ពស់ពេកហើយ៖ករណីប្រឆាំងនឹងឪពុកម្តាយដែលជាអ្នកស្រឡាញ់ភេទដូចគ្នាដែលមានភាពរឹតត្បិត (របាយការណ៍) ឆ្នាំ២០០៦។<www.aclu.org/lgbt-rights_hiv-aids/too-high-price-case-against-restricting-gay-parenting>

សមភាពអាពាហ៍ពិពាហ៍របស់ប្រជាពលរដ្ឋអូស្ត្រាលី "ការសាកល្បងដែលបរាជ័យមួយ៖ ហេតុអ្វីបានជាសម្ព័ន្ធតាមរយៈការចុះអ៊ីតាស៊ីវិលមិនអាចជំនួសឲ្យសមភាពអាពាហ៍ពិពាហ៍បាន" (សលកប័ត្រ) ឆ្នាំ២០១០ ។ <www.australianmarriageequality.com/wp/wp-content/uploads/2010/12/A-failed-experiment.pdf>

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា "កម្រងសលកប័ត្រស្ថាប័ន៖ ការបែងចែកអំណាច និងនីតិរដ្ឋ" (សលកប័ត្រឆ្នាំ ២០១១)
<www.cchrcambodia.org/index_old.php?url=media/media.php&p=factsheet_detail.php&fsid=3&id=5> ។

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ៖ "ការធ្វើចំណាត់ថ្នាក់ច្បាប់របស់ ម.ស.ម.ក ៖ គោលនយោបាយភូមិឃុំមានសុវត្ថិភាព" (សលាកប័ត្រព័ត៌មាន)(ខែមករា ឆ្នាំ២០១២)
<www.cchrcambodia.org/index_old.php?url=media/media.php&p=factsheet_detail.php&fsid=27&id=5>។

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ៖ "សារព័ត៌មានបែបទំនើប និងការលើកស្ទួយសិទ្ធិមនុស្សនៅកម្ពុជា" (របាយការណ៍) ឆ្នាំ២០១២។

<www.cchrcambodia.org/index_old.php?url=media/media.php&p=report_detail.php&reid=79&id=5>

មជ្ឈមណ្ឌលសម្រាប់ការរីកចម្រើនរបស់ជនជាតិអាមេរិក"របៀបបិទចន្លោះភាពខុសគ្នាផ្នែកសេវាសុខភាពសម្រាប់ ភ.ដ.ព.ប" (កំណត់ហេតុសង្ខេប) (ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៩)<www.americanprogress.org/wp-content/uploads/issues/2009/12/pdf/lgbt_health_disparities.pdf>។

អង្គការអន្តរជាតិសុខភាពគ្រួសារ "អាកប្បកិរិយាផ្លូវភេទ មេរោគឆ្លងតាមរយៈការរួមភេទ និងជំងឺអេដស៍ក្នុងចំណោមបុរសដែលមានទំនាក់ទំនងផ្លូវភេទជាមួយបុរសដូចគ្នា នៅទីក្រុងភ្នំពេញ" (កម្ពុជា ឆ្នាំ២០០០) ទំព័រ ៦។ <www.fhi360.org/en/HIVAIDS/pub/survreports/MSMCambodia/index.htm>។

សម្ព័ន្ធអ្នកស្រលាញ់ភេទដូចគ្នាប្រឆាំងនឹងការបរិហារកេរ្តិ៍ `សន្ទស្សន៍ការទទួលខុសត្រូវរបស់បណ្តាញសារព័ត៌មាន ឆ្នាំ២០១១- ២០១២´ (ខែសីហា ឆ្នាំ២០១២) <www.glaad.org/publications/nri>។

ភីតធី ហ្គ័រដេន `ការពិនិត្យឡើងវិញនូវការនិយាយបង្អាប់លេងសើចក្នុងវិទ្យាស្ថានអប់រំ´ (របាយការណ៍ឧបត្ថម្ភដោយ យូណេស្កូ និងរៀបចំសម្រាប់កិច្ចពិភាក្សាថ្នាក់អន្តរជាតិនៅទីក្រុងរីអូ ដឺ ចេនីរ៉ូ ប្រទេស ប្រេស៊ីល ថ្ងៃទី ៦ -៩ ខែធ្នូ ឆ្នាំ២០១១ បោះពុម្ពឆ្នាំ២០១២)
<http://unesdoc.unesco.org/images/0021/002157/215708e.pdf>។

ភីតធី ហ្គ័រដេន `ការពិនិត្យឡើងវិញនូវការនិយាយបង្អាប់លេងសើចក្នុងវិទ្យាស្ថានអប់រំ´ (របាយការណ៍ឧបត្ថម្ភដោយ យូណេស្កូ និងរៀបចំសម្រាប់កិច្ចពិភាក្សាថ្នាក់អន្តរជាតិនៅទីក្រុងរីអូ ដឺ ចេនីរ៉ូ ប្រទេស ប្រេស៊ីល ថ្ងៃទី ៦ -៩ ខែធ្នូ ឆ្នាំ២០១១ បោះពុម្ពឆ្នាំ២០១២)
<http://unesdoc.unesco.org/images/0021/002157/215708e.pdf>។

អង្គការឃ្លាំមើលសិទ្ធិមនុស្ស `"យើងនឹងបង្ហាញអ្នកថាអ្នកគឺជាស្ត្រី" ៖ ហិង្សា និងការរើសអើងមកលើស្ត្រីស្រលាញ់ស្ត្រីស្បែកខ្មៅ និងបុរសប្តូរភេទនៅអាហ្វ្រិកខាងត្បូង´ (របាយការណ៍) (ថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០១១)
<www.hrw.org/reports/2011/12/05/we-ll-show-you-you-re-woman>។

សមាគមអ្នកស្រលាញ់ភេទដូចគ្នា អ្នកស្រលាញ់ភេទទាំងពីរ អ្នកប្តូរភេទ និងអន្តរភេទ`សុខភាពរបស់ស្ត្រីស្រលាញ់ស្ត្រី ៖ អាថ៌កំបាំង និងការពិត´ (ខែកញ្ញា ឆ្នាំ២០១១) <www.iglhrc.org/binary-data/ATTACHMENT/file/000/000/539-1.pdf>។

អ៊ិលហ្គា "ការស្អប់ខ្ពើមអ្នកស្រឡាញ់ភេទដូចគ្នាដែលជម្រុញដោយរដ្ឋមានសមត្ថកិច្ច៖ ការស្ទាបស្ទង់មតិជាសកលមួយជុំវិញបញ្ញត្តិដែលដាក់ការរួមភេទរបស់បុគ្គលវ័យជំទង់ស្រឡាញ់ភេទដូចគ្នា ជាបទឧក្រិដ្ឋ" ចេញផ្សាយនាខែឧសភា ឆ្នាំ២០១២
<http://old.ilga.org/Statehomophobia/ILGA_State_Sponsored_Homophobia_2012.pdf> ។

សហព័ន្ធអន្តរជាតិរៀបចំផែនការគ្រួសារ`ប័ណ្ណរាយការណ៍ស្តីពីការពារមេរោគអេដស៍សម្រាប់ បុរសរួមភេទជាមួយបុរស និងអ្នកប្តូរភេទ ៖ កម្ពុជា´(ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១១)
www.msmgf.org/index.cfm/id/11/aid/4648។

ក្រសួងអប់រំ យុវជន និងកីឡា `ស្ថិតិ និងសូចនាករអប់រំ ២០១០ -២០១១´(ខែមិនា ឆ្នាំ២០១១)
<http://moeys.gov.kh/km/component/joomdoc/doc_download/32-education-statistics-and-indicators2010-2011-kh.html>

កម្មវិធីជាតិចម្រុះប្រឆាំងនឹងអំពើហិង្សា `អំពើហិង្សាបង្កដោយភាពស្អប់ខ្ពើមមកលើ សហគមន៍ស្ត្រីស្រលាញ់ស្ត្រី បុរសស្រលាញ់បុរស អ្នកស្រលាញ់ទាំងពីរភេទ អ្នកប្តូរភេទ អ្នករួមភេទដូចគ្នានៅសហរដ្ឋអាមេរិក ឆ្នាំ២០១០´

(ឆ្នាំ២០១១)
<http://avp.org/documents/NCAVPHateViolenceReport2011Finaledjlfinaledits.pdf>។

របាយការណ៍របស់លោកស្រី ណាវី ភីឡៃ ស្តីអំពី "របាយការណ៍របស់ឧត្តមស្នងការជាន់ខ្ពស់ទទួលបន្ទុកសិទ្ធិមនុស្ស ស្តីពីច្បាប់និងការអនុវត្តិបែបរើសអើង និងទង្វើប្រកបដោយភាពហឹង្សាលើបុគ្គលដោយហេតុតែនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័ររបស់ពួកគេ" ចេញផ្សាយថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១១។ ឯកសាររបស់អង្គការសហប្រជាជាតិ A/HRC/19/41
<www.ohchr.org/Documents/HRBodies/HRCouncil/RegularSession/Session19/A-HRC-19-41_en.pdf>

ទីម៉ូធី ប៊ិបឡា និងជូឌិត ស្តេស៊ី "តើយេនឌ័រ និងឪពុកម្តាយពាក់ព័ន្ធគ្នាយ៉ាងណា?" (២០១០) ៧២.១ ព្រឹត្តប័ត្រអាពាហ៍ពិពាហ៍ និងគ្រួសារ លេខ៣ ។ ។ ស្តូនវល យូខេ "គ្រួសារខុសប្លែកគ្នា៖ បទពិសោធន៍កូននៅជាមួយឪពុកម្តាយដែលជាស្ត្រីស្រឡាញ់ស្ត្រី និងបុរសស្រឡាញ់បុរស" (របាយការណ៍) ឆ្នាំ ២០១០។
<www.stonewall.org.uk/what_we_do/research_and_policy/health_and_healthcare/3471.asp>

មណ្ឌលការពារការធ្វើអត្តឃាត 'ការប្រឈមនៃការធ្វើអត្តឃាត និងការការពារសម្រាប់ យុវជនដែលជា ស្ត្រីស្រលាញ់ស្ត្រី បុរសស្រលាញ់បុរស អ្នកស្រលាញ់ទាំងពីរភេទ និងអ្នកប្តូរភេទ' (ឆ្នាំ២០០៨)
<www.sprc.org/sites/sprc.org/files/library/SPRC_LGBT_Youth.pdf>។

ការិយាល័យឧត្តមស្នងការសហប្រជាជាតិស្តីពីសិទ្ធិមនុស្ស 'កើតមកដោយសេរី និងស្មើភាព ៖ និន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ ក្នុងច្បាប់សិទ្ធិមនុស្សអន្តរជាតិ' (ខែកញ្ញា ឆ្នាំ២០១២) ៥១
<www.ohchr.org/Documents/Publications/BornFreeAndEqualLowRes.pdf>។

អង្គការសុខភាពពិភពលោក 'ទម្រង់នៃការផ្តល់សេវាសុខភាព ៖ កម្ពុជា ២០១២' (ឆ្នាំ២០១២)
<www.wpro.who.int/health_services/service_delivery_profile_cambodia.pdf>។

## សុន្ទរកថា និងកិច្ចសម្ភាសន៍

សេចក្តីថ្លែងការណ៍របស់លោកស្រី ណាវី ភីឡៃ ស្តីអំពី "សេចក្តីថ្លែងការណ៍របស់លោកស្រី ណាវី ភីឡៃ ឧត្តមស្នងការជាន់ខ្ពស់ទទួលបន្ទុកសិទ្ធិមនុស្ស ដាក់ជូនក្រុមការងារជុំវិញកិច្ចបញ្ចប់អំពើហឹង្សា និងការរើសអើងប្រឆាំងនឹងបណ្តាជនដោយសារតែនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័ររបស់ពួកគេ"(កិច្ចប្រជុំក្រុមប្រឹក្សាសិទ្ធិមនុស្សលើកទី១៩ នាថ្ងៃទី០៧ ខែមិនា ឆ្នាំ២០១២)។
<www.ohchr.org/en/NewsEvents/Pages/DisplayNews.aspx?NewsID=11917&LangID=E>.

បទអន្តរាគមន៍របស់លោកស្រីហ៊ីឡារី គ្លីនតុន "ប្រសាសន៍ទទួលស្គាល់ទិវាសិទ្ធិមនុស្សអន្តរជាតិ" (សាលអង្គការសហប្រជាជាតិ នៅហ្សឺណែវ នៃប្រទេសស្វីស នាថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១១ ។
<www.state.gov/secretary/rm/2011/12/178368.htm>

បទអន្តរាគមន៍របស់លោកប៉ារ៉ាក់ អូបាម៉ា "ប្រសាសន៍របស់ប្រធានាធិបតីក្នុងព្រឹត្តការណ៍យុទ្ធនាការមួយ" (សារៈមន្ទីរសិល្បៈរូប៊ីន នៅទីក្រុងញូយ៉ក នាថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០១២ ។ <www.whitehouse.gov/the-press-office/2012/05/14/remarks-president-campaign-event>

## អត្ថបទ និងសេចក្តីថ្លែងការណ៍

ថូម៉ាស់ អាដាស៊ុន "ការងាកមើលលើអាពាហ៍ពិពាហ៍អ្នកស្រឡាញ់ភេទដូចគ្នា និងការអនុម័តច្បាប់ជាទូទៅនៅពិភពលោក" អាស្សូស៊ីអេតធិដប្រេស (ចេញផ្សាយថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១២)។
<http://news.yahoo.com/look-gay-marriage-adoption-worldwide-154940786.html>

ចេសុន អាមប្រ៊ីដ "ការផ្លាស់ប្តូរភេត និងច្បាប់របស់ប្រទេសថៃឡង់ដ៍" (វេទិកាច្បាប់ប្រទេសថៃឡង់ដ៍ នាថ្ងៃទី១១ ខែមេសា ឆ្នាំ២០០៨។<http://www.thailawforum.com/Transsexuals-and-Thai-Law.html> ។

សេចក្តីថ្លែងការណ៍របស់វេទិកាភ.ដ.ព.ប.អ.ម.អ "ដាក់បញ្ចូលនិន្នាការភេទ និងសិទ្ធិទៅក្នុងវេទិកាសង្គមស៊ីវិល និងវេទិកាពលរដ្ឋអាស៊ាន និងក្នុងសេចក្តីប្រកាសសិទ្ធិមនុស្សអាស៊ាន" (ឆ្នាំ២០១២) <www.boell-southeastasia.org/downloads/PRESS_RELEASE_-LGBTQI.pdf>។

សេចក្តីថ្លែងការណ៍របស់វេទិកាភ.ដ.ព.ប.អ.ម.អ "សេចក្តីប្រកាសសិទ្ធិមនុស្សអាស៊ានបដិសេធក្នុងការការពារសិទ្ធិរបស់ភ.ដ.ព.ប.អ.ប" (ចេញផ្សាយនៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១២)
<www.sithi.org/temp.php?url=media_view2.php&mid=6095>។

ទីម៉ូធី ប៊ិបឡា និងជូឌិត ស្ទេស៊ី "តើយេនឌ័រ និងឪពុកម្តាយពាក់ព័ន្ធគ្នាយ៉ាងណា?" (២០១០) ៧២.១ ព្រឹត្តប័ត្រអាពាហ៍ពិពាហ៍ និងគ្រួសារ លេខ៣

ជូលី ប៊ិលស៊័រ 'ករណីសុន្ទរកថារបស់អ្នកការពារសិទ្ធិអ្នកស្រលាញ់ភេទដូចគ្នា ចំពោះការទម្លាក់ការចោទប្រកាន់លើម៉ាដូណា' (ឌឹ អែតវ៉ូខេត  ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១២) <www.advocate.com/news/world-news/2012/11/23/russian-gay-rights-speech-case-against-madonna-dismissed>។

អេដម៉ុន ប្រុចន៍ 'តៃវ៉ាន់ ៖ ប្រហែលជាមួយភាគប្រាំនៃចំនួនបុរសស្រលាញ់បុរសមានទំនោរសម្លាប់ខ្លួន' (ព័ត៌មានពណ៌ផ្កាឈូក ថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១២) www.pinknews.co.uk/2012/04/17/taiwan-almost-one-in-five-gay-people-have-attempted-suicide/។

ម.ស.ម.ក 'ម.ស.ម.ក អំពាវនាវឲ្យមានសមភាព និងគ្មានការរើសអើងសម្រាប់ ភ.ដ.ព.ប ក្នុងវិស័យការងារ' (សេចក្តីថ្លែងការណ៍) (ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១២) <www.cchrcambodia.org/media/files/press_release/245_202ccfeandflgbatp%28l%29iee_en.pdf>។

ម.ស.ម.ក "ម.ស.ម.កគូសបញ្ជាក់ពីភាពគ្រោះថ្នាក់ក្នុងការអនុម័តសេចក្តីប្រកាសស្តីពីសិទ្ធិមនុស្សអាស៊ានដែលមានចន្លោះប្រហោង" (សេចក្តីថ្លែងការណ៍ ចេញផ្សាយថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១២) <www.sithi.org/temp.php?url=media_view2.php&mid=6093>។

ចេននី អ័រ ឌីយេ និងភីដទី អ័រ រូឌ្រីដ "ច្បាប់ស្តីពីប្រព្រឹត្តកម្មស្មើភាពគ្នារបស់ទីក្រុងដាចស៍ តាមទ្រឹស្តី និងការអនុវត្តន៍ជាក់ស្តែង" (មជ្ឈមណ្ឌលសិទ្ធិរ៉ូម៉ាសហគមន៍អ៊ឺរ៉ុប ចេញផ្សាយថ្ងៃទី១០ ខែឧសភា ឆ្នាំ២០០៣) www.errc.org/article/the-dutch-equal-treatment-act-in-theory-and-practice/1400> ។

ស្ទីវិន អែលលេនជឺ "ទីស្តីការបារាំងបានដាក់ចេញនូវច្បាប់អាពាហ៍ពិពាហ៍អ្នកស្រឡាញ់ភេទដូចគ្នា ថ្វីបើមានការជំទាស់ពីអ្នកអភិរក្សនិយម" ចេញផ្សាយដោយញូយ៉កថៃមស៍ ថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១២។ <www.nytimes.com/2012/11/08/world/europe/gay-marriage-bill-advances-in-france.html>.

ណាអូមី ហ្វូនថាណូ 'សង្គមនៃស្ត្រីប្តូរភេទក្នុងប្រទេសហ្វីលីពីន រយៈពេល១០ឆ្នាំ ៖ មួយទស្សវត្សរ៍នៃការគាំទ្រសមាគមស្ត្រី និងភាពជាបងប្អូនស្រី' (ប្លុករបស់សង្គមនៃស្ត្រីប្តូរភេទក្នុងប្រទេសហ្វីលីពីនថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១២) <http://strapmanila.blogspot.com/2012/02/strap-turns-10-decade-of-support.html>។

ជេហ្វ្រី ហ្គេថលមែន 'ជនជាតិអ៊ូហ្គង់ដាដែលនិយាយតំណាងឲ្យអ្នកស្រលាញ់ភេទដូចគ្នាត្រូវបានគេវាយដំ'សារព័ត៌មាន ឌឹ ញូវយ៉ក ថាមស៍ ថ្ងៃទី២៧ ខែមករា ឆ្នាំ២០១១ <www.nytimes.com/2011/01/28/world/africa/28uganda.html?_r=0>។

ចេននី អ័រ ឌីយេ និងភីដទី អ័រ រូឌ្រីដ "ច្បាប់ស្តីពីប្រព្រឹត្តកម្មស្មើភាពគ្នារបស់ទីក្រុងដាចស៍ តាមទ្រឹស្តី និងការអនុវត្តន៍ជាក់ស្តែង" (មជ្ឈមណ្ឌលសិទ្ធិរ៉ូម៉ាសហគមន៍អ៊ឺរ៉ុប ចេញផ្សាយថ្ងៃទី១០ ខែឧសភា ឆ្នាំ២០០៣) www.errc.org/article/the-dutch-equal-treatment-act-in-theory-and-practice/1400> ។

ទិវា គាំ និងម៉េងហួង "ដូចគ្នា តែរៀបគ្នា" (ភ្នំពេញប៉ុស្តិ៍ ផ្នែកលីហ្វ ចេញផ្សាយថ្ងៃទី២២ ខែកញ្ញា ឆ្នាំ ២០១០។ <www.phnompenhpost.com/index.php/2010092242205/LIFT/same-same-but-married.html>

អាណា លិច "មនុស្ស៨០០នាក់បានអបអរសាទរភាពចម្រុះបែបនៃនិន្នាការភេទ នៅប្រទេសវៀតណាម" (សារព័ត៌មានហ្គេស្តា ចេញផ្សាយថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១២) <www.gaystarnews.com/article/800-celebrate-sexualities-diversity-vietnam271112>

យុទ្ធនាការសិទ្ធិមនុស្ស សន្ទស្សន៍សមភាពក្នុងសាជីវកម្ម<www.hrc.org/corporate-equality-index/#.ULXYBIZe-Ys>។

1ផាទ្រីក ឃើង ប៉ាស្កាល់ 'ឡាឡាត អនុម័ត 'បើកចិត្ត បើកបេះដូង' ជាពាក្យស្លោកយុទ្ធនាការថ្មី' (រើរ៉ា ហ្វាល់ ថ្ងៃទី២១ ខែមេសា ឆ្នាំ២០១២)<http://ph.news.yahoo.com/blogs/the-inbox/ladlad-adopts-open-mind-open-heart-campaign-slogan-091949933.html>។

ក្រាមេ រីដ "សមយុទ្ធទាមទារសិទ្ធិភ.ដ.ព.បជាសកល" (ក្លូបិល ប៉ុស្តិ៍ ចេញផ្សាយនាថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១១) http://www.globalpost.com/dispatch/news/culture-lifestyle/111101/opinion-the-globalization-lgbt-rights-fight>។

សីលា ហ្សាយ៉ន 'ការចាត់ចំណាត់ថ្នាក់កន្លែងការងាររបស់ ក្រុម ភ.ដ.ព.ប បង្ហាញថាមានការប្រសើរឡើងក្នុងសាជីវកម្មអាមេរិក' (ប្រែនឆាណែល ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១១)<www.brandchannel.com/home/post/2011/12/19/HRC-2012-Corporate-Equality-Index-121911.aspx>។

ចូស្វ៊ែរ វីលវ៉ល 'ចំនួនអ្នកប្រើប្រាស់អ៊ិនធើណែតកើនឡើងលើសពីពីរដងធៀបនឹងឆ្នាំមុន' សារព័ត៌មាន ឌឹ ខេមបូឌា ដេលី  ថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១២។

"ការដាក់អពាហ៍ពិពាហ៍អ្នកស្រឡាញ់ភេទដូចគ្នាឲ្យស្របច្បាប់អាចជម្រុញឲ្យអ្នកស្រឡាញ់ភេទដូចគ្នាមានសុខភាពល្អ" (ព័ត៌មានសុខភាពប្រចាំថ្ងៃ ចេញផ្សាយថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ ២០១១) <http://news.yahoo.com/legalized-same-sex-marriage-may-boost-gay-mens-210409455.html>។

"តុលាការកំពូលរបស់ម៉ិចស៊ីកូ បានចេញដីកាសម្រេចឲ្យមានការទទួលស្គាល់អាពាហ៍ពិពាហ៍អ្នកស្រឡាញ់ភេទដូចគ្នា ទូទៅមួយនៅទូទាំងប្រទេស" (LGBTQ Nation ចេញផ្សាយថ្ងៃទី១០ ខែសីហា ឆ្នាំ២០១០) ។ <www.lgbtqnation.com/2010/08/mexico-supreme-court-orders-gay-marriages-recognized-country-wide/>.

'មន្ត្រីឃោជាវាយប្រហារមកលើសិស្ស' សារព័ត៌មាន ឌឹ ភ្នំពេញប៉ុស្តិ៍ (ភ្នំពេញ ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១១)

'តារាសម្តែងជាស្ត្រីប្តូរភេទអំពាវនាវឲ្យឈប់មានការរើសអើងបន្ទាប់ពីទទួលបានរង្វាន់ជាតារាសម្តែងល្អបំផុតផ្នែកអ្នកស្រលាញ់ភេទដូចគ្នាល្អ' (ឌឹ ខេមបូឌា ដេលី  ថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០១២)

www.thecambodiaherald.com/cambodia/detail/1?page=14&token=ZDYxM2MxYjI0NWEwYWEwZmIwYjA1ZjE3MGZiMTA5

## គេហទំព័រ

ក្រុមអានចារី www.astraeafoundation.org/grants/meet-a-grantee/anjaree

អង្គការឥន្ទធនូបាងកក <www.bangkokrainbow.org/About_Us.html>។

មូលនិធិកើតមកក្នុងរបៀបនេះ ‘បេសកកម្មរបស់យើង’ <http://bornthiswayfoundation.org/pages/our-mission/>។

គណៈកម្មការសិទ្ធិមនុស្ស និងសមភាព <www.equalityhumanrights.com>

សម្ព័ន្ធបុរសស្រឡាញ់បុរស និងស្ត្រីស្រឡាញ់ស្ត្រីប្រឆាំងនឹងការរើសអើង<www.glaad.org>

យុទ្ធនាការសិទ្ធិមនុស្ស <www.hrc.org>

គណៈកម្មការសិទ្ធិមនុស្សអន្តរជាតិដើម្បីអ្នកស្រឡាញ់ភេទដូចគ្នា <www.iglhrc.org>

សមាគមអ្នកស្រឡាញ់ភេទដូចគ្នា អ្នកស្រឡាញ់ភេទទាំងពីរ អ្នកប្តូរភេទ និងអន្តរភេទ <www.ilga.org>

ក្រុមពណ៌ឥន្ទធនូ <www.colorsrainbow.com/>

សង្គមស្ត្រីផ្លាស់ប្តូរភេទនៃហ្វីលីពីន <www.tsphilippines.com/aboutstrap.htm>

ស្ទូនវល <www.stonewall.org.uk/>

# ឧបសម្ព័ន្ធ៖ អង្គការមិនមែនរដ្ឋាភិបាលធ្វើការលើវិស័យសិទ្ធិរបស់បណ្តាជនភ.ដ.ប.ប នៅកម្ពុជា

- បណ្តាញចតុមុខ (“BC”)
- បណ្តាញពលរដ្ឋផ្ទុកមេរោគអេដស៍ (“CPN+”)
- កិច្ចសហប្រត្តិការដើម្បីសេវាសង្គម និងអភិវឌ្ឍន៍ (“CSSD”)
- កញ្ញា
- ខេមរា
- អង្គការខ្មែរអភិវឌ្ឍន៍ដើម្បីសេរីភាព (“KDFO”)
- កិច្ចសហប្រតិបត្តិការស្ត្រីខ្មែរដើម្បីអភិវឌ្ឍន៍ (“KWCD”)
- សេវាសង្គមសុខភាពបុរស (“MHSS”)
- សុខភាពបុរសកម្ពុជា (“MHC”)
- បណ្តាញបុរសស្ត្រីអភិវឌ្ឍន៍កម្ពុជា (“CNMWD”)
- សហគមន៍ឥន្ទធនូកម្ពុជា (“RoCK”)
- សមាគមសុខភាពបន្តពូជកម្ពុជា (“RHAC”)
- បណ្តាញស្ត្រីដើម្បីសាមគ្គីភាព (“WNU”)